# ១. ជ្រើសរើសសុភមង្គល

ការរៀបអាពាហ៍ពិពាហ៍ ឬរៀបការ ឬបានគ្នាជាគូស្រករ ឬបានគ្រួសារ ឬបានប្តីប្រពន្ធ ជាលក្ខណៈធម្មជាតិ និងជាសេចក្តីត្រូវការ យ៉ាងហោចណាស់ក៏មួយជីវិតម្តងរបស់បុរស-ស្ត្រីទូទៅនៅលើលោកនេះ ។ ការរៀបអាពាហ៍ពិពាហ៍ ជាសេចក្តីសំរេចចិត្តមួយដ៏ធំរបស់បុរស-ស្ត្រី ក្នុងការរួមរស់ជាមួយជនដែលខ្លួនស្រឡាញ់ពេញចិត្ត ដើម្បីបំពេញនូវសេចក្តីត្រូវការក្នុងការរស់នៅជាគូៗ ដើម្បីបំពេញនូវសេចក្តីត្រូវការខាងភេទ និងបន្តពូជពង្សរបស់មនុស្សឱ្យមានជាអង្វែងទៅទៀត ។ ដូច្នេះហើយទើបបានជា ការរៀបអាពាហ៍ពិពាហ៍មានសារសំខាន់ណាស់សំរាប់ជីវិតរបស់គេម្នាក់ៗក្នុងការស្វែងរកនូវអ្វីដែលគេហៅថា *សុភមង្គលសំរាប់ជីវិតនៃការរៀបអាពាហ៍ពិពាហ៍* ។ ខ្មែរយើងបានឱ្យតម្លៃទៅលើការជ្រើសរើសបុរស-ស្ត្រី មកធ្វើជាគូអាពាហ៍ពិពាហ៍ខ្លួនណាស់ ទើបបានជាបង្កើតពាក្យស្លោកនាំគ្នានិយាយថា « *ធ្វើស្រែខុស ២-៣ ឆ្នាំ គង់មានត្រូវ ១ ឆ្នាំ យកប្តីប្រពន្ធតែខុសម្តងគឺខុសមួយជីវិតហើយ* » ។

ដើម្បីសម្រេចនូវសុភមង្គលជីវិតរបស់ខ្លួន អ្នករៀបអាពាហ៍ពិពាហ៍ តែងមានទ្រឹស្តី និងមានទស្សនៈផ្សេងៗគ្នា សំរាប់ធ្វើដំណើរទៅរកសុភមង្គល ៖

១. អ្នកខ្លះថា សុភមង្គលស្ថិតនៅលើមាស ប្រាក់ ពេជ្រ កែវ កង ដូច្នេះគេគិតតែស្វែងរក ស្រមៃ យល់សប្តិតែពីរបស់ទុំះប៉ុណ្ណោះ ដល់មិនបានដូចចិត្ត ឬបាត់បង់នូវវត្ថុនោះទៅ គេក៏ចាប់ផ្តើមកើតទុក្ខ មានបញ្ហាក្នុងជីវិតគ្រួសាររបស់គេភ្លាម ។ នៅក្នុងរឿងផ្កាស្រពោន យាយនួនដែលជាម្តាយនាងវិធាវី យល់ថា សុភ-

មង្គលស្ថិតនៅលើការមានទ្រព្យសម្បត្តិច្រើនរបស់កូនប្រសារគាត់គឺ ណៃសិត ។

២. អ្នកខ្លះយល់ថា សុភមង្គលស្ថិតនៅលើអំណាច បុណ្យសក្តិ កេរ្តិ៍ឈ្មោះ ដូចជាករណីម្តាយនាងមារ ដែលចង់លើកកូនទៅឱ្យកូនលោកអរជូន ។

៣. អ្នកខ្លះយល់ថា សុភមង្គលស្ថិតនៅលើការយល់ចិត្តគ្នាទៅវិញទៅមក ការស្រឡាញ់គ្នារស់ពិចិត្តពិថ្លើម ការមានអនុស្សាវរីយ៍កំសត់កម្រនឹងគ្នា ដូចជានៅក្នុងរឿងកូឡាបប៉ៃលិន ដែលហ្មុនឌារីជាបុត្រីគហបតី សុខចិត្តទៅស្រឡាញ់ចៅចិត្រ ជាកូនកំព្រា អ្នកក្រមកធ្វើជាគូជីវិតរបស់ខ្លួន ។

៤. អ្នកខ្លះយល់ថា សុភមង្គលស្ថិតនៅលើការគ្រប់គ្រាន់ខាងសម្ពន្ធភាគភោគ ឬការសេវនកិច្ច ពិសេសនៅក្នុងសង្គមឧស្សាហកម្មនៃសង្គមអឺរ៉ុប ។

៥. អ្នកខ្លះមិនយល់ថា អ្វីជាសុភមង្គលនៃអាពាហ៍ពិពាហ៍ទេ ជីវិតមានគូស្រករបស់គេគឺ ការរស់នៅបែបជាមួយថ្ងៃ១មិនមានខ្វាយខ្វល់អ្វី យ៉ាងណា ក៏យ៉ាងនោះទៅ បែបគ្មានទិសដៅអ្វីសោះក៏មានដែរ ។

ទាំង ៥ ប្រភេទនៃសុភមង្គលរបស់ជីវិតអាពាហ៍ពិពាហ៍នេះ អ្នកខ្លះក៏សមបំណង អ្នកខ្លះក៏ខុសបំណង គ្មានអ្វីជាមាត្រដ្ឋានឱ្យច្បាស់លាស់ថាអ្វីដែលល្អជាងគេនោះទេ ស្រេចតែអ្នកណារើសយកមួយណាក៏យកទៅ ផ្សេងតាមព្រេងវាសនា តាមមាន តាមបាន ។

ចំពោះអ្នក តើអ្នកជ្រើសយកសុភមង្គលប្រភេទណា ? មាសប្រាក់ ? អំណាច ? ការយល់ចិត្តគ្នា ? ភោគសម្ព័ន្ធ ? ឬក៏បណ្តោយទៅតាមព្រេងវាសនាឬ ?

អ្នកជ្រើសរើសយកមួយណាក៏បានដែរ បើអ្នកយល់ថាមួយហ្នឹងវាល្អសំរាប់អ្នកហើយ គ្រាន់តែថា បើអ្នកសំរេចចិត្តហើយ សូមអ្នក*កុំស្តាយក្រោយ* ឱ្យ

សោះ ព្រោះការស្តាយក្រោយពុំអាចជួយអ្វីអ្នកបានទេ ។

បើអ្នកមិនអាចសំរេចចិត្តក្នុងការជ្រើសរើសទេនោះ សុំកុំឱ្យតែអ្នកបណ្តោយជីវិតរបស់អ្នកខ្ជះខ្ជាយក្នុងជលសាឱ្យសោះ ព្រោះជីវិតនេះមានតម្លៃណាស់ ។ បើអ្នកសួរខ្ញុំ ខ្ញុំនឹងប្រាប់អ្នកបាន តែអ្នកមិនបាច់បង្ខំចិត្តថា ត្រូវតែជឿខ្ញុំទេ សូមពិចារណាត្រិះរិះឱ្យបានល្អិតល្អន់ជាមុនសិន សឹមសំរេចចិត្ត ។ ធ្វើដូច្នេះទើបអ្នកមានឈ្មោះថាជាមនុស្សដែលមានវិញ្ញាណ ។ បើអ្នកសំរេចចិត្តថាសួរខ្ញុំ សូមអញ្ជើញបើកទំព័របន្ទាប់ ហើយអានដោយការយកចិត្តទុកដាក់ចុះ ជួនកាលអ្នកនឹងអាចជឿខ្ញុំ ក៏បានដែរ ។

សូមអញ្ជើញដោយមេត្រីភាព !

WAT KHEMARARATANARAM

# ២- សេចក្តីសុខ
# មូលដ្ឋាននៃសុភមង្គល

ក្នុងព្រះពុទ្ធសាសនា មានពាក្យទូន្មានជាច្រើនដែលទាក់ទងទៅនឹងជីវិតអាពាហ៍ពិពាហ៍របស់បុរស-ស្ត្រី ដែលព្រះសម្មាសម្ពុទ្ធលោកបានសំដែងដល់គូស្វាមីភរិយា ដែលតែងមកសាកសួរព្រះអង្គអំពីបញ្ហាសុភមង្គលជីវិត ។

តទៅនេះ គឺជាទស្សនៈរបស់ព្រះសម្មាសម្ពុទ្ធ ដែលទាក់ទងទៅនឹងជីវិតអាពាហ៍ពិពាហ៍ ដែលខ្ញុំសូមលើកយកមកធ្វើសេចក្តីពន្យល់ទុកជាគតិក្នុងការធ្វើដំណើរលើវិថីជីវិតដែលសែនលំបាក ។

សុភមង្គលនៃជីវិតអាពាហ៍ពិពាហ៍ តាមទស្សនៈរបស់ព្រះពុទ្ធសាសនា គឺស្ថិតនៅលើសេចក្តីសុខ នៅក្នុងគ្រួសាររបស់ខ្លួនដែលមើលនៅក្នុងវិមាត្រ ៣ យ៉ាង ខាងក្រោម ៖




WAT KHEMARARATANARAM

### ក. សុខមើលតាមបន្ទាត់ឈរ

សុខមើលតាមបន្ទាត់ឈរនេះមាន ២ យ៉ាងគឺ សុខកាយ និងសុខចិត្ត ។ សុខកាយ គឺការដែលមិនអាចមានជំងឺផ្សេងៗ កាយមិនពិកលពិការ កាយរឹងប៉ឹង មាំមួន អវៈយវៈទាំងអស់មានសុខភាពមាំមួន ធ្វើការងារបានគ្រប់យ៉ាងទាំងអស់ មានអាយុយឺនយូរ ។ សុខកាយម្យ៉ាងទៀតគឺ ការដែលមានគ្រឿងឧបភោគបរិភោគគ្រប់គ្រាន់ មានបច្ច័យ ៤ គ្រប់គ្រាន់ គឺមានសំលៀកបំពាក់ ខោ អាវ គ្រឿងអលង្ការតុបតែងខ្លួនគ្រប់គ្រាន់ មានផ្ទះសម្បែង ទីសំណាក់ស្រួលបួល មានយានជំនិះ មានម្ហូបអាហារគ្រប់គ្រាន់ ត្រឹមត្រូវទៅតាមក្បួនអនាម័យ និងមានថ្នាំសំរាប់ព្យាបាលជំងឺបានគ្រប់គ្រាន់ ។ សេចក្តីសុខខាងកាយនេះ ជាសេចក្តីសុខដែលគេស្គាល់គ្រប់គ្នា ហើយដែលគ្រួសារនីមួយៗតែងប្រាថ្នា ។ តែសេចក្តីសុខប្រភេទនេះ មិនទាន់គ្រប់គ្រាន់ទៅនឹងសេចក្តីត្រូវការរបស់សុភមង្គលទេ ព្រោះថា ឧទាហរណ៍ បើអ្នកជាអ្នកមានទ្រព្យសម្បត្តិច្រើនហូរហៀរ តែអ្នកជាមនុស្សដែលមើលមុខគ្នាពេលណា ឈ្លោះគ្នាពេលហ្នឹង ចិត្តអ្នករំពៃចង់បានតែទ្រព្យថែមទៀត មិនចេះឆ្អែតឆ្អន់ រហូតដល់កើតទៅជាមានជំងឺរសាប់រសល់រកសុខគ្មាន អ្នកមានតែការព្រួយបារម្ភរាល់ពេល ខ្លាចតែគេលួចទ្រព្យ អ្នកខ្វះការកក់ក្តៅក្នុងក្រុមគ្រួសារ ប្តីប្រពន្ធកូនរបស់ខ្លួន ប្រព្រឹត្តតែអំពើ អបាយមុខ ដែលលោកហៅថា ភ្លក់ស្រា ភ្លក់ស្រី ភ្លក់ល្បែងពាណា ។ ល ។ នោះជីវិតរបស់អ្នកនឹងមិនមានសេចក្តីសុខឡើយ ។ អ្នកមានទ្រព្យច្រើនមែន តែជួនកាលអ្នកមិនអាចមានសេចក្តីសុខ ដេកលក់ស្រួលស្មើនឹងជីវិតគូស្វាមីភរិយាខ្លះដែលក្រទ្រព្យសម្បត្តិ តែចេះស្រឡាញ់គ្នាល្អកល្អឺននោះឡើយ ។ ដូច្នេះហើយ សេចក្តីសុខខាងផ្លូវចិត្ត ទើបជាសេចក្តីសុខដែលសំរាប់បន្ថែមឱ្យពេញទៅលើសេចក្តីសុខ

ខាងផ្លូវកាយ ដើម្បីឱ្យសុភមង្គលខាងអាពាហ៍ពិពាហ៍មានតុល្យភាព ។




*ខ. សុខមើលតាមបន្ទាត់ដេក*

សុខមើលតាមបន្ទាត់ដេកនេះ មាន ៤ យ៉ាង ៖

*១. អត្ថិសុខ* គឺសុខដែលកើតអំពីការមានទ្រព្យសម្បត្តិ មានការរីករាយសប្បាយចិត្ត មានមោទនភាពចំពោះខ្លួន ថាខ្លួនមានទ្រព្យសម្បត្តិដែលបានមកដោយការប្រកបការងារដោយកម្លាំងញើសឈាម ព្រោះសេចក្តីព្យាយាមរបស់ខ្លួនទាំងពីរនាក់ប្តី-ប្រពន្ធ និងជាទ្រព្យដែលបានមកដោយសុចរិតត្រឹមត្រូវតាមធម៌ ។

*២. ភោគសុខ* គឺសុខដែលកើតអំពីការបានប្រើប្រាស់ទ្រព្យសម្បត្តិ មានសេចក្តីរីករាយសប្បាយចិត្ត ថាខ្លួនបានប្រើប្រាស់ទ្រព្យសម្បត្តិដែលខ្លួនរកបានមកដោយសុចរិតនោះ ចិញ្ចឹមគ្រួសារខ្លួន ជួយអ្នកដែលគួរជួយ ធ្វើបុណ្យ ធ្វើទាន និងបំពេញប្រយោជន៍ដល់ក្រុមគ្រួសារខ្លួន អ្នកដទៃ និងសង្គម ។ ជាអភ័ព្វណាស់ដែលគ្រួសារខ្លះមានទ្រព្យសម្បត្តិ តែជាមនុស្សកំណាញ់ សូម្បីតែខ្លួនឯង ប្រពន្ធកូន ក៏មិនហ៊ានចាយវាយ ស្លាប់ទៅសល់ទ្រព្យទុកឱ្យគេមទេ ។ បើយ៉ាងនេះ ការមានទ្រព្យសម្បត្តិច្រើន តែមិនបានចាយ ពិតជាមិនអាចមានសុភមង្គលទេ ។

*៣. អនណសុខ* គឺជាសេចក្តីសុខដែលកើតអំពីការមិនមានជំពាក់បំណុល

បំណុលគេ មានចិត្តសប្បាយរីករាយ សប្បាយចិត្ត មិនខ្មាសអៀន និងឱ្យអ្នកណាមកស្តីជេរ ទារបំណុល ឬមុខក្រាស់ដើរទៅខ្ចីគេ ។ តាមពិតទៅ បើទោះជាមិនមានទ្រព្យសម្បត្តិ ក៏មិនសូវមានបញ្ហាដែរ តែបើលតែជំពាក់គេហើយនោះ សេចក្តីទុក្ខខាងផ្លូវកាយ និងផ្លូវចិត្ត ប្រាកដជាចូលមកគ្របដណ្តប់ជីវិតតែខ្លាំងជាពុំខាន ។

៤. *អនវជ្ជសុខ* ជាសេចក្តីសុខដែលកើតពីការប្រព្រឹត្តិ ដែលមិនមានទោស គឺមានសេចក្តីសុខ សប្បាយរីករាយ មានមោទនភាពលើខ្លួន ថាខ្លួនមានការប្រព្រឹត្តិដ៏សុចរិត មិនហោរហៅ មិនមានទោសពៃរ៍ទាំងកាយវាចាចិត្ត ដែលនឹងអាចឱ្យសមាជិកគ្រួសារខ្លួន ឬអ្នកដទៃឯណាមួយ ឬដោយហោចទៅ សូម្បីតែខ្លួនឯងអាចមកតិះទៀន រិះគន់ ជេរស្តី ចាប់ចង ឬបៀតបៀនខ្លួនឡើយ ។ បើនិយាយឱ្យខ្លីទៅ មនុស្សដែលគ្មានទោសពៃរ៍ ចង់ដើរ ចង់ដេក ចង់ឈរ ចង់អង្គុយ ក៏មានការស្រួល សប្បាយចិត្ត មិនព្រៃងរអែងគ្រប់ពេលវេលា សូម្បីតែដល់ពេលរៀបស្លាប់ ក៏មិនភ័យថានឹងធ្លាក់ទៅកាន់អបាយភូមិឡើយ ។



*គ. សុខមើលតាមបន្ទាត់បញ្ញិត*

សេចក្តីសុខតាមបញ្ញិតនេះ ជាគោលនៃសេចក្តីសុខដែលបង្រួមនូវសេចក្តីសុខទាំង ២ ខាងដើម និងជាសេចក្តីសុខរឹតតែមានទំហំធំជាងសេចក្តីសុខណាៗទាំងអស់ ។ សេចក្តីសុខនេះមាន ២ លំដាប់គឺ :

*១. លោកិយសុខ* : គឺជាសេចក្តីសុខនៅក្នុងបច្ចុប្បន្នជាតិនេះ ឥឡូវនេះ គឺទាំងសុខកាយ សុខចិត្ត សុខព្រោះមានទ្រព្យ សុខព្រោះចាយទ្រព្យ សុខព្រោះមិនជំពាក់គេ និងសុខព្រោះមិនមានទោសពៀរ ។ សុខនេះជាសេចក្តីសុខដែលជាប់ជំពាក់ដោយវត្ថុប្រកបដោយលោភៈ ទោសៈ មោហៈ ប្រឡាក់ប្រឡូសដោយកិលេស មានអាយុនៃការសោយសុខខ្លី មិនយឺនយូរ មិននិរន្តរ៍ បន្តិចអណ្តែត បន្តិចលិច មិនទៀងស្ថិតនៅមិនបានយូរ ជាទុក្ខ មិនមានអ្នកណាអាចបង្គាប់បញ្ជាថា ឱ្យទៅជារបស់ផងខ្លួនបានឡើយ ។ លោកឧបមាសេចក្តីសុខប្រភេទនេះ ថាដូចជាមនុស្សដែលកើតរមាស់ ពេលដែលរមាស់ក៏យកដៃទៅអេះ ។ អេះទៅស្រួលទៅៗ លុះដល់អេះរួចហើយ ក៏ក្រហាយ ចេញឈាម ក្លាយទៅជាខ្ទុះទៅទៀត ។ តែទោះជាយ៉ាងណាក្តី បើបានសេចក្តីសុខជាលោកិយ ដូចបានអធិប្បាយខាងលើនេះ ក៏ឈ្មោះថាប្រសើរដែរហើយ ។

ដើម្បីឱ្យសេចក្តីសុខនោះ ទៅជាសេចក្តីសុខទៀងទាត់ មានសម្បូរណ៍ភាព និងមិនក្លាយទៅជាទុក្ខវិញនោះ ព្រះអង្គទ្រង់បង្ហាញនូវសេចក្តីសុខដ៏កំពូលមួយទៀត ដែលមនុស្សគ្រប់រូបត្រូវដើរឱ្យដល់គឺ :

*២. លោកុត្តរសុខ* ដែលជាសេចក្តីសុខខាងផ្លូវចិត្ត ជាសេចក្តីសុខដែលមិនជាប់ជំពាក់ទៅនឹងវត្ថុ ជាសុខដែលមិនប្រែប្រួល និងមិនមានទុក្ខទោសបន្តិចណា

នោះ ។ សេចក្តីសុខនេះ យើងស្គាល់នៅក្នុងនាមថាព្រះនិព្វាន ។ សុខនេះមិនមានខ្វល់ខ្វាយក្នុងការចង់បាន មិនមានការក្តៅក្រហាយ ក្រវក្រោធក្នុងចិត្ត មិនវង្វេងទៅក្នុងអធម៌ ។ សេចក្តីសុខនេះ បើប្រៀបទៅនឹងបុរសដែលកើតរមាស់គឺ គាត់មិនយកដៃ " គឺលោកិយសុខ " ទៅអេះទេ គឺគាត់យកថ្នាំរមាស់គឺ *លោកុត្តរសុខ* មកលាប ហើយក៏ជាតែម្តង លែងមានទុក្ខ ឬរមាស់ទៀត ។ សេចក្តីសុខនេះ គេនឹងអាចបានទទួលនៅពេលឥឡូវនេះ រស់នៅលើលោកនេះ មិនចាំបាច់ស្លាប់ទៅហើយ ជាតិមុខទើបបាននោះទេ បើគេមានសេចក្តីព្យាយាមដើម្បីធ្វើសេចក្តីសុខនោះឱ្យកើតឥឡូវ ។

ការបានយល់ដឹងឱ្យច្បាស់នូវអ្វីដែលជាគោលដៅនៃជីវិតអាពាហ៍ពិពាហ៍ ឬដែលហៅថាសុភមង្គលឱ្យច្បាស់លាស់នេះ ជាការចាំបាច់ណាស់ ដើម្បីឱ្យយុវជនៈ និងយុវនារីទាំងឡាយប្រៀបធៀប ប្រមើលមើលនូវទស្សនៈរបស់ខ្លួនលើរឿងសុភមង្គលនៃអាពាហ៍ពិពាហ៍ ថាតើមានលក្ខណៈត្រឹមត្រូវ សម្បូណ៌ហើយឬនៅ ដើម្បីត្រៀមខ្លួនឱ្យហើយស្រេច សម្រាប់រស់ជាមួយគូរបស់ខ្លួន ។

> *ដំណើរជីវិតមិនមែនជារឿងដែលយើងត្រូវបណ្តោយឱ្យទៅជារឿងតាមយថាកម្ម ឬព្រហ្មលិខិតទេ តែជាសង្គ្រាមមួយដ៏ធំ និងកាចសាហាវ ដែលម្នាក់ៗត្រូវរៀបផែនការវាយលុក និងទប់ទល់ ព្រោះផលនៃសង្គ្រាម និងសេចក្តីស្នេហាជាច្រើន គឺបរាជ័យតែប៉ុណ្ណោះ ។*

# ៣- ការជ្រើសរើសគូស្រករ

*« ធ្វើស្រែខុស ២-៣ ឆ្នាំ គង់មានត្រូវ ១ ឆ្នាំ រើសគូស្រករតែខុសម្តង គឺខុសមួយជីវិតហើយ »* នេះជាពាក្យស្លោកខ្មែរលើកឡើង ជាគតិដាស់តឿនដល់បេក្ខជនដែលមានបំណងរៀបអាពាហ៍ពិពាហ៍ដើម្បីស្វែងរកសុភមង្គលជីវិតរួមគ្នា ។ រើសគូស្រករ មិនខុសពីការជ្រើសរើសទិញសម្ភារៈយកមកប្រើប្រាស់ទេ ។ បើយើងទិញរបស់ចាស់ របស់គ្រាំគ្រា របស់មិនល្អ មិនមានគុណភាពយកមកប្រើ យើងក៏នឹងលំបាកចិត្តច្រើន ព្រោះរវល់តែជួសជុល ប៉ះប៉ុន កែកុន គ្រប់ពេលវេលា ។ ទិញអស់លុយ ហើយខាតបង់សំរាប់ជួសជុលទៀត ឬជួនកាលប្រើមិនកើតក៏មាន ។ លើសពីនេះទៅទៀត របស់ខ្លះដែលចាស់ខូចច្រើនពេក អាចនឹងឱ្យអ្នកប្រើប្រាស់ទទួលគ្រោះថ្នាក់ដល់ជីវិតក៏មានដែរ ។ ដូច្នេះ មុននឹងសំរេចទិញគូស្រករយកមកប្រើ គួរតែប្បិពិនិត្យពិចារណា និងជ្រើសរើសឱ្យបានដិតដល់ មុននឹងប្រគល់លុយពីសេចក្តីស្នេហា និងជីវិតរបស់ខ្លួនទៅឱ្យអ្នកនោះ ។ តែរឿងនេះ ពិបាកណាស់ ព្រោះ*ស្នេហាច្រើនតែស្ថិតនៅលើហេតុផលណាៗទាំងអស់* ។

## ១. ការពិចារណាលើព្រឹត្តិកម្ម

មានគូស្វាមីភរិយា ១ គូ បាននាំគ្នាមកទូលសួរព្រះ ថាធ្វើដូចម្តេចដើម្បីឱ្យសេចក្តីស្នេហារបស់គេស្ថិតនៅជានិរន្តរ៍ និងអាចជួបគ្នានៅគ្រប់ៗជាតិទៀត ។ ព្រះសម្មាសម្ពុទ្ធបានប្រាប់ថា មានគោលបដិបត្តិ ៤ យ៉ាង ដែលអាចឱ្យគូស្វាមីភរិយាបានទទួលនូវនិរន្តរភាពនៃអាពាហ៍ពិពាហ៍គេបាន គឺត្រូវមាន : សមសទ្ធា សមសីលា

សមចាគា និង សមបញ្ញា ។

១. *សមសទ្ធា* គឺការដែលគូស្រករមានជំនឿ ទស្សនៈ ការយល់ឃើញ ការស្រឡាញ់ ការចូលចិត្ត ការនិយមរសជាតិ ស៊ីវិល័យ ឧត្ដមគតិ ជីវិតអាពាហ៍ពិពាហ៍ដូចៗគ្នា ប៉ុនគ្នា ឬស្រដៀងគ្នា ។ សទ្ធានេះ មានកម្លាំងខ្លាំងណាស់ ព្រោះបើគូនោះមានសទ្ធាដូចគ្នា គេក៏នឹងប្រព្រឹត្តដើម្បីប្រយោជន៍ដល់គ្នានឹងគ្នា ចុះសម្រុងគ្នាបានយ៉ាងស្រួល ។ ការដែលប្រុសស្រឡាញ់ស្រីប៉ុនគ្នា និងទំហំស្នេហាដែលស្រីមានចំពោះប្រុស ជាកត្តាសំខាន់សំរាប់លើកស្ទួយ និងជំរុញជីវិតអាពាហ៍ពិពាហ៍ ។ ស្នេហាតែម្ខាង១នឹងបានទទួលទុក្ខ ឬសុខតែម្ខាង១ប៉ុណ្ណោះ ដែលនឹងនាំទៅរកភាពរកាំរកូសក្នុងរឿងគ្រួសារ ។ ក្នុងផ្នែកសាសនា សទ្ធាបានដល់ការដែលគូស្វាមីភរិយាមានការជឿលើច្បាប់របស់កម្មប៉ុនគ្នា ថាធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ជាមនុស្សមានហេតុមានផលដូចគ្នា ជឿថាម្នាក់ៗអាចសម្រេចវាសនាជីវិតខ្លួនបានដោយទង្វើរបស់ខ្លួន មិនមែនជាមនុស្សដេកចាំព្រេងវាសនា ឬទ្រាំទទួលយកជីវិត ដែលព្រហ្មលិខិតគូរទុកនោះទេ និងជាអ្នកដែលមានជំនឿក្នុងសាសនាតែមួយដូចគ្នា ។ បញ្ហាចុងក្រោយនេះ ខ្ញុំឃើញថា ព្រោះតែមានជំនឿសាសនាខុសគ្នា បានធ្វើឱ្យក្រុមគ្រួសារជាច្រើនរកាំរកូស បាត់សុភមង្គលជីវិត ដែលជាការឱ្យសោកស្ដាយណាស់ ពិតហើយថាស្នេហាគ្មានព្រំដែនខែប្រពៃណី និងសាសនាទេ ព្រោះជាសេរីភាពរបស់មនុស្ស តែការដែលដៃគូទាំងសងខាងមានសទ្ធាក្នុងសាសនាដូចគ្នា ក៏នឹងនាំឱ្យស្នេហាកើតតែមានរសជាតិខ្លាំងឡើងដែរ ។

២. *សមសីលា* បន្ទាប់ពីការពិចារណាទៅលើកត្តាសទ្ធាហើយ គូអាពាហ៍ពិពាហ៍ ត្រូវមើលពិចារណាទៅទៀត លើដៃគូរបស់ខ្លួនអំពីកត្តាសីល ។ ការពិចារ-

ណាលើកត្តាសីល មានលក្ខណៈដែលត្រូវពិចារណា ៤ យ៉ាងគឺ :

*ក. ឥន្ទ្រិយសំវរសីល* : សីលនេះបានដល់ការប្រើប្រាស់ឥន្ទ្រិយ៍ទាំង ៦ របស់បុគ្គលម្នាក់ៗ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ និងចិត្ត ។ យើងមើលថា តើដៃគូរបស់យើងនោះ ចូលចិត្តមើលអ្វី ស្ដាប់អ្វី ទទួលទានអ្វី ធ្វើកិច្ចការអ្វី និងគិតអ្វី ។ ន័យត្រង់នេះ បានសេចក្ដីថា ព្រឹត្តិកម្មដែលចេញតាមរយៈឥន្ទ្រិយ៍ទាំង ៦ នេះ ស្ថិតនៅក្នុងក្របខ័ណ្ឌសីលធម៌ សុជីវធម៌ ជាសុភាពបុរស សុភាពនារី និងជាឥន្ទ្រិយ៍ដែលមានសមត្ថភាព រវៀសរវៃ មិនស្លក់ មិនទក់មក់ មិនមានទុព្វលភាពជាដើម ។ ជាសរុប ឥន្ទ្រិយសំវរសីល បានន័យថា រូបរាងកាយរបស់ដៃគូយើងនោះ មានសុខៈភាព មានសមត្ថភាពល្អ និងមានគុណធម៌ល្អ ដូចដែលបានអធិប្បាយពីខាងលើ ។ ការមើលទៅលើកត្តារាងកាយនេះ អាចឱ្យដៃគូនីមួយៗយកមកប្រៀបធៀបនឹងខ្លួនថាព្រឹត្តិកម្ម និងចំណង់ចំណូលចិត្តរបស់ដៃគូរបស់ខ្លួន អាចចុះសម្រុងនឹងខ្លួនបានឬទេ ឬបើមិនទាន់ចុះសម្រុងគ្នាទេ ក៏ខំយ៉ាងណាដើម្បី *ឱ្យដើរទៅរកផ្លូវជាមួយគ្នាបាន* ។ ទុំះជីវិតយើង ក៏នឹងមានភាពប្រសើរឡើងជាមិនខាន ។

*ខ. បាដិមោក្ខសំវរសីល* : ឥន្ទ្រិយសំវរសីល ទាក់ទងទៅនឹងរបៀបរៀបរយផ្ទាល់ខ្លួនរបស់ម្នាក់ៗ ឯបាដិមោក្ខសំវរសីល ទាក់ទងទៅនឹងការបញ្ចេញព្រឹត្តិកម្មចំពោះជនដទៃ និងសង្គម ក្នុងលក្ខណៈដែលមិនធ្វើឱ្យខ្លួនឯងក្ដៅក្រហាយ និងអ្នកដទៃ ក៏មិនខូចប្រយោជន៍ ។ គូអាពាហ៍ពិពាហ៍គប្បីពិចារណាឱ្យបានដឹងថា ដៃគូរបស់ខ្លួនជាអ្នកមានសីលឬទេ គឺបានដល់ការដែល :

១. ជាអ្នកមិនកាចឃោរឃៅ ប៉ះដៃយកដៃ ប៉ះជើងយកជើង ឬជាអ្នកពេញចិត្តតែនឹងរឿងសម្លាប់ និងធ្វើបាបមានុស្សណាកម្មឈើរបគេ,

២. ជាអ្នកមិនចេះមានដៃ មានជើង ចេះលួច ចេះឆក់ ចេះប្លន់,

៣. ជាអ្នកមិនចេះខិលខូចរឿងស្រីញី ប្រុសឈ្មោល ប៉ះពាល់ប្រពន្ធប្តីគេ

៤. ជាអ្នកមិនចេះនិយាយកុហក ភូតភរ បោកបញ្ឆោត និយាយតែពាក្យទៀងត្រង់, និង

៥. ជាអ្នកមិនវង្វេង ស្រវឹងទៅដោយការសេពសុរា គ្រឿងញៀន ល្បែងស៊ីសងជាដើម ។

ព្រះពុទ្ធលោកបានចែកប្រភេទនៃជីវិតអាពាហ៍ពិពាហ៍ជា ៤ ប្រភេទ ដោយយោងទៅលើសីល ដែលទាក់ទងទៅនឹងសង្គមរបស់គូស្រករ គឺ ៖

- *ខ្មោចនៅជាមួយខ្មោច* = ប្តីអត់សីល ប្រពន្ធក៏អត់សីល
- *ខ្មោចនៅជាមួយទេពធីតា* = ប្តីអត់សីល ប្រពន្ធមានសីល
- *ទេវតានៅជាមួយខ្មោច* = ប្តីមានសីល ប្រពន្ធអត់សីល
- *ទេវតានៅជាមួយទេពធីតា* = ប្តីមានសីល ប្រពន្ធក៏មានសីល

ខ្មែរយើងមានពាក្យស្លោកថា ប្តីប្រពន្ធនៅជាមួយគ្នាបាន មាល់តែ « *នាងរត់រកអ្នក មេខាតល័ក្ខណ៍រត់រកអាក៏ចាក់អន្ទ្យា* » ។ នាងរត់រកអ្នកគឺ ទេវតានៅជាមួយទេវតា ឯមេខាតល័ក្ខណ៍រត់រកអាក៏ចាក់អន្ទ្យា គឺខ្មោចនៅមួយខ្មោច ។ តែខ្មោចនៅជាមួយខ្មោច ពិតមែនតែសុខ មានសុភមង្គលនឹងគូស្រករខ្លួនមែន តែសុភមង្គលនេះប៉ះពាល់ទៅលើសេចក្តីសុខអ្នកដទៃ ទៅលើសង្គម ដូច្នេះសង្គមក៏នឹងអាចដាក់ទោសត្រឡប់មកវិញ ធ្វើឱ្យភាពសុខស្រួលក្នុងគ្រួសារបាត់បង់ទៅវិញដែរ ។

គ. *អាជីវបារិសុទ្ធិសីល* ៖ គឺការសម្លឹងមើល ឬពិចារណាទៅលើអាជីវកម្ម មុខរបរចិញ្ចឹមជីវិត ថាតើអាជីវកម្មសុចរិត ឬទុច្ចរិត ។ ក្នុងរឿងនេះ នាងរត់រក

អ្នក គួរជ្រើសរើសរកដៃគូរបស់ខ្លួនដែលជាអ្នកមានមុខរបរទៀងត្រង់ រកស៊ីតាមសម្មាអាជីវោ មិនមែនជាចោរ មិនមែនជាអ្នកឆបោក ស៊ីសំណូក លួចទ្រព្យជាតិជាដើម ព្រោះរបរនេះ យូរ ឬឆាប់ នឹងត្រូវវិនាសសាបសូន្យ ត្រូវគេចាប់ចងជាមិនខាន ។ ដៃគូអាពាហ៍ពិពាហ៍ មិនគួរណានឹងសម្លឹងមើលដៃគូខ្លួនត្រឹមតែទ្រព្យសម្បត្តិដែលគេមាននោះទេ តែត្រូវមើលថាតើទ្រព្យនោះបានមកដោយរបៀបណាផង ដើម្បីធានាផល់ជីវិតសុភមង្គលរបស់ខ្លួន ។ ម្យ៉ាងទៀត អាជីវកម្ម និងទ្រព្យសម្បត្តិដែលដៃគូខ្លួនមាន គួរឱ្យសក្តិសមទៅនឹងអាជីវកម្ម និងទ្រព្យរបស់ខ្លួនដើម្បីចៀសវាងការប្រកាន់វណ្ណៈ ឬការមើលងាយគ្នាទៅវិញទៅមក ។

ឃ. *បច្ចយសន្និស្សិតសីល* ៖ គឺការសង្កេតពិចារណា និងជ្រើសដៃគូរបស់ខ្លួន ត្រង់ចំណុចការប្រើប្រាស់ទ្រព្យសម្បត្តិដែលរកបានមកដោយសុចរិតនោះថាតើចាយវាយយ៉ាងណា ខ្ជះខ្ជាយឬទេ មានការសន្សំសំចៃឬទេ ប្រើលើរបស់ដែលមានប្រយោជន៍ឬទេ ។ ព្រះសម្មាសម្ពុទ្ធបានសំដែងពីការប្រើប្រាស់ទ្រព្យសម្បត្តិដែលរកបានមកហើយ ដូចតទៅ ៖

ក. ចិញ្ចឹមខ្លួន មាតា បិតា បុត្រ ភរិយា និងជនដែលនៅក្រោមអាណាព្យាបាលទាំងឡាយឱ្យបាននៅជាសុខសប្បាយ,

ខ. ជួយបំរុងមិត្តភក្តិ និងអ្នករួមការងារឱ្យនៅសុខជា,

គ. ទុកសន្សំដើម្បីការពារ បង្ការពេលមានភ័យអន្តរាយ,

ឃ. ធ្វើពលី ៥ យ៉ាង ៖

- *ញាតិពលី* ៖ សង្គ្រោះញាតិ សាច់សាលោហិត,
- *អតិថិពលី* ៖ ទទួលភ្ញៀវ,

- *បុព្វបេតពលី* ៖ ធ្វើបុណ្យឧទ្ទិសដល់អ្នកដែលស្លាប់ទៅហើយ,
- *រាជពលី* ៖ បង់ពន្ធភាសី អាករ តាមដែលរដ្ឋចែងបញ្ញត្តទុក,
- *ទេវតាពលី* ៖ សក្ការៈ បំរុង ឬធ្វើបុណ្យឧទ្ទិសរបស់ ឬវត្ថុសក្តិសិទ្ធិ ដែលគួរគោរពបូជា តាមទំនៀមទម្លាប់ ជំនឿដែលមានពីដើម ។

*៣. សមចាគា* ចំណុចទី៣ ដែលបេក្ខជនអាពាហ៍ពិពាហ៍គប្បីពិចារណា ជាបន្ទាប់មកទៀត គឺការពិនិត្យមើលទៅលើការលះបង់ ដែលបាលីលោកហៅថា ចាគៈ ។

*ចាគៈ* មានកត្តាដែលត្រូវពិចារណា ២ សណ្ឋាន គឺ ៖ ចាគៈចំពោះគូរបស់ខ្លួន និងចាគៈចំពោះអ្នកដទៃ ។

*ចាគៈចំពោះគូរបស់ខ្លួន* ៖ គឺការដែលម្នាក់មានចិត្តលះបង់ ហ៊ានធ្វើពលិកម្ម ហ៊ានបោះបង់សេចក្តីសុខ សេចក្តីស្រឡាញ់ប្រយោជន៍របស់ខ្លួនទៅលើដៃគូរបស់ខ្លួនប៉ុណ្ណា ប៉ុនស្មើគ្នាឬទេ ។ ព្រោះគូស្វាមីភរិយានិមួយៗ បើម្នាក់ៗគិតតែពីខាងបាន គិតតែពីខាងត្រូវ គិតតែពីសុខដល់ខ្លួនដោយពុំមើល ពុំយកចិត្តទុកដាក់ទៅលើគូរបស់ខ្លួននោះ ការនេះក៏ពុំអាចនឹងនៅជាមួយគ្នាបានសុខដែរ ។ ឧទាហរណ៍ ពេលដែលភរិយារបស់ខ្លួនត្រូវឆ្លងទន្លេ មានប្តីខ្លះមិនរវីរវល់ទាល់តែសោះ គិតតែពីស្រវឹង ឬដើរលេង ដោយភ្លេចគិតថា ពេលនេះភរិយាខ្លួនមានទុក្ខ ខ្លួនត្រូវហ៊ានលះបង់កិច្ចការផ្ទាល់ខ្លួនខ្លះដើម្បីនាងឡើយ ។ ឬដូចភរិយាខ្លះ គិតតែពីចង់បានមាសពេជ្រមកប្រដាប់ខ្លួន ដោយពុំគិតថាស្វាមីខ្លួនត្រូវជួបនឹងការលំបាកយ៉ាងខ្លាំងក្នុងការរកគ្រឿងអលង្ការទាំងនោះ ។ ការដែលពុំហ៊ានលះបង់សេចក្តីប្រាថ្នា ឬការសប្បាយរបស់ខ្លួនឱ្យដៃគូរបស់ខ្លួននោះ ជួនកាលអាចបណ្តាលឱ្យគូរបស់ខ្លួនបាត់បង់ជីវិត ក៏

មានដែរ ។ អ្នកដែលមានការលះបង់ប៉ុនគ្នា គឺអ្នកដែលមានបេះដូងតែមួយ ហ៊ាន ស្លាប់ដើម្បីម្នាក់ទៀត ហ៊ានទទួលទុក្ខដើម្បីឱ្យម្នាក់ទៀតបានសេចក្តីសុខ ។ ក្នុងរឿង ព្រះវេស្សន្តរ នាងមេទ្រីសុខចិត្តលះបង់នូវសេចក្តីសុខផ្ទាល់ខ្លួនព្រះនាង ដើម្បីតាម ចំរើព្រះវេស្សន្តរ ដែលជាគំរូមួយនៃ*ចាគៈ* ។

*ចាគៈចំពោះអ្នកដទៃ* គឺការជួយអ្នកដទៃ លះបង់សេចក្តីសុខផ្ទាល់ខ្លួន ដើម្បីប្រយោជន៍ជនដទៃ ។ ការដែលគូខ្លះ គិតតែពីលះបង់ដល់អ្នកដទៃ តែភ្លេចគិត ដល់គូរបស់ខ្លួនក្នុងផ្ទះ ក៏មិនជាការប្រសើរដែរ ព្រោះនឹងអាចនាំប៉ះទង្គិចដល់សេចក្តី ស្នេហាក្នុងផ្ទះរបស់ខ្លួន ។ យើងសង្កេតឃើញករណីខ្លះដែលប្តីគិតតែធ្វើការជា ប្រយោជន៍សាធារណៈ និងប្រយោជន៍ជាតិខាងក្រៅខ្លះខ្លាំងពេក ភ្លេចគិតគូដល់ គ្រួសាររបស់ខ្លួន តែងតែធ្វើឱ្យភរិយាមានចិត្តក្បត់ទៅមានប្រុសថ្មីជាញឹកញាប់ ។

៤. *សមបញ្ញា* យើងបានសម្លឹងមើលទៅលើបេក្ខជនអាពាហ៍ពិពាហ៍ របស់យើងលើចំណុចទស្សនៈ ការប្រព្រឹត្តិ លះបង់ ៣ រួចមកហើយ ។ ជាបន្តបន្ទាប់នេះ យើងមើលទៅលើចំណុចសតិបញ្ញារបស់ដៃគូយើង ។ ការប្រមើលមើលទៅលើ ចំណុចបញ្ញា គឺមើលទៅលើការឆ្លៀវឆ្លាត ការវាងវៃ ការដឹងខុសត្រូវ មានកិច្ចកល ការចេះដឹង ចំណេះវិជ្ជា បច្ចេកទេស ការសិក្សា ។ គូដែលមានបញ្ញាស្មើគ្នា អាចនឹង រាប់ថាជាគូដែលមានវឌ្ឍនភាពជាងគេក្នុងជីវិតរបស់ខ្លួន ។

*សទ្ធា សីលៈ ចាគៈ និងបញ្ញា* ជាចំណុចដែលត្រូវថ្លឹងថ្លែងឱ្យបានជិតដល់ និងគ្រប់ជ្រុងជ្រោយ មិនមែនមើលតែលើចំណុចណាតែមួយៗនោះទេ ។ យើងអាច ឱ្យតម្លៃជីវិតអាពាហ៍ពិពាហ៍ស្មើនឹង១០០ភាគរយ ដោយចំណុចនីមួយៗស្មើនឹង២៥ ភាគរយ ។ តើយើងចង់បានអាពាហ៍ពិពាហ៍ដែលមានសុខ ១០០ ភាគរយ ឬតែ ២៥

ភាគរយ ? នេះជាចម្លើយដែលបេក្ខជននិមួយៗ ត្រូវឆ្លើយចំពោះអាពាហ៍ពិពាហ៍របស់ខ្លួនដោយខ្លួនឯង ។

## ២. ពិចារណាលើលក្ខណៈទូទៅ

ចំណុចខ្លះៗ តទៅនេះ បេក្ខជនអាពាហ៍ពិពាហ៍ គួរពិចារណាផងដែរ មុននឹងសម្រេចចិត្តដើម្បីរៀបអាពាហ៍ពិពាហ៍ ៖

១. ស្រី ឬប្រុសណា ដែលមានរូបរាងកាយ ពណ៌សម្បុរល្អស្អាតលើសលប់លើខ្លួនយើងពេក ។ ព្រោះការដែលល្អស្អាតជាងយើងពេក អាចនឹងឱ្យយើងធន់នឹងពាក្យនិន្ទារបស់អ្នកជិតខាងមិនបាន ។

២. ស្រី ឬប្រុសណា ដែលមានគេចោមរោមស្រឡាញ់ច្រើនពេក ឬដែលយើងតែងនិយាយថាមានស្នេហ៍ខ្លាំង ។ ស្រី ប្រុសប្រភេទនេះ ច្រើនតែវាយឫក ឬអាងខ្លួនថាមានគេស្រឡាញ់ច្រើន ក៏រករឿងដៃគូរបស់ខ្លួន ។

៣. ស្រី ឬប្រុស ដែលឆ្មៀវឆ្លាតតែនឹងការរាំ ការច្រៀង ការដើរលេងកំសាន្ត ព្រោះនេះជាអបាយមុខ ១ ប្រភេទដែរ ( សូមអានទំព័រខាងមុខ ) ។

៤. ប្រពន្ធ ឬប្តីរបស់អ្នកដទៃ ។ ចំណុចត្រង់នេះ មានទម្ងន់ដែលត្រូវពិចារណាឱ្យបានខ្លាំង ព្រោះនាង ឬអ្នក នឹងបានឈ្មោះថាលួចប្តីគេ លួចប្រពន្ធគេ ប្រពន្ធចុងគេ ជាពាក្យមួយដែលនឹងនាំឱ្យយើងឈឺចាប់ដល់ជីវិតយ៉ាងខ្លាំង ។

៥. ស្រី ឬប្រុសណា ដែលព្រមស្រឡាញ់យើង ព្រោះថាយើងមានទ្រព្យសម្បត្តិច្រើន ឬយសសក្តិ ឋានៈអ្វីមួយ ដែលបណ្តាលឱ្យគេមកស្រឡាញ់យើង ព្រោះត្រូវការពឹងទ្រព្យសម្បត្តិនេះ ឬបុណ្យយសសក្តិ ឋានៈនោះតែប៉ុណ្ណោះ ។

៦. ស្រី ឬប្រុសណា ដែលមានអាយុចាស់ជាងខ្លួនពេក ឬក្មេងជាងខ្លួនពេក ជាឧទាហរណ៍ក្នុងរឿងព្រះវេស្សន្តរជាតក តាជូជកបាននាងអមិត្តតាជាដើម ។ ក្នុងបរាភវសូត្រ លោកបានសំដែងថា ៖

*អតីតយោព្វនោ បោសោ អានេតិ តិម្ពរុត្ថនិ*

*តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ។*

បុរសមានវ័យដែលចាស់ហួសពេក ហើយមានតម្រេកដោយក្តីតណ្ហា នាំយកស្រីក្មេងមកធ្វើភរិយា ហេតុនោះទៅជានាំឱ្យវិនាស ។

៧. ស្រីពេស្យា ឬប្រុស ដែលប្រពន្ធមួយណាក៏សុំលេង ។

៨. ក្រៅពីនេះ ក៏សូមពិចារណាលើចំណុចឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍របស់ស្ត្រី និងបុរសផងចុះ ( អានទំព័រទី២០ និង ២១ ) ។ ចំណុចដែលសំខាន់ គឺថាពេលសំរេចចិត្តហើយ អ្នកមិនអាចនិយាយថា " ស្តាយក្រោយ " បានទេ ។

*ពិតហើយថា ជីវិតដែលពេញបរិបូណ៌មិនមានទេ*
*តែបើយើងប្រើការត្រិះរិះពិចារណារបស់យើងឱ្យ*
*បានត្រឹមត្រូវ រួមនឹងសេចក្តីព្យាយាមនោះហើយ*
*យើងអាចនឹងបានជីវិតមួយដែលជិតពេញដែរ ។*

# ៤- នាទីក្រោយអាពាហ៍ពិពាហ៍

អ្នកខ្លះគិតថា តែរៀបការរួចហើយ គឺចប់ហើយ ។ តាមពិត មិនចប់ទេ សាច់រឿងនៅវែងឆ្ងាយណាស់ ហើយជួនកាលត្រូវមានគ្រោះថ្នាក់ មុននឹងចប់សាច់រឿងក៏មានដែរ ។ ខ្លះរៀបការបានពីរ-បីថ្ងៃ លែងលះគ្នាក៏មាន ខ្លះបានមួយឆ្នាំ ខ្លះបានកូនមួយ ខ្លះកូនរហូតដល់ទៅ ៥ ហើយ លែងលះគ្នាក៏មានដែរ ឯខ្លះនៅរហូតដល់ចាស់ស្លាប់រៀងខ្លួន សមនឹងពរចាស់ៗប្រសិទ្ធិថា « *សូមឱ្យកូនចៅទាំងពីរនៅថែរក្សាគ្នារហូតដល់ខាំចេករបួត ខាំពោតរបេះ ខ្មោចទាល់តម្រិះធ្វើមិនត្រូវ* » «*រកស៊ីកើតកាលវាលគុត្ត ត្រជាក់ត្រជុំដូចទឹកអប់ចំពង់ខ្លី* » ជាដើម ។

ធម្មៈទាំង ៤ ប្រការគឺ សមសទ្ធា សមសីលា សមចាគា និងសមបញ្ញា មិនមែនត្រឹមតែជាគោលពិចារណាមុនពេលរៀបអាពាហ៍ពិពាហ៍នោះទេ គឺទាំងក្រោយពេលរៀបអាពាហ៍ពិពាហ៍នេះឯង ដែលជាគោលចាំបាច់ ។ គឺបើយើងភ្លាំងភ្លាត់ មិនបានពិចារណារើសជាមុនទេនោះ ក៏គប្បីពិចារណា និងរៀបចំខ្លួនឱ្យសមទៅតាមគោលទាំង ៤ នេះរៀងខ្លួន គឺម្នាក់ៗដែលជាដៃគូ ខំធ្វើយ៉ាងណាតម្រង់ពង្រឹងការស្មើគ្នារវាងជំនឿ ទស្សនៈ ការប្រព្រឹត្តិ ការលះបង់ និងបញ្ញារបស់ខ្លួនឱ្យបានស្មើគ្នា ឬត្រដិត្រដុសងគ្នារហូតដល់អស់មួយជីវិតអាពាហ៍ពិពាហ៍របស់ខ្លួន ។ បើនិយាយតាមភាសារឿងល្ខោន ធម្មៈទាំង ៤ ប្រការនេះ គឺជាដួងចៃ ឬដួងជីវិតសំរាប់គូស្វាមីភរិយានោះឯង បាត់ដួងចៃពេលណា ជីវិតត្រូវអស់ពេលនោះដែរ ។

ក្រៅពីការខំថែរក្សាផ្លូងថៃទាំង ៤ ប្រការនេះហើយ ប្តីភរិយាត្រូវបំពេញនាទីសំខាន់ៗ ៣ ប្រការ ចំពោះសង្គមថ្មីដែលខ្លួនត្រូវរស់នៅជាមួយ ។ នាទីទាំង ៣ ប្រការនោះគឺ នាទីចំពោះគូស្រកររបស់ខ្លួន នាទីចំពោះបុត្រធីតា និងនាទីចំពោះសង្គម ។




*ឥន្ទារម្មណ៍របស់បុរស និងស្ត្រី*

ជាការធម្មតា បុរស-ស្ត្រី ចង់បានគូស្រករ ឬចង់ឱ្យដៃគូរបស់ខ្លួនមានលក្ខណៈ ដូចតទៅគឺ :

- ចង់ឱ្យដៃគូរបស់ខ្លួនជាមនុស្សរូបស្អាត សង្ហា មានអនាម័យ ចេះតុបតែងខ្លួនសមគួរដល់ឋានៈ និងទ្រព្យសម្បត្តិ ស្គាល់របៀបរបបស្លៀកពាក់មានម៉ូដទាន់សម័យ ។

. ចង់ឱ្យដៃគូរបស់ខ្លួនមានសីល សុភាពរាបសាម ស្គាល់ខុសត្រូវ មានចរិយាមារយាទមិនកោងកាច មិនចេះផឹកស៊ី កាប់ចាក់ លេងល្បែងស៊ីសង សេពគប់មិត្តអាក្រក់ ។

. បើដៃគូរបស់ខ្លួនអាចផ្តល់កំណើតនូវបុត្រដល់ខ្លួនបាន គឺមិនមែនជាស្រីអារ ឬប្រុសអារនោះ ក៏រមែងត្រេកអររីករាយពេញចិត្តជាពន្លឹក ។ និយាយតាមភាសាថ្មី គឺជាអ្នកដែលមានសមត្ថភាពក្នុងការបង្កើតកូន ក្នុងការបន្តពូជ ក្នុងការរួមសង្វាស់ជាមួយដៃគូរបស់ខ្លួនតាមសមគួរ ។ តើនរណាឡើយ នឹងពេញចិត្តចំពោះដៃគូដែលមានអវៈយវៈភេទប្រើការមិនកើតនុ៎ះ ។

. ចូលចិត្ត ពេញចិត្តចំពោះបុរស-ស្ត្រីណា ដែលមានទ្រព្យសម្បត្តិ ឬអាជីវកម្ម និងគម្រិះប្រាជ្ញាដែលជាផ្លូវសំរាប់ឱ្យរកទ្រព្យបាន ។

. ចូលចិត្តដៃគូដែលមិនមែនជាមនុស្សខ្ជិលច្រអូស ជាអ្នកមានសេចក្តីព្យាយាម ឧស្សាហ៍ ដៃនៅមិនស្ងៀម ។

ឯ *អនិដ្ឋារម្មណ៍* ឬការមិនចូលចិត្តរបស់បុរស-ស្ត្រីក្នុងលោកនេះ ក៏មានលក្ខណៈ ៥ យ៉ាងដែរគឺ ផ្ទុយគ្នានឹងឥដ្ឋារម្មណ៍ ដែលបានពោលរួចមកហើយ ។ ការដឹងនូវអ្វីដែលជារបស់ចូលចិត្ត និងមិនចូលចិត្តរបស់គូស្វាមីនិងភរិយា ហើយគូម្នាក់ៗ ក៏គប្បីរៀបចំខ្លួន និងថែរក្សាខ្លួនឱ្យបានប្រសើរ ដើម្បីតបស្នងទៅនឹងសេចក្តីត្រូវការរបស់ដៃគូរបស់ខ្លួនឱ្យបានប្រសើរដែរ ។

## អភិសម្ពន្ធភាពនៃគូស្រករ

សម្ព័ន្ធដែលនឹងផ្ទាញ់ទៅបាននោះ ព្រោះអាស្រ័យគ្រឿងទេសផ្សេងៗដែល

ចុងភៅយកមកផ្សំទៅតាមក្បួនម្ហូបអាហារ មិនមែនដាក់ត្រឹមតែទឹក បង់ត្រី និងបង់អំបិលចូលទៅក៏ស្រេច ហើយថាឆ្ងាញ់នោះទេ ។ សេចក្តីស្នេហាក៏ដូចគ្នាដែរ រូបស្អាតក្តី ការប្រព្រឹត្តិល្អក្តី សមត្ថភាពក្នុងរឿងភេទក្តី ទ្រព្យក្តី សេចក្តីព្យាយាមក្តី ពិតមែនតែជាចំណង់ចំណូលចិត្តរបស់បុរស និងស្ត្រីមែន តែកាលបើខ្វះគ្រឿងផ្សំផងនោះ ម្ហូបអាហារនេះអាចនឹងកើតការធុញទ្រាន់ក៏បានដែរ ដូច្នេះជាការចាំបាច់ណាស់ដែលចុងភៅស្នេហា ត្រូវចេះផ្សំគ្រឿងម្ហូបអាហាររបស់ខ្លួនឱ្យឆ្ងាញ់ជាប់ជានិច្ច ។ គ្រឿងនេះអាចធ្វើឱ្យស្នេហានោះ រឹតតែមានជីវជាតិ និងសុភមង្គលកាន់តែកើន ១ កម្រិតទៀត ។ គ្រឿងទាំងនេះមាន ៖

*១. រូប ៖* រូបកាយ សម្ផស្ស ជាគ្រឿងដំបូងបង្អស់ ។ ពិតហើយដែលតាមព្រះពុទ្ធសាសនា រូប គឺជារបស់ដែលមិនអាចស្ថិតស្ថេរអស់មួយជីវិតបានទេ ។ ឥឡូវនេះ នាង ឬអ្នក ស្អាតផូរផង់ មុខស្រស់បស់ ស្បែកតឹងរលោង តែមិនយូរប៉ុន្មានទេអ្នក ឬនាង នឹងមានស្បែកជ្រីវជ្រួញ មុខជាំ កម្លាំងខ្សោយ មុខមិនស្រស់បស់ ដូចកាលពីក្រមុំ-កម្លោះ ឬទើបនឹងរៀបការហើយថ្មីៗនោះទេ ។ តែទោះជាយ៉ាងនេះក្តី ការថែរក្សារូបរាងកាយ សម្ផស្ស ស្បែក កម្លាំងពលំ ជាការចាំបាច់ណាស់ មិនត្រូវបណ្តែតបណ្តោយទៅតាមធម្មជាតិនោះទេ សម័យឥឡូវនេះ មានម្សៅ មានថ្នាំរក្សាសម្ផស្សមុខ មាត់ សក់ ស្បែក ក៏មានប្រសិទ្ធិភាពណាស់ ដូច្នេះ ស្វាមីភរិយាគួរចេះតុបតែង ថែរក្សាខ្លួនប្រាណ កម្លាំងពលំរបស់ខ្លួនឱ្យបានល្អប្រពៃ ។ ផាត់ម្សៅ លាបសក់ សិតសក់ ស្លៀកពាក់ខោអាវស្អាតបាត មានអនាម័យ រៀបចំទីកន្លែងសម្រាកឱ្យបានស្អាតល្អ ឈ្មោះថាបានធ្វើឱ្យរូបរបស់ខ្លួនក្មេងឡើងវិញជាមិនខាន ។

*២. សើច ៖* ត្រូវចេះសើច និងរកឱកាសសើចឱ្យបានញឹកញាប់រវាងគូ

ស្វាមីភរិយា ។ គេតែងនាំគ្នានិយាយថា សើចច្រើនអាយុវែង ។ មិនតែប៉ុណ្ណោះ មនុស្សមួយចំនួនទៀតតែងនិយាយថា ...

ស្វាមីភរិយា ។ គេតែងនាំគ្នានិយាយថា សើចច្រើនអាយុវែង ។ មិនតប្បីជាមនុស្សមម្មូរតែមុក្ខពិព្រលឹមដល់ព្រលប់ គិតតែមុខក្រញូវនោះទេ ។ ពេលដែលស្វាមី ឬភរិយារបស់អ្នកមកពីធ្វើការហត់នឿយបាត់ខ្លាំង បើអ្នកសើចដាក់ ឬញញឹមយ៉ាងផ្អែមល្ហែមមួយនោះ ស្វាមី ឬភរិយារបស់អ្នកនឹងធូរស្រាលភ្លាមមួយរំពេច ។ ការញញឹមដាក់គ្នា ការសើចដាក់គ្នាធ្វើឱ្យបរិយាកាសរីករាយ ស្រស់បស់គ្រប់កាល ។ អ្នកអាចមិនស្ទាវចេះសើច តែគប្បីរៀនសើច រៀនញញឹមដាក់គូរបស់អ្នក ។ ជីវិតមានការលំបាកណាស់ទៅហើយ អ្នកត្រូវរៀនសើចដាក់ជីវិតខ្លះទៅ ។ សូមទោស ខ្ញុំភ្លេចប្រាប់ ច្បាប់បុរាណលោកហាមថា កុំឱ្យសើចឮផ្ទះពីរ-បី ព្រោះវានាំឱ្យខាតលក្ខណ៍ ។ សើចឮល្មមតែគ្នាអ្នកពីរនាក់ និងគ្រួសារអ្នកបានហើយ ។

*៣. និយាយពីរោះ* : ត្រូវចេះនិយាយពាក្យសំដីពីរោះ ពាក្យលួងលោម ពាក្យផ្ទាក់ផ្ទួមលើកកម្លាំងចិត្តឱ្យដល់គ្នានឹងគ្នា ។ " *អណ្ដាតជាអាទិ៍កន្លង រស់ផងស្លាប់ផង ពីព្រោះអណ្ដាត* " ។ បើអ្នកខុស សូមឱ្យចេះនិយាយសូមទោស បើដៃគូរបស់អ្នកខុស សូមឱ្យអ្នកចេះនិយាយលួងលោមអត់ទោសឱ្យ និងលើកកម្លាំងចិត្តចំពោះការដែលដៃគូអ្នកចេះកែប្រែ ។

តើនរណានឹងសប្បាយចិត្ត បើអ្នកស្ពឹកត្រឹក ស្ពឹកស្វាច ពាំងពិត្រឹកមើលយប់មិនបាត់នោះ ។ រៀននិយាយ និងប្រាប់កិច្ចការពិតផ្ទាល់ខ្លួនដល់ដៃគូរបស់អ្នក បើដៃគូរបស់អ្នកមិនដឹង ។ " *ជោកអ្វីនឹងដៃ ថ្លៃអ្វីនឹងមាត់* " បើអ្នកឃើញស្វាមី ភរិយារបស់អ្នកមិនសប្បាយចិត្តហើយ អ្នកអាចចូលទៅសួរថា" បង ! អូន ! មិនសប្បាយចិត្តរឿងអ្វី បងអាចជួយបានទេ ? គ្រាន់តែប៉ុណ្ណោះ គ្រួសារអ្នកធូរចិត្តបន្តិចទៅហើយ ។

*៤. ច្រៀង* : បើទោះបីអ្នកច្រៀងមិនពិរោះក្តី ការច្រៀងបន្តិចៗនៅនឹងគល់ក អាចនាំនូវមនោសញ្ចេតនាអ្នកចូលទៅក្នុងប្រអប់បេះដូងរបស់ដៃគូអ្នក ជាពិតប្រាកដ ។ បើជាអ្នកច្រៀងតមេវិញនោះ អ្នកគិតមើល តើអ្នកនឹងសប្បាយយ៉ាងណាទៅ ? ការបំពេរគ្នានាំឱ្យគេងលក់ ឬប្រើសំឡេងរបស់ខ្លួនជាបែបបំពោល និងជាមនោសញ្ចេតនា នឹងអាចធ្វើឱ្យដៃគូរបស់អ្នករំភើប និងស្រឡាញ់អ្នករឹតតែខ្លាំងឡើងជាមិនខានដែរ ។ ហាត់ច្រៀងឱ្យចេះ ច្រៀងបន្តិចៗដោយសំឡេងទន់ភ្លន់ និងដាក់មនោសញ្ចេតនាអ្នកទៅក្នុងបទចម្រៀង អ្នកនឹងឃើញប្រសិទ្ធិភាពរបស់វាជាមិនខាន ។

*៥. យំ* : ចេះខ្សឹកខ្សួល ចេះធ្វើមុខស្រងូតស្រងាត់ ចេះព្រួយបារម្ភជាមួយ នៅពេលដែលដៃគូរបស់ខ្លួនមានបញ្ហា ។ ការនេះសំខាន់ណាស់ អ្នកប្រហែលចាំពាក្យខ្មែរដែលនិយាយថា "*ដឹងគ្នាក្នុងគ្រាក្រ សម្បុរល្អនៃកត្តិក* "ហើយ ។ ដូច្នេះ កុំញញើត ឬអៀនប្រៀននឹងសំដែងការចូលរួមចំណែកចំពោះសេចក្តីទុក្ខ ដែលដៃគូអ្នកមាន ។ ជួនកាលបើអ្នកដឹងថាអ្នកខុស ហើយអ្នកធ្វើមុខស្រងូត ឬយំបន្តិចៗផងនោះ ខ្ញុំជឿថាដៃគូអ្នកពិតជាជួយពិបាកចិត្តជាមួយអ្នកជាមិនខាន ។ នាងដែលជាភរិយា ប្រហែលជាធ្លាប់ទស្សនាខ្សែភាពយន្តខ្មែរខ្លះហើយ ត្រង់វគ្គដែលនាងជាភរិយាចុងចង់បានមាស ពេជ្រ តែស្វាមីខ្លួនមិនឱ្យ លុះដល់នាងធ្វើជាយំខ្សឹកខ្សួល ស្រាប់តែស្វាមីនាងឱ្យមួយរំពេច ។ តែខ្ញុំសូមប្រាប់ទុកជាមុន បើនាងយំខ្លាំងៗ ឬននៀលឡើប៉ាផាក់ដី ដូចកូនក្មេងនោះ ស្វាមីនាងអាចនឹងវាយនាងថែមក៏បានដែរ ។ សូមប្រយ័ត្ន !

*៦. ខ្ទិកម៉ូក់* : ចេះសំដែងអាកប្បកិរិយាខ្ទិកម៉ូក់ អៀនប្រៀនធ្វើជានឹង

មុនក្រោយ ងបន្តិចបន្តួច វាសកន្ទុយភ្នែក សម្លក់ដោយស្រឡាញ់ ។ ល ។ ទាំងអស់នេះ នឹងធ្វើឱ្យសាច់រឿងរបស់អ្នករីតតែស្រស់ និងគួរឱ្យស្រឡាញ់ឡើងជាពិតប្រាកដ ។

កុំភ្លេចថា អ្នកត្រូវរក្សាជីវិតអាពាហ៍ពិពាហ៍អ្នកឱ្យបានជានិរន្តរ៍ ដូច្នេះគ្មានរឿងអ្វីដែលអ្នកត្រូវខ្មាសអៀន មិនហ៊ានសំដែងទេ ព្រោះជីវិតជារោងល្ខោនស្រេចទៅហើយ ។ បើអ្នកសំដែងបានល្អ បានស្រស់ អ្នកមើលគឺដៃគូរបស់អ្នកនឹងចង់មើលអ្នកជារៀងរហូត ។

*៧. រង្វាន់* : ត្រូវចេះផ្តល់រង្វាន់ ឬឱ្យនូវរបស់អនុស្សាវរីយ៍ ដូចជាចិញ្ចៀនមាស ពេជ្រ ខោ អាវ តាមឱកាសផ្សេងៗ ដូចជាថ្ងៃខួបមង្គលការ ថ្ងៃខួបអាយុជាដើម ។ ជូនកាល ការទៅផ្សារ ឬធ្វើដំណើរទៅឆ្ងាយ ទៅបរទេស ទៅខេត្តក្រៅលុះត្រឡប់មកវិញ មានឥវ៉ាន់ជាប់ដៃបន្តិចបន្តួចផ្ញើដៃគូរបស់ខ្លួន នឹងធ្វើឱ្យដៃគូរំភើបចិត្តជាពុំខាន ។ ជួនកាលរបស់នោះមិនមានតម្លៃទេ បើគិតជាប្រាក់ តែមានតម្លៃត្រង់ថា ស្វាមី ឬភរិយារបស់ខ្លួននឹកញ្ញាមកផ្ញើនោះឯង ។ ខ្ញុំចង់និយាយឱ្យរឹតតែល្អិតទៅទៀតថា សូម្បីតែពេលបរិភោគបាយ ក៏យើងអាចស្គាល់នូវភាពទាក់ទឹកចិត្តបានដែរ ដោយការបេះនូវចំណែកត្រីដែលល្អៗ ដែលឆ្ងាញ់ ចុកសំរាប់ឱ្យដៃគូរបស់ខ្លួន រៀងៗខ្លួន ឧទាហរណ៍ បើស្ងោរត្រីរស់ នាងភរិយាជ្រើសយកសាច់ថ្គាល់ត្រីទៅឱ្យស្វាមី ឯស្វាមីក៏ចាប់ក្រពះត្រីមកឱ្យប្រពន្ធ ឯប្រពន្ធក៏អាចថា " បងទុកពិសារចុះអាហ្នឹងឆ្ងាញ់ " តែប៉ុណ្ណេះ ក៏ឈ្មោះថាជារង្វាន់ដែរ ។ ម្យ៉ាងទៀត រង្វាន់មិនចាំបាច់តែវត្ថុទេ ការពោលសរសើរក៏ឈ្មោះថាជារង្វាន់ដែរ ដូចជាថា " អូនធ្វើម្ហូបថ្ងៃនេះឆ្ងាញ់ណាស់ " ជាដើម ។

*៨. ផស្សៈ ឬការប៉ះពាល់ ការថ្នាក់ថ្នម ការបបោសអង្អែល ។* ស្វាមីខ្លះ

មិនហ៊ានកាន់ដៃភរិយានៅនឹងមុខគេទេ ព្រោះខ្លាចគេចំអក តែតាមការពិត រឿងនេះធ្វើឱ្យភរិយារបស់អ្នករីករាយណាស់ ។ ការស្ទាបក្បាលលេង ការអង្អែលស្មា ឬខ្នងតិចៗ ជាការបន្ថែមនូវរសជាតិប្លែកដែរ ។ ពេលឈឺ ការដែលដៃគូរបស់ខ្លួនយកដៃមកស្ទាបថ្ងាស ស្ទាបខ្លួន ច្របាច់ដៃជើង ដណ្ដប់ភួយឱ្យ ឬស្រឡាបទឹក នឹងអាចឱ្យអ្នកជំងឺធូរស្រាលមួយកំរិតភ្លាម ឯការដែលព្រងើយកន្តើយ នឹងធ្វើឱ្យមួម៉ៅជាមិនខាន ។

ការបោកគក់ខោអាវឱ្យគ្នា មិនមែនជារឿងថោកទាប ឬអគមង្គលឡើយ ព្រោះគ្មានអ្វីជាអាថ៌កំបាំង ឬថោកទាបសំរាប់គូស្វាមីភរិយាឡើយ ជាពិសេស ពេលភរិយាខ្លួនឈឺ មានកិច្ចរវល់ខ្លាំង ពេលឆ្លងទន្លេជាដើម ។

ក្នុងសង្គមឧស្សាហកម្ម ដែលគូស្វាមី-ភរិយាត្រូវធ្វើការទាំងពីរនាក់ ការជួយគ្នាទៅវិញទៅមក ជាការសម្រាលនូវភារៈរបស់ដៃគូខ្លួន ១ ភាគធំ ។ ជាបញ្ចប់ផស្សៈបានដល់ការបបោសអង្អែលក្នុងលក្ខណៈជាបែបសិល្បៈស្នេហា ពេលរួមដំណេកគ្នា ជារឿងមួយដែលដៃគូម្នាក់ៗទាមទារ និងត្រូវការត្រប់គ្នា ។ ចំពោះប្រទេសដែលល្អគណាស់ គេមានគ្លីនិកសំរាប់ផ្ដល់យោបល់ពីរឿងការរួមដំណេក ។ ក្នុងឥណ្ឌាពីដើម មានគម្ពីរមួយឈ្មោះកាមសាស្ត្រ ដែលជាផ្នែកមួយនៃគម្ពីរត្រៃវេទនៃសាសនាហិណ្ឌូ សំរាប់គូស្វាមីភរិយាតែម្ដង ។

គូអាពាហ៍ពិពាហ៍ថ្មីក្ដី ឬគូអាពាហ៍ពិពាហ៍ចាស់ក្ដី ដែលមានបញ្ហានឹងរឿងមួយអាពាហ៍ពិពាហ៍ខ្លួនមិនទំនងជារសនោះ អាចសាកល្បង និងផ្សំគ្រឿងទាំង ៨ នេះបានគ្រប់ពេលវេលា គឺការតែងរាងកាយ ការចេះសើច ការចេះនិយាយ ចេះច្រៀងចេះយំសោក ចេះបញ្ចេញអាកប្បកិរិយា ចេះផ្ដល់រង្វាន់ និងចេះបបោសអង្អែល ។

អ្នកនឹងឃើញថា ក្រោយពីផ្សំគ្រឿងរួចហើយ ជីវិតអាពាហ៍ពិពាហ៍អ្នកនឹងប្រែទៅរកផ្លូវមួយដ៏ប្រសើរជាមិនខាន ។ សាកល្បងទៅ ព្រោះរបស់នេះមាននៅនឹងអ្នកហើយទេតី មិនបាច់ទៅរកមិញផ្លូវពីណាទេ ។

WAT KHEMARARATANARAM

# ៥- នាទីស្វាមីចំពោះភរិយា

## ១. អ្នកជាស្វាមីប្រភេទណា ?

### ស្វាមី ៧ ជំពូក

*១. វធកាស្វាមី* = ស្វាមីដូចពេជ្ឈឃាត រង់ចាំតែរករឿងវាយតប់ និងសម្លាប់ភរិយាខ្លួន ចិត្តមិនត្រាប្រណី ដូចជាពេជ្ឈឃាតដែលមិនដែលត្រាប្រណី ចំពោះអ្នកទោសរបស់ខ្លួន ។

*២. ចោរស្វាមី* = ស្វាមីដូចចោរ មិនត្រង់នឹងភរិយាខ្លួន ចាំតែលួចបំបាត់ទ្រព្យសម្បត្តិ ឬលាក់លៀមរឿងអ្វីៗនឹងប្រពន្ធ ដូចជាចោរដែលចាំតែលួចទ្រព្យគេ និងលាក់បំបាត់រឿងអាក្រក់ខ្លួនមិនឱ្យគេដឹង ។

*៣. អយ្យាស្វាមី* = ស្វាមីដូចជាចៅហ្វាយ ចាំតែចង្អុលបញ្ជា ខុសស្តីបន្ទោស ប្រើប្រពន្ធធ្វើការដូចជាខ្ញុំបំរើរបស់ខ្លួន ។

*៤. បិតាស្វាមី* = ស្វាមីដូចជាឪពុក មានចិត្តស្រឡាញ់ថ្នាក់ថ្នមប្រពន្ធដូចកូន មើលការខុសត្រូវ រាំងមិនឱ្យកូនធ្វើខុស ការពារកូនគ្រប់ទិសទី ។

*៥. ជេដ្ឋាស្វាមី* = ស្វាមីដូចបងប្រុស ស្រឡាញ់ថែទាំប្រពន្ធ ដូច

WAT KHEMARARATANARAM

បងប្រុសស្រឡាញ់ប្អូន ការពារប្អូន ។

៦. *សខីស្វាមី* = ស្វាមីដូចមិត្តភក្តិ គឺចុកភរិយាខ្លួនស្មើនឹងមិត្ត ពេលជួបគ្នាក៏រីករាយ បានអ្វីក៏ចែកគ្នាតាមនាទីមិត្តគោរពមិត្ត រួមទុក្ខរួមសុខគ្នា ។

៧. *ទាសាស្វាមី* = ស្វាមីដូចទាសា ស្តាប់បង្គាប់ភរិយា ធ្វើការគ្រប់បែបយ៉ាងមិនឱ្យភរិយាខ្លួនព្រួយឡើយ ។

ស្វាមី ៣ ជំពូកខាងលើមិនល្អឡើយ លោកឱ្យចៀសវាងចេញ កុំប្រព្រឹត្តនិងឱ្យរើសយកយ៉ាងណាមួយ ក្នុងចំណោម ៤ យ៉ាងខាងក្រោម ។

## ២. ចំណុចខ្សោយរបស់អ្នកជាស្វាមី

ចំណុចខ្សោយ ១០ យ៉ាងខាងក្រោម អ្នកជាស្វាមីគប្បីដឹង និងពិនិត្យកែខៃខ្លួនឱ្យបានល្អ និងទាន់ពេលវេលា ព្រោះចំណុចខ្សោយនេះ ជាកត្តាដែលអាចឱ្យភរិយារបស់ខ្លួនមើលងាយ ឬធុញទ្រាន់មកលើខ្លួនបាន ៖

១. ជាមនុស្សក្រ មិនមានទ្រព្យសម្បត្តិអ្វីសោះ ។ ក្រនេះអាចរួមដល់ការក្រគំនិត ក្របញ្ញា ឬដូចសម្តេចព្រះសង្ឃរាជលោកតែងជាពាក្យថា " ក្រកិច្ច ក្រកល់ ក្រដឹង ក្រយល់ ក្រវៃឆ្លៃឆាស់ " ។

២. ជាមនុស្សដែលមានជំងឺជាប់ជានិច្ច ជំងឺរ៉ាំរ៉ៃ មួយថ្ងៃកាត់ មួយថ្ងៃកោរ រកថ្ងៃជានោះតិច បន្តិចឈឺៗ ។

៣. ជាមនុស្សចាស់ គ្រាំគ្រា ទុព្វលភាព រាងកាយមិនមាំមួន ចាស់ជរាចូលតម្រោតាដូជក និងនាងអមិត្តធីតា ធ្វើអ្វីមិនកើត ត្រូវពឹងភរិយាខ្លួន ។

៤. ជាមនុស្សស្រវឹងអ្វីមិនដឹង ដើរដេកតាមផ្លូវក្របី ឬតាមផ្លូវជាដើម ពេល

ស្រវឹង ក៏ធ្វើអាការៈចោកទាប អាក្រាតខ្លួន ឬពុំនោះសោត ក៏វាយប្រពន្ធកូន ។

៥. ជាមនុស្សល្ងង់ ទក់មក់ ទ្រើក១ មិនស្វាគ្រប់ ១០ ។

៦. ជាមនុស្សធ្វេសប្រហែស ខ្ជិលខ្ជា គ្មានសតិ មានសេចក្ដីប្រមាទច្រើន ។

៧. ធ្វើអ្វី ធ្វើមិនជាក់លាក់ ចាប់នេះ ចាប់នោះមិនគ្មោះត្រង់ណា ធ្វើនេះបន្តិច ធ្វើនោះបន្តិច ចាប់ការឱ្យពិសពាស មិនច្បាស់អ្វីសោះ ។

៨. ខ្ជិលច្រអូស មិនធ្វើការងារ ដេកចាំតែស៊ី ចាំតែអង្គុយបង្ហាញ ពឹងតែកម្លាំងប្រពន្ធ រកស៊ីដូចសត្វប្រឡាំងកាស ។

៩. មិនប្រឹងប្រែងរកទ្រព្យសម្បត្តិយកមកទុកដាក់ ។

១០. បំផ្លាញទ្រព្យសម្បត្តិឱ្យវិនាសទៅដោយអបាយមុខ ឬដោយប្រការណាមួយ ។

## ៣. ស្គាល់ពីភរិយារបស់អ្នក

ការរួមរស់ជាមួយគ្នា មិនមែនជាការស្រួលទេ បើគេពុំបានស្គាល់គ្នា ឬប្រពន្ធ ឬពុំព្រមស្គាល់គ្នាឱ្យបានច្បាស់លាស់ ។ ស្វាមីស្គាល់ភរិយា ភរិយាស្គាល់ស្វាមី ជាពាក្យដែលមានន័យថា ស្វាមីភរិយាខ្លួនមិនមែនជាអ្នកដទៃ មិនមែនជាមនុស្សប្លែកមុខ ឬសត្រូវទេ ។ ការស្គាល់នេះ មិនមែនស្គាល់ដូចស្គាល់គោក្របីនោះទេ គឺស្គាល់ចរិត ស្គាល់កិរិយាមារយាទ ស្គាល់ការចូលចិត្ត ស្គាល់សុខ ស្គាល់ទុក្ខរបស់អ្នកម្ខាងទៀត ។ ម្យ៉ាងទៀត បើយើងស្គាល់ ហើយចំណាំបានថា ស្វាមីភរិយារបស់យើងធ្លាប់មានការប្រព្រឹត្តិយ៉ាងនេះ១ លុះដល់យើងឃើញប្លែកខុសពីប្រក្រតី ក៏នឹងអាចឱ្យយើងពិចារណា ឬតាមមើលថាមានអ្វីកើតឡើងចំពោះស្វាមីខ្លួន ហើយអាចនឹងការពារបានចំពោះអន្តរាយណាមួយ ដែលនឹងកើតឡើងចំពោះដៃគូខ្លួនជាមិនខាន

ឬបើមានរឿងកើតឡើងនោះ ក៏នឹងមិនធ្ងន់ធ្ងរពេក ។

នៅក្នុងជាតក រឿងកុណាលជាតក ( ជាតករឿងតាវៅ ) បាននិយាយពីលក្ខណៈរបស់ភរិយាមិនល្អ ទុកជាច្រើនប្រការ សំរាប់ឱ្យស្វាមីពិនិត្យ និងធ្វើការប្រុងប្រយ័ត្ន ។

WAT KHEMARARATANARAM

# លក្ខណៈដែលអាចសង្ស័យថាស្រីនឹងខូច

មានលក្ខណៈ ៩ យ៉ាង ដែលស្រីពានបញ្ហាតែងតែប្រព្រឹត្តដោយភ្លេចខ្លួនថាមានគេកំពុងមើល ។ បុរសជាស្វាមី កាលបើឃើញហើយ គប្បីតាមដានពិនិត្យមើល និងការពារទុកពីដំបូងឱ្យហើយ ៖

១. នាងតែងធ្វើដំណើរទៅកាន់សួនច្បារជាញឹកញាប់ បើទោះជាមិនមែនពេលដែលគួរនឹងទៅក៏ដោយ ។

២. នាងតែងធ្វើដំណើរទៅកាន់សួនឧទ្យានធំៗជាញឹកញាប់ ។ ឧទ្យានបានដល់ព្រៃធំៗ ដែលគេទុកឱ្យដល់ជនដើរលេងលំហែចិត្ត ។

៣. នាងតែងទៅកាន់កំពង់ទឹក មានអូរ ស្ទឹងជារឿយៗ ។

៤. នាងតែងទៅកាន់ផ្ទះញាតិរបស់ខ្លួនណាមួយជារឿយៗ ។

៥. នាងតែងទៅកាន់ផ្ទះអ្នកដទៃជារឿយៗ ។

៦. គិតតែពីឆ្លុះកញ្ចក់ផ្ទៀងផ្ទង់ ថែទាំសំពត់អាវមិនឱ្យបាក់ភ្លឺ និងតែងខ្លួនសំអាងខ្លួនជាប្រក្រតី គ្រប់ពេលវេលាខុសពីធម្មតា និងពេលគួរមិនគួរ ។

៧. សេពនូវសុរាគ្រឿងស្រវឹងប្លែកពីធម្មតា និងប្រក្រតី ។

៨. ចេះតែលបមើល ចោលកន្ទុយភ្នែក ផ្ទៀងផ្ទង់ទៅកាន់ប្រុសដទៃមិនដាក់ភ្នែក និងមិនប្រក្រតី ។

៩. ឈរបង្ហាញខ្លួននៅនឹងមាត់ទ្វារ ឬបង្អួច រាល់ពេលជាប្រក្រតី ។

ចំណុចទាំង ៩ នេះ មិនមែនបានន័យថា ត្រាប់តែឃើញធ្វើ ក៏ចាប់សង្ស័យនោះទេ លុះត្រាតែឃើញប្លែកញឹកញាប់ហួសពីការធម្មតា ដែលនាងធ្លាប់

ប្រព្រឹត្ត ។ ព្រឹត្តិកម្មទាំងនេះ ក៏អាចឱ្យមាតា បិតា សង្កេតមើលដល់កូនស្រីរបស់ខ្លួនបានដែរ ដើម្បីជៀសវាងការភ្លាំងភ្លាត់ដោយការប្រមាទ ឬ នឹងមិនដល់ ។

## លក្ខណៈ ៤០ របស់ស្រីដែលចង់ ចែចង់បុរស

លក្ខណៈ ៤០ យ៉ាងនេះ ជួនកាលជាដំណើរដែលនាងធ្វើដើម្បីទាក់ទាញបុរសឱ្យងាក ឬយកចិត្តទុកដាក់សម្លឹងមើលនាងតែប៉ុណ្ណោះ តែត្រង់នេះលោកទុកជាខុសពីលក្ខណៈស្រីគ្រប់លក្ខណ៍ដែរ ។

១. កាច់រាង

២. បន្ទន់ខ្លួន

៣. កែក្រាយ

៤. ក្រអិមក្រអៀប

៥. យកក្រចកផ្ចាត់ក្រចក

៦. យកជើងផ្ចាត់ជើង

៧. យកឈើគូសដីលេង

៨. លើកបីកូនក្មេងយកមកពរនិប

៩. ឱ្យកូនក្មេងលើកខ្លួនលេង

១០. លេងបន្លែងនឹងក្មេង

១១. ឱ្យកូនក្មេងលេងនឹងខ្លួន

១២. ថើបកូនក្មេង

១៣. ញ៉ាំងឱ្យកូនក្មេងថើបខ្លួន

១៤. ញុំាម្ហូបចំណីលេង
១៥. ញុំាងឱ្យកូនក្មេងញុំា
១៦. ឱ្យវត្ថុទៅកូនក្មេងលេង
១៧. សុំល្អងលោមយកមកវិញ
១៨. ធ្វើត្រាប់តាមកូនក្មេងដែលវាធ្វើកាយវិការ
១៩. និយាយឱ្យឮខ្លាំងៗ
២០. និយាយតិចៗ
២១. និយាយបើកចំហមាត់
២២. និយាយលាក់លៀម
២៣. ធ្វើនូវសញ្ញាដោយអាការៈរាំ ច្រៀង ប្រគំ
យំរៀបរាប់ ម៉ិកម៉ក់ ស្អិតស្អាង
២៤. សើចក្អាកក្អាយ
២៥. សម្លឹងសម្លក់
២៦. ញាក់ចង្កេះ
២៧. ញុំាងទ្រព្យកំបាំងឱ្យកំរើក
២៨. បើកបង្ហាញភ្លៅ
២៩. បិទភ្លៅទៅវិញ
៣០. បង្ហាញដោះ
៣១. បង្ហាញក្លៀក
៣២. បង្ហាញផ្ចិត

៣៣. មិចវ័ណ្ណក

៣៤. ញាក់ចិញ្ចើម

៣៥. ខាំបបូរមាត់

៣៦. លៀនអណ្ដាត

៣៧. ឲ្យគស់ពត់

៣៨. ស្លៀកសំពត់វិញ

៣៩. រំសាយសក់

៤០. បួងសក់វិញ

## លក្ខណៈភរិយាដែលខូច ឬប្រុងនឹងខូច ២៦ យ៉ាង

១. ស្រីសរសើរការនៅឃ្លាតគ្នាអំពីប្ដី

២. មិននឹកស្រណោះរឭកប្ដី ដែលនៅឃ្លាតគ្នា

៣. មិនត្រេកអរនឹងប្ដីដែលទើបមកដល់

៤. ពោលទោសពីប្ដីខ្លួន ប្រឆ្មុស្តនឹងប្ដី

៥. មិននិយាយសរសើគុណពីប្ដីខ្លួន

៦. ប្រព្រឹត្តនូវសេចក្ដីវិនាសដល់ប្ដី

៧. មិនប្រព្រឹត្តសេចក្ដីចំរើនដល់ប្ដី

៨. ធ្វើអំពើដែលមិនគួរធ្វើដល់ប្ដី

៩. មិនធ្វើអំពើដែលគួរធ្វើដល់ប្ដី

១០. ពេលដេកស្លៀកសំពត់ខោអាវជាប់មាំខ្លួន

១១. លបដេកមុនប្តី
១២. ដេកបម្រះនឿយណាយ
១៣. បង្កជម្លោះ
១៤. ផឹកផ្តើមចេញវែងដូចជារងទុក្ខ
១៥. ទៅកាន់បង្អន់ និងបន្ទប់ទឹកជាញយៗ
១៦. ប្រព្រឹត្តខឹងមាស់ មិនធ្វើការងារ
១៧. ឮសំឡេងប្រុសឯទៀត ខំផ្ទៀងស្តាប់
១៨. ជាស្រីបំផ្លាញទ្រព្យរបស់ប្តីដែលរកបានមក
១៩. ធ្វើនូវសន្តវកិច្ចនឹងប្រុសទាំងឡាយដែលស្និទ្ធស្នាល
២០. បានតែខាងជើងចេញដើរ
២១.ដើរលេងរឿយៗក្នុងពេលវេលាយប់
២២. ប្រព្រឹត្តកន្លងចិត្តប្តី
២៣. មិនគោរពប្តី
២៤. មានចិត្តគំនិតខូចកាច
២៥. ឈរទៀបមាត់ទ្វារញយៗ
២៦. បង្ហាញក្លៀក រាងកាយ ដោះ ដើរទៅកាន់ទិសផ្សេងៗ
ហើយក្រឡេកមើល ។

## ៤. ការសង្គ្រោះរបស់ស្វាមីចំពោះភរិយា

ក្នុងឋានៈជាស្វាមី លោកបានចែងធម្មៈ ៥ ប្រការ សំរាប់អនុវត្តន៍ចំពោះ

ភរិយារបស់ខ្លួនគឺ :

១. រាប់អាន លើកមុខភរិយា ថាជាភរិយារបស់ខ្លួន ។ ត្រង់នេះ យើងធ្លាប់ឮហើយថា មានប្រុសខ្លះ ពេលគេសួរថាដើរជាមួយនរណា ក៏ប្រាប់គេថាជាប្អូន ជាបង ឬជាអ្នកបំរើ ត្លុកម៉ាកខ្លួនទៅវិញ ដែលជាការធ្វើឱ្យភរិយាខ្លួនអន់ចិត្ត និងខ្មាសគេជាខ្លាំង និងជាការនាំទៅរកការប្រេះឆា ឈ្លោះប្រកែកគ្នាជាញឹកញាប់ ។

២. មិនមើលងាយភរិយារបស់ខ្លួនដោយកាយ និងវាចា ។ គឺស្វាមីមិនគួរវាយតប់ភរិយា ឬជេរស្តី ប្រមាថកាតមាន តិះដៀលដោយផរុសវាចានោះឡើយ តែអ្នកនិយាយស្តីដោយគោរព និងផ្អែមល្ហែម ។

៣. មិនប្រព្រឹត្តក្បត់ចិត្តភរិយារបស់ខ្លួនទៅមានស្រីថ្មី ប្រពន្ធថ្មីឡើយ ព្រោះធម្មតាចិត្តស្រី មិនដែលមាននរណាសប្បាយចិត្តទេ ពេលដែលស្វាមីខ្លួនទៅលេង ឬមានស្រីថ្មី ។ យើងជាប្រុសគួរគិតថា ចុះបើភរិយាយើងមានប្រុសថ្មី តើយើងសប្បាយចិត្តទេ ?

៤. ប្រគល់ភារកិច្ចជាធំក្នុងផ្ទះឱ្យទៅភរិយា ដូចជាការមើលទុកដាក់ទ្រព្យសម្បត្តិ រៀបចំតុបតែង មើលការខុសត្រូវក្នុងផ្ទះជាដើម ។ ព្រោះខ្មែរមានពាក្យស្លោកមួយថា : " *ស្រី១គេចេះអស់ហោះនៅឡើយ អស់ហើយទៅបន្តិច* " ។

៥. ផ្តល់គ្រឿងអលង្ការឱ្យដល់ភរិយារបស់ខ្លួនតាមកាល និងតាមអត្តភាព " ដូចជាអភិសម្ពន្ធភាពនៃអាពាហ៍ពិពាហ៍ ចំណុចទី៨ ដែរ " ។

ស្វាមីក៏ត្រូវដឹងផងដែរនូវសេចក្តីទុក្ខរបស់ភរិយាខ្លួន ក្នុងឋានៈជាស្រី និងជាភេទទន់ខ្សោយ ដែលមានអ្វី១ខុសពីបុរសភេទ ដូចតទៅ :

១. ភរិយាតែងមានសេចក្តីទុក្ខ ព្រោះការព្រាត់ពីបង ប្អូន ម្តាយ ឪពុក

ស្រុកកំណើតមកនៅនឹងស្វាមី ទីកន្លែងថ្មី មនុស្សចម្លែកថ្មី ដែលធ្វើឱ្យគ្នាមិនស្រណុកចិត្ត ឬខ្លាចៗ ធ្វើនេះមិនសម ធ្វើនោះមិនសម ព្រោះប្លែកកន្លែង ។ ស្វាមីត្រូវដឹងនូវវិបត្តិផ្លូវចិត្តនេះ និងព្យាយាមសម្រួលការឱ្យភរិយារបស់ខ្លួនបានស្រួលផង ។

២. ស្ត្រីតែងមានសេចក្តីទុក្ខទាំងខាងផ្លូវកាយ និងផ្លូវចិត្ត នៅពេលចុងខែ ជាពេលដែលនាងមានឈាមរដូវ ។ ក្នុងរដូវកាលនេះ នឹងធ្វើឱ្យឈឺចុកចាប់ដល់ពោះ ឬឈឺក្បាល ឬទៅជាខ្យល់ចាប់ បើជួនជាឈាមរដូវដើរមិនទៀងផង ឬមានធ្លាក់សផងនោះ ក៏នឹងរឹតតែជាបញ្ហាឡើង ។ ម្យ៉ាងទៀត ក្នុងរដូវកាលនេះ អារម្មណ៍របស់ស្ត្រី ក៏មានភាពមិននឹងន ឆាប់ខឹង មិនសប្បាយចិត្តជាដើម ។ ស្វាមីត្រូវយល់ពីបញ្ហានេះ ជួយរួមចំណែកក្នុងការឈឺចាប់ផងដែរ និងមិនធ្វើអ្វីដែលជាការលំបាកដល់នាង ឬបើមិនស្រួល ក៏ប្រញាប់ប្រញាល់រកថ្នាំសង្កូវព្យាបាល ។

៣. ភរិយាតែងមានសេចក្តីទុក្ខ ពេលដែលនាងមានគភ៌ ។ ការមានគភ៌ជាការមួយដែលនាងជាភរិយាទាំងអៀនខ្មាស ទាំងត្រូវទ្រាំថែមទៀតនូវទម្ងន់ដែលកូនក្នុងផ្ទៃបន្ថែមជារៀងរាល់ថ្ងៃ ។ នាងមិនអាចឈរបានស្រួល ដើរបានស្រួល ឬប្រកបកិច្ចការបានស្រួល ដូចកាលដែលមិនមានកូនក្នុងផ្ទៃនោះទេ ។ ទាំងចំណីអាហារក៏ដូចគ្នាដែរ មានស្រីខ្លះរហូតដល់ចាញ់កូន ឬនឹកចង់ចំណីផ្តេសផ្តាសដែលរកមិនបានក៏មាន ។ ក្នុងសម័យពុទ្ធកាល មហេសីព្រះបាទពិម្ពិសារ ពេលដែលព្រះនាងទ្រង់ព្រះគភ៌ កូនក្នុងព្រះឧទរបានបណ្តាលឱ្យព្រះនាងចង់តែសោយព្រះលោហិតរបស់ស្វាមីរហូតទាល់តែស្គមស្គាំង ព្រោះពុំហ៊ានប្រាប់ ។ លុះក្រោយមក ព្រះបាទពិម្ពិសារ លោកចេះតែជម្រិតសួរ ព្រះនាងទ្រាំមិនបានក៏ទូលប្រាប់ទៅ ។ ព្រះបាទពិម្ពិសារ លោកក៏យកព្រះខ័នមកអារព្រះហស្តសម្រក់ព្រះលោហិតឱ្យមហេសីសោយ ។

គ្រាន់តែសោយហើយ ព្រះនាងក៏ឈប់ឃ្លាន ហើយក៏ជាចាប់ពីថ្ងៃនោះទៅ ។ ពេលមានគភ៌លំបាកណាស់ ដូច្នេះ ស្វាមីត្រូវយល់ទុក្ខធុរៈរបស់ភរិយាឱ្យ មែនទែន ។

៤. ភរិយាតែងមានសេចក្តីទុក្ខ ព្រោះត្រូវបំរើសេចក្តីត្រូវការខាងភេទរបស់ស្វាមី ។ ចំណុចត្រង់នេះ សំខាន់ណាស់ចំពោះអ្នកជាស្វាមីដែលត្រូវយល់ទុក្ខធុរៈរបស់ភរិយាខ្លួន និងអារម្មណ៍របស់ភរិយាខ្លួនដែរ មិនមែនចេះតែត្រូវការពេលណា ផ្មើរណា ក៏ចេះតែប្រព្រឹត្តសេព អាងតែគ្នាមិនហ៊ានប្រកែកនោះទេ ។ ពេលមានរដូវ ពេលមានគភ៌ ពេលប្រសូតបុត្រ សុទ្ធតែជារយៈពេលដែលស្ត្រីគ្នាមានបញ្ហាទាំងផ្លូវកាយ និងចិត្ត ដូច្នេះ ស្វាមីគួរចេះតម ឬវៀរលើកលែងខ្លះ ។ ពេលមានជំងឺក៏ជាពេលដែលយើងត្រូវយល់ចិត្តភរិយាដែរ ។ ត្រង់នេះធ្វើឱ្យយើងគិតដល់ឧបោសថសីល ឬសីល ៨ ដែលព្រះសម្មាសម្ពុទ្ធលោកបញ្ញត្ត ដោយឱ្យអ្នកសមាទានចេះវៀរចាក ឬខាន តមខ្លះ ដើម្បីកុំឱ្យមានភារៈធ្ងន់ពេកដល់ភរិយា ស្វាមីរបស់ខ្លួនដែលយើងគួរតែសមាទាន ព្រោះក្នុង ១ ខែ យើងមានតែ ៤ ដងប៉ុណ្ណោះ ។

៥. ភរិយាតែងមានសេចក្តីទុក្ខ ពេលដែលនាងឆ្លងទន្លេប្រសូតបុត្រ ។ ឆ្លងទន្លេជាពាក្យដែលប្រើសម្រាប់ពេលប្រសូតបុត្រ ព្រោះមានគ្រោះថ្នាក់ដូចឆ្លងទន្លេអញ្ចឹងដែរ ។ ស្វាមីគប្បីនៅថែទាំ និងជាកម្លាំងចិត្តដល់នាងនូវគ្រប់កិច្ចការទាំងពួង ជាពិសេស បើនាងមានការមិនសប្បាយចិត្ត ឬធ្វើការធ្ងន់ អាចនឹងឱ្យទៅជាធាស់ស្ពមរីងរៃ ដាច់ទឹកដោះ ឬដល់ជាត់បង់ជីវិតក៏មានដែរ ។ ស្វាមីគប្បីសាកសួរចាស់ៗឱ្យបានច្រើនក្នុងរឿងនេះផងចុះ ។

សេចក្តីដែលខ្ញុំរៀបរាប់ពង្រីកអត្ថន័យលើពុទ្ធវចនៈព្រះសម្មាសម្ពុទ្ធនេះ

មិនអាចគណនានាឱ្យអស់នូវសេចក្ដីពិតរបស់ស្រី ឬភរិយាបានឡើយ ស្វាមីគប្បីសាកសួរពិនិត្យបន្ថែមទៀតទៅចុះ ។ ខ្ញុំគ្រាន់តែចង់និយាយថា " *ពេលគេមានទុក្ខ បើយើងធ្វើឱ្យគេបាត់កើតទុក្ខ គេប្រាកដជាស្រឡាញ់ គោរពយើងជាមិនខាន* " ។

ព្រះបាទសម្ដេចព្រះហរិរក្សរាមា ឥស្សរាធិបតី ព្រះបរមកោដ្ឋ ព្រះអង្គផ្លូវទ្រង់បាននិពន្ធជាកំណាព្យស្ដីពីនាទីរបស់ស្វាមី ដូចតទៅ :

*កតមេហិ បញ្ចគតិ ‒ ហិ សាមិកា ភរិយាស ‒ ង្គហាតព្វា* ប្រែតាមអត្ថាធិប្បាយបាលី :

ថាប្រុសឯណា នឹងមានភរិយា លោកឱ្យចេះក្ដី ទាំងប្រាំចំពោះ សង្គ្រោះចិត្តស្រី ប្រពន្ធប្រក្រតី ដូចធម៌សម្ដែង ។ បើប្ដីឯណា ពុំកាន់កិរិយា ទាំងប្រាំនេះចែងហៅប្ដីទុរជន ជួរពាន់ក្រៃលែង ចេះតែកំហែង ចិត្តប្រពន្ធពិត ។ បើប្ដីកាន់ច្បាប់ទាំងប្រាំនេះខ្ជាប់ ហៅប្ដីសុចរិត បម្រុងភរិយា ដោយនាព្រមក្រឹត្យ ប្រសើរពេកពិតឥតអ្វីផ្ទឹមឡើយ ។ អស់ប្រុសទាំងឡាយ ចូរចាំអធិប្បាយ ច្បាប់នេះជាត្រើយ ទុកគ្រប់ប្រុសប្រាណ កុំមានកន្ដើយ មានប្រពន្ធហើយ ជាសុខសម្រាន្ត ។

មួយគឺហៅប្ដី ឱ្យប្រើស្រដី នឹងប្រពន្ធមាន ពាក្យទន់ពិរោះ ស្មើស្មោះដោយក្សាន្ត សរសើររាប់អាន តាមស័ព្ទវាចា ។ មួយគឺប្រពន្ធ ខុសឆ្គងស្រាលធ្ងន់កុំជេរផ្ដាសា ទាត់ធាក់ជេរលដី ដូចខ្ញុំអាត្មា កុំស្ដីដើមថា ឱ្យឮសាយសព្ទ ។ មួយគឺបានធន ប្រគល់ប្រពន្ធ ទុកដាក់រណ្ដាប់ ទាំងគ្រឿងអាហារ ជាការស្រីផ្ទាប់ រៀបចំសម្រាប់ ថែទាំរក្សា ។ មួយគឺកុំផ្ទង់ កុំខំតែប ‒ ង្កើតកូនហើយថា ប្រពន្ធសុខចិត្តឱ្យគិតប្រាថ្នា រួសរកទ្រព្យា សម្រាប់ឱ្យផង ។ មួយគឺឱ្យចាប់ ស្រឡាញ់ឱ្យខ្ជាប់ កុំជិនណាយពោង បើមានប្រពន្ធ ទៀតកុំប៉ុនប៉ង ស្រឡាញ់ស្នេហ៍ស្នង ឱ្យស្មើមុខឡើយ

សម្តែងសេចក្តី គ្រប់ប្រាំវិធី ចែងចប់ស្រេចហើយ ឱ្យអស់ប្រុសផង ចាំចងជាត្រើយ ផ្ចង់កុំកន្តើយ ចោលច្បាប់បុរាណ ។ បើប្រុសឯណា ពុំផ្ចង់ចិន្តា ដូចធម៌ប្បន្នាន នៅនឹងភរិយា គ្មានជាសុខសាន្ត ហឹនហោចធនធាន ទាស់ទែងលែងគ្នា ។ ឯវិស័យចិត្ត អស់ស្រីផងពិត មានប្តីប្រាថ្នា អំពើទាំងប្រាំ នេះចាំចិន្តា គ្រប់ចិត្តភរិយា នៅនាលោកិយ ។ បើខ្វះអំពើ ណាមួយហើយតើ ប្រពន្ធជាប្តី ចិត្តពុំត្រូវត្រង់ ពុំគង់មេត្រី ត្អូចចិត្តស្វាមី អាក់អន់ពុំស្មោះ ។ លោកឱ្យប្រុសផង គន់គិតស្ងួនត្រង ផ្ចង់ផ្ចិតសង្គ្រោះ ប្រពន្ធឱ្យពិត ដោយក្រឹត្យប្រាំនោះ ប្រពន្ធក៏ស្មោះ ចិត្តចូលរួមឯង ។ កុំគិតតែយក ប្រពន្ធបានមក គ្រាន់ឱបប្រលែង បង្កើតតែកូន សោះសូន្យធនផែង លោកឱ្យគិតក្រែង ជំនៀវលនិន្ទា ។ ធម្មតាជាប្តី បានទ្រព្យធនអ្វី ឬយសសក្តា តែងនៅសុខសឹង ទីពឹងផងគ្នា ព្រោះដ្បិតភរិយា កាន់ក្តីសុចរិត ។ អំពើច្នេះហោង ឱ្យអស់ប្រុសផង ចងចាំក្នុងចិត្ត តាមធម៌ប្បន្នាន គ្រប់ប្រាណប្រុសពិត ទុកជាក្រមក្រឹត្យ ជាច្បាប់តទៅ ។ អង្គអញ្ញរចនា សេចក្តីកាព្យ តាមច្បាប់ទុកនៅ ក្នុងព្រះបាលី សេចក្តីជ្រាលជ្រៅ ពុំហ៊ានសៅដៅ លើកលេងងាយដាយ ។ ឧស្សាហ៍ខំប្រុង ប្រែរករើសក្នុង គម្ពីរនិកាយ អដ្ឋកថា ដីកាបរិយាយ និបាតទាំងឡាយ មកផ្សំស្រដី ។ ជាច្បាប់ទុកត ដំណឹងតំណា ដំណើរស្ត្រី ឱ្យជាក់ប្រាកដ ដោយបទបាលី គ្រាន់អស់ប្រុសស្រី រើសរៀនរកផ្លូវ ។ ច្បាប់នេះប្រសើរ ដំណឹងដំណើរ ទំនងនេះត្រូវ ជាច្បាប់ប្រាកដ ដោយបទត្រឹមត្រូវ គួរយើងឥឡូវ ប្រព្រឹត្តរក្សា ។ គួររៀនឱ្យស្ទាត់ ឱ្យចាំរត់មាត់ ដាក់ក្នុងចិន្តា គ្រាន់នឹងប្រិតប្រៀន បង្រៀនអាត្មា តាមដោយគាថា នេះឯងតទៅ ។ ចែងចប់អភិប្រាយ ដោយអត្ថបរិយាយ សូរេចថ្ងៃសៅរ៍ ប្រាំបីរោចឯ នាខែមាឃនៅ ឆ្នាំរកាត្រូវ ឧត្តស័កស្រេចហោង ។

# ៦- នាទីភរិយាចំពោះស្វាមី

យើងបានដឹង និងយល់អំពីនាទីខាងស្វាមី កិច្ចការដែលស្វាមីត្រូវដឹងពីភរិយា និងចំណុចខ្សោយរបស់បុរសជាស្វាមីហើយ ។ ឥឡូវនេះ យើងងាកមកមើលមកដឹង យល់ពីខាងនាងដែលជាភរិយាម្តង តើមានអ្វីខ្លះដែលគួរសិក្សា និងអនុវត្ត ?

## ១. នាងជាភរិយាប្រភេទណា ?

ភរិយាមាន ៧ ប្រភេទ ដូចជាបុរសដែរគឺ ភរិយាដូចពេជ្ឈឃាត ភរិយាដូចចោរ ភរិយាដូចមិត្តភក្តិ និងភរិយាដូចទាសី ។ ឯសេចក្តីអធិប្បាយ ក៏មានន័យដូចស្វាមី ៧ ជំពូកដែរ ដោយគ្រាន់តែដូរពីស្វាមី មកជាភរិយាតែប៉ុណ្ណោះ ។

ដើម្បីជាការថែរក្សាកេរ្តិ៍ដំណែលរបស់បុព្វបុរសខ្មែរ ខ្ញុំសូមលើកយកកំណាព្យរបស់ព្រះបាទសម្តេចព្រះហរិរក្សរាមា ឥស្សរាធិបតី គ្រះបរមកោដ្ឋ " ព្រះអង្គដួង " ដែលទ្រង់បាននិពន្ធពីភរិយា ៧ ជំពូក មកជូនអ្នកអាន ដូចតទៅ :

ខ្លួយសោតព្រះពុទ្ធ ទេស្នាចំពុត ថាវិភរិយា មានប្រាំពីរស្មោះ ប្អូននោះចិត្តជា បីនោះមោហោ ចិត្តខ្លួចងាយដាយ ។ ឯប្រពន្ធជា ឯកឈ្មោះមាតា ភរិយាដូចម្តាយឈឺគ្នាយកខ្លួន វែងសួនមិនណាយ មិនទឹករសាយ ចិត្តចាំអាណិត ។ កូនទុក្ខទោសម្តេច ខ្សត់ក្រច្រើនតិច ខឹងខុសខ្លួចចិត្ត ព្រាត់ប្រាសឃ្លាតឈង់ ពុំបង់បែងចិត្ត គង់ចាំចិត្តគិត ឈឺគ្នាលកូនស្មោះ ។ ប្រពន្ធណាគាប់ ឈឺគ្នាលប្តីខ្ជាប់ ចិត្តចាំកាន់កោះដូចម្តាយស្រឡាញ់ កូនពេញពីពោះ ហៅប្រពន្ធនោះ ថ្លៃឥតផ្ទឹមផល់ ។ ប្រពន្ធជាទី

ឈ្មោះហៅទាសី ភរិយាដូចគល់ ខ្ញុំនឹងអម្ចាស់ ប្រើណាស់ខ្វាយខ្វល់ អាចអត់ទប់ទល់ មធ្ងន់បម្រើ ។ មិនមានចំនេរ ទោះម្ចាស់វាយជេរ អត់ឱនសារពើ តាមតែបង្គាប់ ប្រញាប់ចង់ធ្វើ ចិត្តពុំសើរើ ចៀសវៀងក្រោធា ។ ប្រពន្ធណាអត់ ឱនអង្គកំណត់ ខ្លាចប្ដីអាត្មា ដូចខ្ញុំនឹងម្ចាស់ ខ្លាចណាស់ធានា ប្រពន្ធនោះជា ប្រសើរសុខសួន្ស ។ ប្រពន្ធជាត្រី ឈ្មោះភគិនី ភរិយាដូចប្អូន ស្រឡាញ់បងពិត លំអិតលំអន ទទួលជំនូន មានពាក្យពីបង ។ ផ្ដាច់ផ្ដួលតែមួយ នឹងចងជាត្រួយ ចិត្តចាំចំណង ពំនាក់ពំនឹង ពាក់ពឹងប៉ុនប៉ង តែនឹងអង្គបង ឥតមែមីមៃ ។ ប្រពន្ធណាចួល នឹងប្ដីមួយមួល ចិត្តជាប់អាល័យ ដូចប្អូននឹងបង ចាំចងអាស្រ័យ ប្រពន្ធនោះថ្លៃ មធ្យមពេកពិត ។ ប្រពន្ធចត្វា ឈ្មោះហៅសខា ភរិយាដូចមិត្ត សម្លាញ់ស្រឡាញ់ អស់អញ្ចពេកពិត ស្មើខ្លួនស្មើចិត្ត ស្មីគ្រស្មោះចិន្ដា ។ បើមិត្តទៅបាត់ ស្ងប់ស្ងួនមុខមាត់ ទុក្ខទន់ទយា ឃើញមុខមកបាន ចិត្តក្សាន្តសោះសា ស្រស់ស្រួលភក្ត្រា និរទុក្ខសោកសៅ ។ ប្រពន្ធណាចិត្ត ស្រឡាញ់ប្ដីពិត គ្មានក្នុងគ្មានក្រៅ ដូចមិត្តនិងមិត្ត ចងមិត្តជាប់នៅ ប្រពន្ធនោះហៅ ឧត្តមក្រមាន ។ សម្ដែងភរិយា ទាំងប្អូនសឹងជា ក្រស្រីធ្វើបាន បើស្រីណាគិត ផ្គង់ចិត្តសន្ដាន ស្រលាញ់ប្ដីប្រាណ ដូចធមិមេស្នា ។ លោកថាស្រីនោះ ឮកេរ្តិ៍ពីរោះ ទូទៅនានា បើអស់ជីវិត ទៅឋិតសួគ៌ា ចៀសចាកចតុរា-បាយបាបទុក្ខភ័យ ។ ប្រពន្ធពុំជា ឈ្មោះវធកា ភរិយាដូចនៃ សត្រូវចាំចង ពោសផងសព្វថ្ងៃ ប្រពន្ធចង្រៃ ប្ដីមានតែទុក្ខ ។ បើប្ដីខុសចិត្ត វាគ្មានអាណិត ខេរខឹងច្រអូក ចាំចងទោសប្ដី ស្រដីកកកុក ឱ្យមាត់ឱ្យមុខ វាតវាងភ្លោះភ្លើយ ។ សុខទុក្ខសាំទាំ វាមើលចំណាំ នៅស្ងៀមព្រងើយ ពុំជួយទុក្ខភ័យ ដោះដៃកន្តើយ ស្លាប់ដោយរស់ដោយ គ្មានចិត្តមេត្រី ។ ចៅរីភរិយា ប្រពន្ធពុំជា លបល្មចទ្រព្យប្ដី គ្មានចិត្តករុណា មេត្តាប្រណី របស់ទ្រព្យ

អ្វី លក់ចាយអស់ខ្លួន ។ អយ្យាភរិយា ប្រពន្ធពុំជា តម្កើងតែខ្លួន ចេះតែប្រើប្ដី ឥតបីមានស្ងួន ធ្វើឫកណាំខ្លួន ទុកប្ដីដូចខ្ញុំ ។ ប្រពន្ធទាំងបី ធ្លាក់ទៅអវិចី រងទុក្ខជំណាំ ក្នុងខ្លះភ្លើងក្ដៅ យូរនៅក្រៀមក្រំ ព្រោះចិត្តខ្លួនធំ ជាងប្ដីអាត្មា ។ ឯប្រពន្ធបួន មុខនោះគួរស្ងួន យកជាភរិយា នឹងកើតរបស់ កេរ្តិ៍យសសក្ដា ថ្កើងវង្សពង្សា សោយសុខផេរបិត ។ សម្ដែងបរិយាយ ភរិយាទាំងឡាយ ប្រាំពីរចរិត ទាំងថ្លៃទាំងជា ពណ៌នាពោលពិត ចែងចងពិនិត្យ តាមអត្ថគាថា ។

## ២. កម្លាំងរបស់ស្ត្រី

ខ្ញុំបាននិយាយពីចំណុចខ្សោយរបស់បុរសហើយ បើមិនបាននិយាយពីចំណុចខ្សោយរបស់ស្រីនោះ ក៏ឃើញថាមិនសមគួរឡើយ ។ ព្រះដ៏មានព្រះភាគបានសំដែងថា ស្រីមានកម្លាំងក្រៅ ៥ យ៉ាង សំរាប់ឱ្យសំរេចកិច្ចការពី ៖ កម្លាំងរូប, កម្លាំងទ្រព្យ, កម្លាំងញាតិ, កម្លាំងបុត្រ, និងកម្លាំងសីល ។

១. *កម្លាំងរូប* ៖ កម្លាំងនេះសឹងថាពុំបាច់ពន្យល់ឡើយ ព្រោះថាស្រីអាចប្រើរបស់ខ្លួនបញ្ជាប្រើ និងសម្លាប់បុរសបានងាយណាស់ ។ ដែលរាប់បញ្ចូលក្នុងពាក្យថារូបនេះ បានដល់ការប្រើភ្នែក, ប្រើសំឡេង, រាងកាយ និងសម្ផស្សរបស់នាងឱ្យទៅជាអាវុធនោះឯង ។ អាស្រ័យហេតុដូច្នេះឯងបានជា ព្រះសម្មាសម្ពុទ្ធលោកបានបញ្ញត្តនូវវិន័យយ៉ាងតឹងតែងចំពោះភិក្ខុសង្ឃអំពីរឿងស្រី រហូតរាប់ស្រីថាជាភ័យមួយ ក្នុងចំណោមភ័យទាំងបួនដែលអាចសម្លាប់ភិក្ខុបាន ។ លោកឱ្យឈ្មោះភ័យនេះថា " *សុសុកាភ័យ* " ប្រែថា ភ័យមានលក្ខណៈដូចត្រីឆ្លាម អាចសម្លាប់

ដល់អ្នកធ្វេសប្រហែសបាន ។

*២. កម្លាំងទ្រព្យ :* ទ្រព្យជាកម្លាំងមួយទៀត ដែលអាចឱ្យស្រីគ្រប សង្កត់លើកម្លាំងបុរសបាន ។ ជាពិសេស សម័យឥឡូវនេះ ទ្រព្យស៊ីងតែជាកម្លាំង មួយ ដែលខ្លាំងជាងកម្លាំងរូបទៅទៀតផង ។ រូបអាក្រក់ក៏អាក្រក់ចុះ តែបើមាន ទ្រព្យហើយ គឺប្រាកដជាគេឃើញស្អាតជាមិនខាន ។

*៣. កម្លាំងញាតិ :* អ្នកដែលមានញាតិច្រើន រមែងមានទីពឹងពំនាក់ ច្រើនជាងមនុស្សកំព្រា ឬក្បាលមួយតែម្នាក់ឯង ។ ចំណុចនេះ ខ្ញុំមិនបាច់អធិប្បាយ ច្រើនទេ អ្នកអានតង់នឹងដឹង យល់ជាមិនខាន ។

*៤. កម្លាំងបុត្រ :* បើប្រៀបធៀបម្ដាយ និងឪពុក ខ្ញុំគិតថា ភាគច្រើន កូនតែងមានការជំពាក់ចិត្តជាប់ទៅម៉ែច្រើនជាងឪពុក ព្រោះបានឥទ្ធិពលពីម្ដាយ តាំង ពីក្នុងផ្ទៃរហូតដល់ធំ ។

ដូច្នេះ មិនជាការពិបាកយល់ទេ ដែលមាតាអាចពឹងកម្លាំងរបស់កូន ។ ស្វាមីដែលឃើញភរិយាខ្លួនខុសនៅនឹងមុខហើយ តាំងចិត្តថានឹងលែងលះនាង ហើយក៏មិនអាចលះលែងបាន ព្រោះជាប់ជំពាក់នឹងរឿងកូនញ៉ឹងឯង ។

*៥. កម្លាំងសីល :* គឺការប្រព្រឹត្តល្អនៅក្នុងបែបបទសីលធម៌ ក្នុងឋានៈ ជាភរិយាគ្រប់លក្ខណ៍ ទន់ភ្លន់ សុភាពរាបសារ ស្គាល់ខុស ស្គាល់ត្រូវ ទាំងនេះ រាប់ថាជាកម្លាំងរបស់ស្រីមួយផ្នែកទៀត ក្នុងការប្រកបកិច្ចការណាមួយឱ្យបាន សម្រេច ។

នៅមានកម្លាំងមួយទៀត ដែលមានអានុភាពយ៉ាងខ្លាំងក្លា អាចរុញច្រាន

កម្លាំងទាំង ៥ ដែលអធិប្បាយមកហើយនោះ ឱ្យរីតតែមានសន្ទុះឡើង ។ កម្លាំង ទុំះគឺ សេចក្ដីក្រោធនោះឯង ។ បើស្រីក្រោធហើយ ខឹងហើយ ចងគំនុំហើយ ច្រើនតែមានរឿងគគ្រឹកគគ្រេងកើតឡើងជាមិនខាន ទាំងល្អ និងអាក្រក់ ។

តែទោះជាយ៉ាងនេះក្ដី " កម្លាំងក្រោធ " នេះ ក៏ជាចំណុចខ្សោយតែមួយគត់របស់ស្រី ដែលសត្រូវទាំងឡាយអាចធ្វើឱ្យនាងវិនាសគ្រប់ប្រការបាន ។ ឈ្មោះជាសត្រូវ តែងមានគោលបំណង ៧ យ៉ាងគឺ :

១. សត្រូវមានបំណងចង់ឱ្យយើងមានសម្បុរអាក្រក់ ហ្មហ្មង,

២. សត្រូវមានបំណងចង់ឱ្យយើងគិតតែពីដេកកើតទុក្ខ,

៣. សត្រូវមានបំណងចង់ឱ្យយើងមិនបានទទួលផលប្រយោជន៍ច្រើន,

៤. សត្រូវមានបំណងចង់ឱ្យយើងមិនមានយសសក្ដិ និងខូចយសសក្ដិ,

៥. សត្រូវមានបំណងចង់ឱ្យយើងមិនមានមិត្តភក្ដិរាប់អាន,

៦. សត្រូវមានបំណងចង់ឱ្យយើងមិនបានទ្រព្យ និងឱ្យយើងវិនាសទ្រព្យ,

៧. សត្រូវមានបំណងចង់ឱ្យយើងធ្លាក់នរក ឬជាប់គុកច្រវាក់ ។

សត្រូវទាំងឡាយអាចនឹងយកជ័យជំនះលើស្រីបាន បើចេះធ្វើយ៉ាងណាឱ្យខឹងព្រឹក ខឹងល្ងាច ខឹងយប់បាន ។ លើកឧទាហរណ៍យ៉ាងងាយបំផុតគឺ បើនាងណាតាប់ខឹង រហ័សខឹង ខឹងច្រើន ខឹងជាប់ មិនយូរប៉ុន្មានទេ នាងនោះនឹងមានមុខឡើងជាំ មុខអាចម៍រុយ មុខមាត់មិនស្រស់បស់ ឯសម្បុរស្បែកក៏រាប់រស្មីដែរ ។ ក្នុងព្រះពុទ្ធសាសនា បុគ្គលដែលដាច់ខ្យល់ស្លាប់នៅពេលកំពុងមានសេចក្ដីក្រោធប្រាកដជាធ្លាក់ទៅកាន់នរកភូមិ ជាពិតប្រាកដ ។ អាស្រ័យហេតុដូច្នេះហើយទើបបានជា ព្រះជិនស្រីលោកបានឱ្យឱវាទយ៉ាងច្រើន កុំឱ្យមនុស្សរៀនក្រោធ ព្រោះ

ក្រោយនេះ ជាផ្លូវឆ្ពោះទៅរកការអន្តរាយគ្រប់បែបយ៉ាង ។

ចំពោះកម្លាំងទាំង ៥ ខាងលើវិញ នាងជាស្ត្រី ឬជាភរិយា ត្រូវដឹង ថាថា កម្លាំងនាងទាំង ៥ នេះ នឹងត្រូវញ៉ាំមថាញ់កម្លាំងបុរសតែ ១ គត់ គឺ" កម្លាំងឥស្សរិយ-យស " ។ បុរសណាដែលមានឥស្សរិយយស ឬជាអ្នកដែលមានបណ្តាសក្តិយសធំ រមែងអាចបង្ក្រាបនូវកម្លាំងរបស់ស្ត្រីទាំង ៥ បានជាពិតប្រាកដ ។

## ៣. នាទីភរិយាចំពោះស្វាមី

នាងជាភរិយា កាលបើស្វាមីបានបំពេញនាទីចំពោះខ្លួនហើយ ក៏គប្បី បំពេញនូវតួនាទី ៥ យ៉ាង ចំពោះស្វាមីខ្លួនវិញគឺ :

១. ចាត់ចែងការងារក្នុងផ្ទះដោយល្អប្រពៃ មានកិច្ចការចង្ក្រាន ផ្ទាំង មើលរៀបចំឥវ៉ាន់ ទ្រព្យសម្បត្តិ មើលខ្ញុំបំរើធ្វើការងារ ។ ល ។ រៀបចំផ្ទះសម្បែង ឱ្យរៀបរយ ស្អាតបាត មានអនាម័យ គួរចង់នៅ ដូចសុភាសិតថា " *ដំណេកដេក ជាខ្នាត ឱ្យសំអាតសំអាងជា មើបមេវតារក្សា ចំរើនសុខស្រីសួស្តី* " ។

២. សង្គ្រោះញាតិខាងស្វាមីដោយល្អ មិននិយមតែញាតិខ្លួន រាប់អាន ដោយស្មើ ។

ខ្មែរយើងមានពាក្យនិយាយថា " *ម្រាំផ្សែងភ្លើងបាន មើបម្រាំម៉ែក្មេក បាន* " ។

រឿងម៉ែក្មេកនោះ ជារឿងសំខាន់ណាស់សំរាប់សង្គមខ្មែរ ភាគច្រើន បែកព្រាត់ប្រាសគ្នា ព្រោះតែម៉ែក្មេកនេះឯង ។ ខ្ញុំបានឮចាស់ៗនិយាយថា " ប្តី ប្រពន្ធត្រូវស្រឡាញ់ ទំនុកបំរុង រក្សា ថែទាំម៉ែក្មេករបស់ខ្លួនឱ្យបានច្រើនជាងម៉ែ

បង្កើតរបស់ខ្លួននោះទើបបានសុខ បើពុំនោះទេ បន្តិចឮថា ហ៎ាមេនោះ អាហ្នឹងវាគិតតែសាច់ខាងម៉ែឪវាទេ ។ ដូច្នេះ ជារឿងសំខាន់ណាស់ដែលនាងជាភរិយាត្រូវគិតសាច់ខាងស្វាមីខ្លួនឱ្យបានដូចនឹងខាងខ្លួន ។

៣. មិនក្បត់ ចិត្តសាវ៉ា មានថ្មី ឬដោយបោចទៅ ស្វាមីតែគិតថានឹងមានថ្មី ។ ក្នុងសង្គមភូមិភាគអាស៊ី ច្រើនតែនិយាយថា " ប្រុស១ដូចមាសទឹក ១០ ធ្លាក់គប់ភក់ជ្រាំយ៉ាងណា លើកមកវិញនៅតែដដែល " ដែលជាហេតុឱ្យប្រុស១មានភរិយាបានច្រើន ឬអាចមានក្រៅបាន នៅពេលដែលស្រីត្រូវមានភក្តីភាពចំពោះស្វាមីដដែល ។ រឿងនេះពិបាកណាស់ ព្រោះជារឿងការនិយមនៅក្នុងសង្គម ថ្វីដ្បិតតែនៅក្នុងច្បាប់ត្រូវមានភរិយា ឬស្វាមីតែ ១ ក៏ដោយ ។

៤. រក្សាទ្រព្យសម្បត្តិ ដែលស្វាមីរកបានមកឱ្យគង់វង្ស មិនខ្ជះខ្ជាយ ធ្វេសប្រហែស ឬចាយវាយស្រេចតែនឹងចិត្ត ដោយពុំបានសាកសួរស្វាមី ។

ស្រីត្រូវចេះពាក្យថា " *អស់ពោះនៅឡើយ អស់ហើយនៅបន្តិច* " និងត្រូវចេះពាក្យបុរាណថា " *ខ្លែងហើរដ្បិតខ្យល់ នាយថ្កើងដ្បិតពល រក្សាឱ្យសុខទ្រព្យគង់ដ្បិតស្រី ចេះសំចៃទុក ផ្ទះធំស្រណុក ដ្បិតប្រពន្ធជា* " ។

៥. មិនខ្ជិលច្រអូសនឹងកិច្ចការទាំងពួង ដៃនៅមិនស្ងៀម ព្រោះខ្លួនមាននាទីជា " *មេផ្ទះ* " ។ សុភាសិតខ្មែរយើងពោលថា " *គោល្បឿនស៊ីកក ស្រីល្អស៊ីកក្អេ* " ។ ត្រង់នេះ មានន័យថា ស៊ីកសាវ៉ុង ឬក្បិនប៉ែកខាងក្រោយ ព្រោះត្រូវរវល់ក្នុងការត្បាញរវៃ បោសច្រាស យូរៗទៅក៏ស៊ីកខាងគូថអស់ ។

ដែលអធិប្បាយមកហើយនេះ សំរាប់គូស្វាមី ភរិយាណា ដែលនៅដាច់តែឯង បែកផ្ទះសម្បែងពីម្តាយ ឪពុក ករវែក កន្លាំងខ្លួនឯង និងសំរាប់គូស្វាមី ភរិយា

ដែលស្វាមីត្រូវមកនៅខាងភរិយា គឺនៅផ្ទះខាងស្រី ។

តាមទំនៀមទម្លាប់ខ្មែរដែលយកស្រីជាធំ ក្រោយពេលអាពាហ៍ពិពាហ៍ ខាងប្រុសច្រើនតែមកនៅខាងស្រី ។ តែនៅក្នុងទំនៀមទម្លាប់ចិន ស្រីត្រូវធ្វើដំណើរ ទៅខាងប្រុស ក៏ដូចគ្នានឹងវប្បធម៌ឥណ្ឌាដែរ ។ បើជួនជាត្រូវទៅនៅខាងស្វាមី នាង ជាស្រីគប្បីដឹង និងត្រៀមខ្លួនឱ្យបានស្រួលបួល ដើម្បីនឹងបដិបត្តិនូវកិច្ចទាំងឡាយ ដូចតទៅនេះ ៖

១. មានចេតនាល្អក្នុងការបំរើប្ដី បដិបត្តិ និយាយស្ដីដោយគោរព និង អស់ពីចិត្តពីថ្លើមដល់មាតាបិតាស្វាមី ឱ្យដូចជាមាតាបង្កើតរបស់ខ្លួន ។

២. គោរពរាប់អានដល់បុគ្គលដែលស្វាមីគោរពរាប់អាន ដូចជាគ្រូអាចារ្យ ញាតិ មិត្ត ទៅហ្មាយ និងរាក់ទាក់ទទួល ពេលដែលជននោះមកផ្ទះ ។

៣. មិនខ្ជិលច្រអូសចំពោះកិច្ចការរបស់ស្វាមី ជួយរំលែកសុខទុក្ខស្វាមី ។

៤. ស្គាល់ការគួរធ្វើ ឬមិនគួរធ្វើចំពោះមនុស្សក្នុងផ្ទះ ដូចជាកិច្ចការណា ជាកិច្ចការមាតាបិតា កិច្ចការអ្នកនៅក្រោម និងចេះបែងចែកការងារ ថាតើអ្នកណា គួរធ្វើអ្វី អ្នកណាគួរទទួលខុសត្រូវអ្វី ។

៥. រក្សាទ្រព្យសម្បត្តិដោយប្រពៃ មិនបំផ្លាញ ឬធ្វើឱ្យបាត់បង់ទៅដោយ ប្រការណាមួយ ឬមានគំនិតមិនត្រង់ កេងប្រវ័ញ្ច លួចលាក់ពីគ្រួសាររបស់ប្ដីខ្លួន ។

នៅមានឱវាទចំនួន ១០ យ៉ាងទៀត របស់ធនញ្ជ័យសេដ្ឋី ដែលផ្ដាំចំពោះ នាងវិសាខា នៅពេលដែលធ្វើដំណើរទៅនៅខាងស្វាមីនាង ជាឱវាទទាក់ទងទៅនឹង ចរិយាមារយាទរបស់ភរិយា ដែលខ្ញុំនឹងសូមនាំមកចុះជាគតិជូន ព្រោះជារបស់មាន សារសំខាន់ ហើយសង្គមខ្មែរ ក៏និយមជាពន់ពេក ។ ឱវាទនេះ ឱ្យដោយខ្លីៗ និងក្នុង

បែបជាប្រស្នាផង ។

១. *ភ្លើងក្នុងកុំនាំចេញក្រៅ* ។ ត្រង់នេះមានន័យថា រឿងរ៉ាវដែលជាសៅហ្មង ក្ដៅក្រហាយ មិនល្អ អាក្រក់ ដែលជារឿងផ្ទៃក្នុងរបស់គ្រួសារខ្លួន មាតាបិតាខ្លួន មិនត្រូវនាំចេញទៅផ្សាយ ដើរប្រាប់គេ ប្រាប់ឯង ដោយហោចទៅ សូម្បីតែសាច់ញាតិរបស់ខ្លួនឡើយ ។

២. *ភ្លើងក្រៅកុំនាំចូលក្នុង* ។ បានន័យថា រឿងណាដែលមិនល្អ មិនមានប្រយោជន៍ ជារឿងក្ដៅក្រហាយ ហើយមិនទាក់ទងទៅនឹងសាច់រឿងរបស់គ្រួសារខ្លួនទេ មិន គប្បីនាំចូលមកក្នុងផ្ទះឱ្យក្រុមគ្រួសារបានទទួលការក្ដៅក្រហាយផងដែរនោះទេ ។ បើទោះជារឿងក្ដៅក្រហាយនោះទាក់ទងទៅនឹងកេរ្តិ៍ឈ្មោះ និងផលប្រយោជន៍របស់គ្រួសារ ឬស្វាមីខ្លួនក្តី ក៏ត្រូវរកឱកាសនិយាយដែរ ដើម្បីកុំឱ្យក្ដៅទាំងរឿង ហើយក្ដៅទាំងមនុស្សទៀត ។ ខ្ញុំឃើញភរិយាខ្លះ ឃើញស្វាមីមកពីធ្វើការហត់នឿយ ឬមានរឿងទុក្ខមិនស្រួលមកដល់ផ្ទះមិនទាន់ទាំងដាក់គូថអង្គុយផង ក៏ស្រាប់តាំងនាំយករឿងអាក្រក់ រឿងក្ដៅក្រហាយទៅពិតទូលបញ្ឆេះ ធ្វើឱ្យស្វាមីដែលកំពុងស្រួលៗនោះក្ដៅក្រហាយឆេះភ្លាមមួយរំពេច ។ ត្រង់នេះមិនល្អសោះ នាងភរិយាគួរកែឱ្យបាន ។

៣. *ត្រូវឱ្យបុគ្គលដែលឱ្យ* ។ ត្រង់នេះមានន័យថា បើមាននរណាមកខ្ចីទ្រព្យ ឬឥវ៉ាន់ណាមួយពីខ្លួន ត្រូវសង្កេតចំណាំថា តើជននោះធ្លាប់ខ្ចីទៅ ឱ្យវិញ សងវិញឬទេ ឬជននោះមានអ្វីជាប្រកាន់ ដែលអាចឱ្យយើងជឿទុកចិត្តថា នឹងសងមកវិញទេ បើឃើញថានឹងសងមកវិញនោះ សឹមឱ្យខ្ចី ។ ត្រង់នេះ នាងភរិយាច្រើនភ្លាត់ណាស់ បើសិនជាជននោះចេះនិយាយផ្អែមល្ហែម បញ្ជោរ ឬធានាម៉ឺងម៉ាត់

ធ្វើមុនម៉ោះនោះ អ្នកប្រាកដជាឱ្យភ្ញាម ។ សូមឱ្យប្រយ័ត្នចំពោះមនុស្ស " *ចិត្តជាមេរ. មត្ត មាត់ជាទេវតា* " ។

*៤. មិនត្រូវឱ្យដល់បុគ្គលដែលមិនឱ្យ* ។ ត្រង់នេះមានន័យថា បើបុគ្គលនោះខ្ចីមិនដែលសងវិញទេ ឬមានដំណើរដែលមិនគួរទុកចិត្តថានឹងមិនឱ្យវិញទេនោះ មិនត្រូវឱ្យខ្ចីទេ ។

*៥. ត្រូវឱ្យដល់បុគ្គលដែលឱ្យក្តី មិនឱ្យក្តី* គឺមានអ្នកខ្លះដែលយើងត្រូវតែឱ្យដោយមិនសង្ឃឹម ឬប្រាថ្នាថាអ្នកនោះនឹងសងវិញ ឬមិនសងវិញនោះទេ ដូចជាបងប្អូនដែលយើងត្រូវជួយជាដើម ។ ន័យមួយទៀត បានដល់ការដាក់មានឱ្យដល់ស្មូមយាចកដែលមកសុំទាន ឬមកសុំការពឹងពាក់ យើងក៏ជួយទៅ រួមទាំងការធ្វើបុណ្យ ធ្វើទាន ដាក់បាត្រចំពោះព្រះសង្ឃ ដែលយើងត្រូវធ្វើជាប្រពៃណីបុណ្យរបស់យើង ។

*៦. ត្រូវអង្គុយដោយស្រួលបួល* ។ បានដល់អង្គុយដឹងខ្ពស់ទាប មានមារយាទ អង្គុយប្រយ័ត្នប្រយែងក្នុងការចេញកេរ្តិ៍ខ្មាស មិនអង្គុយសណ្តូកជើង បើចាស់ៗ ឬស្វាមីអង្គុយទាបជាងខ្លួន មិនអង្គុយច្រងេងច្រងាង យោះដៃ យោះជើង ពែនភ្នែន គងអន្លាក់ខ្លាជាដើម ។

*៧. ត្រូវបរិភោគដោយស្រួលបួល* ។ បរិភោគឱ្យស្គាល់មុនក្រោយ គួរបរិភោគមុនអ្នកណា បរិភោគក្រោយអ្នកណា បរិភោគជាមួយអ្នកណា ពេលណាគួរបរិភោគ និងមានមារយាទល្អ សុជីវធម៌ក្នុងការបរិភោគអាហារផងដែរ ។

*៨. ត្រូវដេកដោយស្រួលបួល* ។ គឺការរៀបចំដំណេកឱ្យបានសមរម្យស្រួលបួល រួមទាំងការត្រៀមវត្ថុចាំបាច់ខ្លះពេលចូលដេក កុំឱ្យពិបាកងើបដើរឆ្ងាយ

ទៅយក ។ ទំនៀមខ្មែរពីដើម មុនដេក ភរិយាត្រូវម្ចូរពារី អប់ទឹកផ្កាលដាក់ចុងជើង។ ក្នុងរឿង *សិរី ៣ ប្រការ* របស់ធម្មបាលបណ្ឌិត ដែលដោះប្រស្នាជាមួយកបិលមហា-ព្រហ្ម បានអធិប្បាយថាពេលព្រឹក សិរីនៅក្បាល ដូច្នេះត្រូវលុបមុខ, ពេលថ្ងៃ សិរីនៅទ្រូង ត្រូវលាបស្រឡាបដើមទ្រូង, ពេលល្ងាច សិរីនៅជើង ត្រូវលាងជើង មុនពេលចូលដេក ។ មិនត្រូវកន្លងខ្លួន ឬជើងប្តី ព្រោះខ្មែរប្រកាន់ថាប្រុស១ មានគ្រូបាធ្យាយកំណើតកាន់ ឬបើប្តីជាអ្នករៀនមន្តអាគម ក៏នឹងសាបអស់ ។ ត្រូវដេកនៅខាងឆ្វេងស្វាមី ឯក្បាលដំណេកគួរដាក់នៅទិសខាងត្បូង ព្រោះត្បូងប្រែថា ក្បាល ។ គួរមើលឱ្យបានច្បាស់ ពេលដេកមិនត្រូវបែរជើងទៅរកស្វាមី មាតាបិតា ឬព្រះពុទ្ធ-រូបទេ ព្រោះដូចជាយើងយកជើងទៅធាក់លោកអញ្ចឹង ។ ត្រូវដេកប្រយ័ត្នប្រយែងក្រែងលេចកេរ្តិ៍ខ្មាស ឬពេលងើបពីដេករបូតសំពត់ជាដើម ។ ខ្មែរមានទំនៀមថា " ប្រពន្ធត្រូវដេកក្រោយប្តី និងភ្ញាក់មុនប្តី " ព្រោះលោកយល់ថា ប្តីធ្វើការនឿយហត់ពីថ្ងៃហើយ ឯប្រពន្ធនៅផ្ទះ ដូច្នេះត្រូវមើលខុសត្រូវ រៀបចំទុកដាក់ចានក្បានឱ្យហើយ មើលទ្វារបង្អួចក្រែងបិទមិនជិត មើលភ្លើងក្រែងវាលឆេះ ។ ល ។ លុះដល់ភ្ញាក់ ត្រូវភ្ញាក់មុន ព្រោះម្យ៉ាងដើម្បីកុំឱ្យឃើញសភាពមិនរៀបរយរបស់សំពត់ ខោអាវខ្លួនពេលដេក និងរៀបចំអាហារពេលព្រឹកសំរាប់ស្វាមីផង ព្រមទាំងបោសច្រាសផ្ទះសម្បែងឱ្យបានស្អាតបាតស្រេចបាច់ ។ ល ។ មួយទៀត ក៏មិនគប្បីដេកកណ្តាលវាលដែរ ត្រូវមានអ្វីបិទបាំង ឬជាមីកំបាំងភ្នែកអ្នកផង ។

*ដំណេកដេកជាខ្លាត ត្រូវសំអាតសំអាងជា*
*ទើបទេវតារក្សា ចំរើនសុខស្រីសួស្តី*

WAT KHEMARARATANARAM

៩. *ត្រូវបូជាភ្លើង ឬបំរើភ្លើង* ។ ភ្លើងក្នុងទីនេះ បានដល់ស្វាមីដែលភរិយាត្រូវគោរពបំរើ ប្រណិប័តន៍ ថ្នាក់ថ្នម ទាំងការតបស្នងចំពោះសេចក្ដីត្រូវការខាងភេទផងដែរ ។ ភ្លើងនេះ បើយើងបូជា ឬបំរើមិនល្អ វានឹងអាចរលាក ឬឆេះដល់នាងជាភរិយាពិតប្រាកដ ។

១០. *ត្រូវថ្វាយបង្គំទេវតាក្នុងផ្ទះ* ។ ទេវតាក្នុងផ្ទះនេះ បានដល់មាតាបិតារបស់ខ្លួនក្ដី របស់ស្វាមីក្ដី ដែលយើងនៅជាមួយ ។ និងមួយទៀត បានដល់គ្រឿងសក្ការបូជាក្នុងផ្ទះដែលយើងជឿគោរពបូជា ។ ការបំរើមាតាបិតា គោរពប្រណិប័តន៍លោក ថ្វាយបង្គំលោក រមែងបាននូវអានិសង្ស និងសេចក្ដីសុខជាពន់ប្រមាណ ព្រោះព្រះសម្មាសម្ពុទ្ធលោកបានពុទ្ធដីកាថា ៖

> *មាតាបិតាជាព្រះព្រហ្មរបស់កូនផង ជាទេវតាដើមផង ជាគ្រូផង និងជាអាហុនេយ្យបុគ្គលរបស់កូនផង កូនណាគោរពបូជា បុណ្យរមែងកើតដល់កូនប្រុសស្រីនោះមិនដាច់ ។*

ក្រៅពីឱវាទទាំង ១០ នេះហើយ នៅមានឱវាទផ្សេងៗទៀតជាច្រើន ដែលសុទ្ធសឹងជាពាក្យទូន្មានចំពោះស្រី ដែលនឹងត្រូវមានស្វាមី ។ ជាពិសេស នៅក្នុងរឿងវិធុរបណ្ឌិតជាតក នៅពេលដែលព្រះនាងវិមលា ដែលជាមហេសីស្ដេចនាគផ្ដាំដល់បុត្រី គឺនាងឥរន្ធតី មុននឹងធ្វើដំណើរទៅជាមួយស្វាមី គឺបុណ្ណកយក្ស ។ បុព្វបណ្ឌិតយើងបានរៀបរៀងតែងពាក្យកាព្យឡើង ដាក់ឈ្មោះថា “ ច្បាប់ស្រី ” មានលំនាំជាបទភុជង្គលីលា ដែលខ្មែរយើងនិយមរាប់អានឱ្យកូនស្រីទន្ទេញណាស់ ។

WAT KHEMARARATANARAM

# ៧- នាទីចំពោះបុត្រាបុត្រី

« *បុត្តា វត្ថុ មនុស្សានំ* កូនទាំងឡាយជាអ្នកបន្តនូវពូជមនុស្ស » ។ នេះជាពុទ្ធភាសិត ដែលផ្តល់សារសំខាន់យ៉ាងខ្លាំងទៅលើបុត្រាបុត្រីរបស់យើងទាំងឡាយ ដែលជាអ្នកបន្តមរតកមនុស្សជាតិពីយើងរាល់គ្នាដែលជាគូស្វាមីភរិយា ។

កូនជាផលិតផលអនុស្សាវរីយ៍តែមួយគត់ ដែលបង្កើតឡើងដោយរួមកាយ រួមចិត្តរបស់មាតាបិតា ។ យើងអាចនិយាយថា " ជីវិតពីររួមគ្នាតែមួយ " ដែលគូស្វាមីភរិយាចំណាំនិយាយនោះ គឺបានទៅរួមគ្នាទៅពេលដែលគូស្វាមីភរិយានោះមានបុត្រឡើង ។ សារសំខាន់របស់បុត្រយ៉ាងហោចណាស់ មាន ៣ យ៉ាងធំៗគឺ ៖

- ជាអ្នកបន្តពូជមនុស្សជាតិ
- ជាអ្នកបន្តវង្សត្រកូល
- ជាចំណងសំរាប់មិនឱ្យមាតា បិតា បែកបាក់គ្នា តាមពុទ្ធវចនៈថា " *បុត្តោ គីវេ* " កូនជាចំណងក ។

មាតាបិតាព្រោះសម្លឹងឃើញនូវសារសំខាន់ ៣ យ៉ាងនេះហើយ ទើបសុខចិត្តទ្រាំទ្រនូវការលំបាកទាំងពួង ដើម្បីការលូតលាស់របស់បុត្រ ។ ផ្ទៃពោះ ជាការដែលមិនអាចជៀសបានឡើយ ដែលមាតាត្រូវទទួលខុសត្រូវចំពោះវាសនាអនាគតរបស់ខ្លួន ដែលជាផលិតផលមានជីវិតម្យ៉ាងរួមនូវជីវិត ២ មកបង្កជាជីវិតមួយ ។

ការទទួលខុសត្រូវរបស់មាតា មិនមែនត្រឹមតែមានឡើងនៅពេលដែលកូនប្រសូតហើយនោះទេ តាមពិត មានតាំងពីកូនមិនទាន់ចាប់បដិសន្ធិម្ល៉េះ ។ ហេតុអ្វីបានជាថាដូច្នេះ ព្រោះថា បើយើងពិនិត្យទៅលើបច្ច័យនៃការមានជីវិតរបស់កូន

យើងអាចបែងចែកការមានជីវិតរបស់កូន និងការទទួលខុសត្រូវរបស់មាតាបិតា ជា ៣ វយៈគឺ :

- វយៈមុនកូនមកចាប់បដិសន្ធិ,
- វយៈពេលកូនមកចំនៅក្នុងផ្ទៃរហូតដល់ថ្ងៃប្រសូត, និង
- វយៈនៃការលូតលាស់របស់កូន រហូតដល់ថ្ងៃដែលយើងលាចាកលោកលែងឃើញមុខកូននោះ ។

## ១. វយៈមុនកូនមកចាប់បដិសន្ធិ

បេក្ខជនអាពាហ៍ពិពាហ៍គួរដឹងថា បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ និងរួមរស់ក្នុងឋានៈជាស្វាមីភរិយាហើយ អ្នកនឹងមានបុត្រជាមិនខាន ។ ដូច្នេះ គួរអ្នកគិតគូរឱ្យបានម៉ែនម៉ែនដែរ ចំពោះការសម្រេចចិត្តដែលមានតែម្តងរបស់អ្នក ដែលមិនត្រឹមតែប៉ះពាល់ដល់ជីវិតរបស់អ្នកទេ តែចំពោះកូនអ្នកទៀតផង ព្រោះការរៀបអាពាហ៍ពិពាហ៍ពីក្មេងពេក តាមក្បួនវេជ្ជសាស្ត្របាននិយាយថានឹងនាំឱ្យកូនមានសុខភាពមិនមាំមាំ ព្រោះមេជីវិតរបស់បុរសស្ត្រី មិនទាន់មានកម្លាំងមាំមួនល្អ ។ ក្បួនវេជ្ជសាស្ត្របាននិយាយថា បុរសស្ត្រី គួររៀបអាពាហ៍ពិពាហ៍ពេលបុរសអាយុបាន ២៥ និងស្ត្រី ២៣ ឆ្នាំ ។ ម្យ៉ាងទៀត អាយុប៉ុណ្ណោះក៏វយៈពេលដែលបានទទួលការសិក្សាល្មមនឹងចិញ្ចឹមជីវិតខ្លួនបាន និងស្គាល់សុខទុក្ខរបស់ជីវិតបានគួរសមហើយ ។ ការរៀបអាពាហ៍ពិពាហ៍ពីអាយុ ១៦ ឬ ១៨ ឆ្នាំ ពេលនេះជាពេលកំពុងរៀនសូត្រ បើរៀបហើយនឹងមិនបានរៀនសូត្រទៀតឡើយ បើតាមច្បាប់ប្រទេសខ្លះ យកអាយុ ១៨ ឆ្នាំ ខ្លះ ២០ ឆ្នាំ ទើបជាអាយុដែលពេញនីតិភាវៈ ។

គូស្រករដែលមានមាឌតូចៗ លុះបានកូនមក កូននោះក៏នឹងមិនធំជាងឪពុក

ម្ដាយដែរ ។ រឿងនេះ ទាក់ទងទៅនឹងកម្លាំងសមត្ថភាពក្នុងការការពារប្រទេសផង ដែរ ។

ការយកសាច់ញាតិជិតៗពេក មកធ្វើជាគ្រួសារ ក៏មានពាក្យថា សតិបញ្ញាមិនសូវមានខ្លាំងពូកែដែរ ព្រោះ Gene របស់យើងមិនមានការអភិវឌ្ឍន៍ ។ បើមាតាបិតា ជាអ្នកមានជំងឺកាមរោគផងនោះ ជំងឺនេះអាចឆ្លងដល់កូន និងអាចធ្វើឱ្យកូនមានពិការភាព ឬ សតិបញ្ញាទន់ខ្សោយ ។ ជាពិសេស សព្វថ្ងៃនេះ ជំងឺអេដស៍ (AIDS) ជាជំងឺមួយដ៏កាចសាហាវដែលឆ្លងទៅកូន ហើយដែលគ្មានថ្នាំព្យាបាល បានឡើយ រង់ចាំតែថ្ងៃស្លាប់ប៉ុណ្ណោះ ។

បើគូស្រករយើងគ្មានសីល ជាមនុស្សទុច្ចរិត ដល់ពេលរៀបអាពាហ៍ពិពាហ៍ហើយ ស្រាប់តែមានទោសទណ្ឌ ត្រូវគេចាប់ដាក់ឃុំឃាំងនោះ កូនយើងក៏ប្រាកដជាកំព្រា និងខ្វះទីពឹងសម្រាប់អភិវឌ្ឍន៍ខ្លួនគ្នាជាមិនខាន ។ល។

ចំណុចទាំងនេះ ជាចំណុចដែលអនាគតមាតាបិតា គួរពិចារណា និងទទួលខុសត្រូវចំពោះកូនយើងដែលនឹងត្រូវកើតពីយើង ពេលដែលយើងរៀបការហើយ ។

*ជាតិជាមាតាបិតា មិនចង់ឃើញកូនរបស់ខ្លួនដែល*
*កើតមកហើយ អស់សង្ឃឹមក្នុងជីវិតនោះឡើយ ។*

## ២. រយៈពេលចាប់បដិសន្ធិ

ជាធម្មតា ចាប់តាំងពីថ្ងៃចាប់បដិសន្ធិ រហូតថ្ងៃចេញចាកផ្ទៃ កូនត្រូវស្ថិតនៅក្នុងផ្ទៃមាតាចំនួន ៩ ខែ ១០ ថ្ងៃ ។ មានកូនខ្លះក៏នៅរហូតដល់ ១០ ខែ ឯខ្លះតែ ៨ ខែ ក៏ត្រូវប្រសូតមកក៏មាន ។ រយៈពេលនៃការលូតលាស់នៅក្នុងផ្ទៃនេះ ជារយៈដែលមាតាបិតា ត្រូវស្រឡាញ់ថ្នាក់ថ្នម និងការពារចំពោះអាយុជីវិតរបស់កូនហើយ ។ នៅក្នុងផ្ទៃ កូនរមែងទទួលអារម្មណ៍ដូចគ្នានឹងម្ដាយដែរ ដូច្នេះហើយបានជាពេលមានទម្ងន់ នាងជាមាតាមិនគប្បីខឹងច្រើន ខ្ញុំម៉ៅច្រើន ឬកើតទុក្ខទោមនស្សទេ ព្រោះនឹងអាចធ្វើឱ្យកូននោះមានមុខមាត់មិនស្អាតបាត ឬមុខក្រញូវដូចម្ដាយពេលខឹងដែរ។ អ្នកដែលជាឪពុកក៏ត្រូវថ្នមភរិយាខ្លួនដែរ ធ្វើយ៉ាងណាឱ្យនាងសប្បាយ ។ ក្នុងរយៈពេលមានទម្ងន់នេះ នាងជាមាតាតែងចង់ឃ្លានជានិច្ច ។ ការបរិភោគក៏មិនត្រូវតាមចិត្តចង់ដែរ ត្រូវគិតថា ចំណីនេះនឹងប៉ះពាល់ដល់កូនខ្លួន ដូចជារបស់មានជាតិស្រាជាតិក្ដៅ ហឹរ កូនយើងក៏ត្រូវទទួលជាតិអាល់កុលហឹរដែរ លុះដល់កើតមក ភាគច្រើន ក៏ច្រើនតែចេះផឹកស្រាដូចម្ដាយដែរ ។ គេបានណែនាំឱ្យនាងជាមាតាសម្លឹងរូបណាដែលស្អាតៗ ឬយករូបកូនក្មេងស្អាតៗ មកបិទដើម្បីឱ្យកាត់មោរកកូន ។ បើម្ដាយជាអ្នកមានសីលធម៌ ឧស្សាហ៍ធ្វើបុណ្យ ធ្វើទាន មានចិត្តរីករាយ កូនក៏នឹងអាចកាត់មោរកម្ដាយបានដែរ ។ គ្រប់ឥរិយាបថទាំងបួន ត្រូវប្រុងប្រយ័ត្ន ក្រែងលោឈឺចាប់ដល់កូន ។ ឪពុកមិនត្រូវវាយតប់ប្រពន្ធឡើយ ព្រោះបើវាមិនរលូតទេ ក៏នឹងអាចកើតមកពិការ ឬសតិបញ្ញាមិនល្អ ។ ការប្រើថ្នាំកែរោគ ដោយមិនស្គាល់គុណភាពថ្នាំច្បាស់លាស់ ឬមិនតាមបញ្ជាពេទ្យក៏នឹងអាចឱ្យកូនពិការដែរ ។ គួរឧស្សាហ៍ទៅឱ្យពេទ្យពិនិត្យពោះឱ្យបានញឹកញាប់ ។ គួរលើកលែងការរួមដំណេកខ្លះ និងគួរពិគ្រោះ

WAT KHEMARARATANARAM

ពេទ្យ ពីរឿងកម្រិតនៃការរួមដំណេកជាមួយស្វាមី ។ អ្នកជាឪពុកត្រូវប្រយ័ត្នក្នុងការទៅដើរលេងជាមួយស្រីពេស្យា ព្រោះនឹងអាចឆ្លងមេរោគកាមរោគពីស្រីទាំងនោះ លុះមកវិញរួមដំណេកជាមួយភរិយា ក៏ឆ្លងទៅដល់ភរិយា និងកូនផងដែរ ។ កូនដែលឆ្លងពីឪពុក ម្ដាយដូច្នេះ កើតមកច្រើនមានពិការភាព ឬខួរក្បាលមិនល្អ ។ ចាស់ៗខ្មែរយើងតែងឱ្យនាងជាម្ដាយផឹកថ្នាំឆ្លងទន្លេ បួន ឬប្រាំខែ មុនឆ្លងទន្លេ ព្រោះបើកូនស្រួល ការឈឺចាប់របស់ម្ដាយក៏មិនមានដែរ ។ ការដែលកូនលំបាកនេះ នឹងប៉ះពាល់ដល់សុខភាព និងខួរក្បាល អារម្មណ៍របស់កូនពិតជាប្រាកដ ។ ពេលប្រសូតទៀតសោត ក៏ត្រូវតែទៅពេទ្យ ឬបើគ្មានពេទ្យ ក៏គួររើសរកយាយឆ្មបណាដែលមានសមត្ថភាព និងមានអនាម័យក្នុងការកាត់ទងផ្ចិត ព្រោះការខ្វះអនាម័យនឹងអាចឱ្យកូនកើតរោគតេតាណូស លុះធំឡើងប្រកាច់ដែលយើងហៅថាស្គន់នោះឯង ។

ខ្ញុំពុំអាចអធិប្បាយឱ្យអស់ទេ ថាតើមាតាបិតាគួរថែទាំកូនក្នុងផ្ទៃយ៉ាងណា ព្រោះខ្ញុំក៏មិនបានរៀនសូត្ររឿងនេះដោយត្រង់ គ្រាន់តែបានដឹងឮពីចាស់ៗ និងបានអានសៀវភៅខ្លះៗប៉ុណ្ណោះ ។ ដូច្នេះ គួរមាតាបិតាសាកសួរចាស់ៗ ដែលមានការពិសោធន៍ និងពេទ្យសម័យថ្មីផងចុះ ។ *តែអ្វីដែលខ្ញុំចង់បង្ហាញនុ៎ះ គឺការទាញអារម្មណ៍មាតាបិតាថា អ្នកមានសារសំខាន់ណាស់ ចំពោះអនាគតរបស់កូន តាំងពីកូនអ្នកនៅក្នុងផ្ទៃនាងជាមាតានោះ ជាការមួយដែលអ្នកត្រូវថ្នាក់ថ្នម ថែទាំជីវិតដ៏តូចស្រាលនេះ ឱ្យមានការរីកចំរើនលូតលាស់ដោយប្រពៃ ដើម្បីស្នងវង្សត្រកូលអ្នក បន្តមរតកមនុស្សជាតិ និងជាទីរីករាយរបស់អ្នកផង ។*

WAT KHEMARARATANARAM

## ៣. រយៈពេលកូនចំរើនធំល្មមពេលហាស់

មានសុភាសិតនៅក្នុងហិតោបទេស បាននិយាយថា : « *បណ្ដាកូនទាំង ៣ ពួក គឺកូនដែលមិនទាន់កើតមួយ, កូនដែលកើតហើយស្លាប់មួយ, និងកូនដែលកើតហើយល្ងង់មួយ, កូនពីរខាងដើមធ្វើទុក្ខតែម្ដងទេ តែកូនទី៣ ធ្វើទុក្ខឪពុកម្ដាយអស់មួយជីវិត* » ។

សុភាសិតនេះ ពញ្ញាក់យើងឱ្យឃើញថា « ការចិញ្ចឹមកូន ជារឿងពិបាកបំផុត » ។ នៅក្នុងពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ នាទីចិញ្ចឹមបីបាច់ ថែរក្សាកូនរបស់មាតាបិតា បាក់ដូចជាចប់សព្វគ្រប់ នៅពេលដែលចែកទ្រព្យសម្បត្តិឱ្យកូនស្រី ប្រុស តាមឱកាសដែលខ្លួនយល់ថាសមគួរមួយ ។ បើពិនិត្យតាមនេះ ម៉ែឪ រហ័សចែកទ្រព្យសម្បត្តិឱ្យកូន ម៉ែឪ ក៏រហ័សអស់កិច្ចរវល់ដែរ តែបើម៉ែឪណាទុកដល់ពេលជិតខ្លួនស្លាប់ ទើបចែកទ្រព្យនោះ ម៉ែឪនោះក៏រវល់តែនឹងរឿងកូន រហូតដល់ខ្លួនស្លាប់ទើបឈប់រវល់ ។ ខ្ញុំឃើញ និងឮម៉ែឪជាច្រើន នៅពេលខ្លួនស្លាប់ទៅហើយ ក៏នៅតែរវល់ទៀត ដូចជានៅក្នុងជំនឿខ្មែរដែលទៅមានជឿលើខ្មោចចូល ឬបញ្ចូលខ្មោចជាដើម ខ្ញុំតែងឃើញខ្មោចម៉ែឪនោះយំស្រែក ព្រោះអាណិតកូន និងកូនឬថាគាត់មិនទាន់ទៅរកភពឃើញទេ ព្រោះនៅរវល់ជាប់ជំពាក់នឹងកូន នៅតាមជួយថែរក្សាកូនជាដើម ។ មិនតែប៉ុណ្ណោះ បើទោះជាម៉ែឪ ឈប់រវល់ទៅហើយក្ដី ក៏កូននៅសុំប្រើដែរ ដូចជាកូនខ្លះបន់ខ្មោចម៉ែឪជួយថែរក្សាខ្លួន សុំឱ្យម៉ែឪជួយឱ្យខ្លួនលេងល្បែងស៊ីសងឈ្នះ ឬសុំឱ្យមកពន្យល់លេខឆ្នោត ជាដើម ។ អនិច្ចាម៉ែឪ ទាំងឡាយអើយ ! អ្នករស់សម្រាប់តែកូនទេឬ ? នៅឥណ្ឌាពីអតីតកាល ជនជាតិឥណ្ឌាដែលកាន់សាសនាហិណ្ឌូ ( ព្រហ្មញ្ញ សាសនា ) បានកាន់ប្រតិបត្តិដើរតាមវិធីជីវិត

ដែលគម្ពីរឧបនិស័ទកំណត់ទុកឱ្យជា ៤ លំដាប់ជីវិត ដែលហៅថាអាស្រម ៤ គឺ ៖

១. *ព្រហ្មចារី* ៖ ជាវ័យដែលត្រូវសិក្សារៀនសូត្រយកនូវចំណេះវិជ្ជាទាំងឡាយ ទាំងខាងសិល្បសាស្ត្រ វិទ្យាសាស្ត្រ និងសីលធម៌សម្រាប់ជាប្រទីបក្នុងដំណើរជីវិត និងឧបករណ៍សម្រាប់ចិញ្ចឹមជីវិតខ្លួនតទៅ ។ លំដាប់ទី ១ នេះ មានរយៈពេលពីអាយុខ្ទង់ ៧ ឆ្នាំ ទៅដល់ ២០ ឬ ២៥ ឆ្នាំ តាមដែលរយៈការសិក្សាវែង ឬ ខ្លី ។

២. *គ្រហស្ថ* ៖ ជាវ័យដែលត្រូវយកគូស្វាមីភរិយា ចិញ្ចឹមជីវិតរកស៊ី ទុកដាក់ទ្រព្យសម្បត្តិដោយខ្លួនឯង សាងខ្លួន សាងឋានៈនៅក្នុងសង្គម មានកូនតវង្សត្រកូល ។ល។ តាមបែបបុថុជ្ជន និងគ្រហស្ថទូទៅ ។ រយៈនេះ មានរយៈពេលខ្ទង់ពី ២៥ ទៅ ៥០ ឆ្នាំ ។

៣. *វានប្រស្ថ* ៖ ជាវ័យដែលត្រូវព្យាយាមនឹងបដិបត្តិធម៌ទៅតាមបែបព្រាហ្មណ៍នៅក្នុងព្រៃ តែក៏នៅជាប់ជំពាក់នៅផ្ទះសម្បែងដែរ ។

៤. *សន្យាសី* ៖ ជាលំដាប់ចុងក្រោយ គឺត្រូវលះបង់កិច្ចការខាងផ្លូវលោកទាំងស្រុង បំពេញខ្លួនជាព្រ័ត្រ ឬបួសពនេចរ ដើម្បីស្វែងរកតម្លៃពិតនៃជីវិត ។ លំដាប់នេះ គឺតែកាលណាចេញទៅហើយ គឺស្លាប់នៅក្នុងព្រៃតែម្តង ។

ព្រះពុទ្ធសាសនា ហាក់ដូចជាមិនបានកំណត់ថា អាយុណាដែលម៉ែឪ ត្រូវលះបង់កូនឱ្យដាច់ ដើម្បីបដិបត្តិធម៌ទេ ព្រោះអនិច្ចតាធម៌ គឺសភាពមិនទៀងក្នុងជីវិត ពុំបានរង់ចាំបុគ្គលណា ឬប្រាប់បុគ្គលណាថា ចាំអាយុប៉ុណ្ណោះប៉ុណ្ណោះ ចាំបដិ-បត្តិឡើយ ។ តែទោះជាយ៉ាងណាក្តី ក៏យើងឃើញខ្មែរយើងខ្លះ តែដល់អាយុចាស់ហើយ គឺ ៦០ ឬ ៧០ ឆ្នាំ ក៏តែងទៅនៅវត្តវ៉ា ដើម្បីភាវនាធម៌ដែរ តែតិចតួចណាស់ ភាគច្រើននៅជាមួយកូនរហូតដល់ថ្ងៃស្លាប់តែម្តង ។

ក្នុងព្រះពុទ្ធសាសនា មានធម្មៈច្រើនណាស់ ដែលនិយាយពីរឿងមាតាបិតាចំពោះកូន ។ ដែលគេឯងស្គាល់ជាងគេ គឺព្រះសូត្រឈ្មោះ សិង្គាលោវាទសូត្រ ដែលនិយាយពីទិស ៦ យ៉ាង តែក្នុងទីនេះ ខ្ញុំព្យាយាមប្រមូល និងបែងចែកធម្មៈ ឬករណីយកិច្ចមាតាបិតាចំពោះកូន តាមដែលមានក្នុងគម្ពីរព្រះត្រៃបិដក ជា ៤ ប្រការធំៗ ដូចរូបខាងក្រោម ដើម្បីងាយស្រួលក្នុងការចាំ ៖




WAT KHEMARARATANARAM

## ក. មាតាបិតាជាអភិវឌ្ឍនករសម្រាប់បុត្រ

ក្នុងបណ្ដាសត្វដែលចិញ្ចឹមកូននឹងទឹកដោះដូចគ្នា មនុស្សយើងមានការរីកចំរើនល្អណាស់ ផ្នែករាងកាយ និងចិត្តគំនិតប្លែកខុសគ្នាឆ្ងាយណាស់ពីពួកសត្វតិរច្ឆានដទៃ ។ ចំណុចដែលខុសគ្នានោះ គឺនៅត្រង់ពេលកើតមកភ្លាម ទារកមនុស្សពុំអាចពឹងលើខ្លួនឯងបានមាល់តែសោះ ដូចជា មិនអាចចេះងើបឈរ អង្គុយ ដើរបានភ្លាមទេ មានសភាពទន់ខ្សោយខាងរាងកាយខ្លាំងណាស់ នៅពេលដែលសត្វតិរច្ឆានដែលចិញ្ចឹមកូននឹងទឹកដោះដែរ ដូចគ្នានឹងមនុស្ស ដូចជា ស្វា គោ ឆ្កែ ជាដើម ពេលកើតមកភ្លាម ទារកសត្វទាំងនោះចេះឈរ ដើរ អង្គុយបាន ហើយតែ ៤.៥ ថ្ងៃប៉ុណ្ណោះ ក៏អាចរត់ ហក់កញ្ឆេងបានភ្លាម ។ ចំណុចខុសប្លែកមួយទៀត គឺការរីកចំរើនខាងសតិបញ្ញា ការរីកចំរើនខាងសតិបញ្ញារបស់សត្វមានទីបញ្ចប់ មានលក្ខណៈទៅតាមសញ្ជាតិញ្ញាណពីកំណើត នៅពេលដែលមនុស្សមានសតិបញ្ញារីកចំរើន មិនចេះចប់មាល់តែសោះ ។ ធាតុភាពបែបនេះ ក្នុងទស្សនៈពុទ្ធសាសនាលោកថា ព្រោះមនុស្សមានធម្មសញ្ញា ។ ធម្មសញ្ញាធ្វើឱ្យមនុស្សខុសពីសត្វ ។ មនុស្សចេះគិត ចេះដឹងខុសត្រូវ ចេះរស់ជាក្រុមគ្រួសារ មានអក្សរ មានភាសានិយាយ ។ល។ ធាតុភាពបែបនេះ អ្នកប្រាជ្ញខ្លះអធិប្បាយថា ព្រោះមនុស្សចេះរស់នៅជាសង្គម និងមានវប្បធម៌ ឯសត្វមិនមានរបស់ទាំងពីរនេះទេ ។

ពាក្យថាសង្គម ប្រែយ៉ាងខ្លីថា ការរួមរស់នៅជាមួយគ្នា ដោយមានអង្គប្រកបសម្រាប់បញ្ជាក់នូវលក្ខណៈរបស់សង្គម ៦ យ៉ាងគឺ :

១. ការមានអាណាបរិវេណ ឬ ដីដែលមានព្រំប្រទល់ជាដែនកំណត់ ( Territory ) ,

WAT KHEMARARATANARAM

២. ការរស់នៅជាក្រុម ( Group living ),

៣. ការដឹងនរណាជាពួកខ្លួន នរណាមិនមែនជាពួកខ្លួន ( Discrimination ),

៤. ការមានសម្ពន្ធភាព និងទំនាក់ទំនងគ្នាទៅវិញទៅមក ( Relation and Interaction ),

៥. ការបែងនាទី និងសហប្រតិបត្តិការ ( Division of Labor and Cooperation ),

៦. ការមានប្រព័ន្ធ ការគិត ជំនឿ តម្លៃនិយម បទដ្ឋានស្រដៀងៗគ្នា ( Idea, belief, value, norms ),

ពាក្យថាវប្បធម៌ បានដល់អ្វីៗគ្រប់បែបគ្រប់យ៉ាង ដែលប្រមូលយកការចេះដឹង ជំនឿ សិល្បៈ សីលធម៌ ច្បាប់ ប្រពៃណី សមត្ថភាព និងនិស្ស័យផ្សេងៗដែលមនុស្សបានមកក្នុងឋានៈជាសមាជិកសង្គម ( Tylor 1871 : 1 ) ក្នុងន័យម្យ៉ាងទៀត វប្បធម៌ គឺវិធីជីវិតរបស់មនុស្សនៅក្នុងសង្គមណាមួយ ។

ការព្យាយាមពន្យល់ឱ្យយល់ពីអ្វីដែលហៅថា សង្គម និងវប្បធម៌ ដោយសង្ខេបនេះ ក៏ដើម្បីចង់យោងមកលើរឿងនាទីមាតាបិតា ក្នុងឋានៈជាអភិវឌ្ឍនករថា មាតាបិតា មាននាទីជួយអភិវឌ្ឍកូនឱ្យអាចរស់នៅក្នុងសង្គម និងមានវប្បធម៌ដែលជាមរតករបស់សង្គម និងមនុស្សជាតិ បានដោយល្អប្រសើរ ។ អ្វីទៅអភិ-វឌ្ឍន៍ ?

បើប្រែតាមតួអក្សរៈត្រង់ៗ អភិវឌ្ឍន៍ គឺការធ្វើឱ្យរីកចំរើនដ៏ក្រៃលែង ។ បានដល់ទង្វើដែលចូលទៅជួយរបស់ ឬវត្ថុអ្វីមួយដែលមិនទាន់មានការរីកចំរើនដែល

មិនទាន់ល្អ ឱ្យមានការរីកចំរើនល្អឡើង ។

ពាក្យអភិវឌ្ឍន៍នេះ បើយកទៅប្រៀបនឹងពាក្យ ធម្មៈ នៅក្នុងព្រះពុទ្ធ-សាសនា ក៏ល្មមនឹងពាក្យថា « ភាវនា » បាន ។ ភាវនា ប្រែថា ការរីកចំរើន ការធ្វើឱ្យចំរើន ។

ពិនិត្យឱ្យច្បាស់ក្នុងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា គឺសុទ្ធតែជាពាក្យប្រៀនប្រដៅដែលសម្រាប់ឱ្យមនុស្សអភិវឌ្ឍជីវិតខ្លួន ពីកម្រិតទាប គឺ បុថុជ្ជនទៅជាកម្រិតខ្ពស់ ឬអរិយជនទាំងអស់ ។ ព្រះសម្មាសម្ពុទ្ធ ជាអភិវឌ្ឍនករ សម្រាប់ពុទ្ធបរិស័ទ ដើម្បីឱ្យពុទ្ធបរិស័ទអាចក្លាយខ្លួនទៅជាអរិយជនបាន ។ ក្នុងកម្មវិធីអភិ-វឌ្ឍន៍នេះ អភិវឌ្ឍនករ មាននាទីត្រឹមតែជាអ្នកណែនាំ ពន្យល់ប្រាប់ហ្វឹកហាត់ តែប៉ុណ្ណោះ ឯការដែលសម្រេចដល់គោលដៅ ឬមិនដល់នោះ ស្ថិតនៅមួយភាគធំលើអ្នកសិក្សា អ្នករៀន ។ យើងអាចប្រៀបកម្មវិធីអភិវឌ្ឍទៅនឹងពាក្យស្លោកខ្មែរថា « *ជួយគេឱ្យជួយខ្លួនឯងបាន* » ។ ម៉ែឪ ត្រូវមានការប្រុងប្រយ័ត្ននៅក្នុងការអភិ-វឌ្ឍន៍កូន ព្រោះថា បើយើងអភិវឌ្ឍខុស កូនយើងនឹងក្លាយទៅជាមនុស្សមិនមានការអភិវឌ្ឍន៍ បើអភិវឌ្ឍត្រូវ កូនយើងនឹងក្លាយទៅជាមនុស្សដែលមានការអភិ-វឌ្ឍន៍ ជាទីសរសើររបស់ជនទាំងពួង ។ ម៉ែឪខ្លះស្រឡាញ់កូន ជួយកូន ថ្នាក់ថ្នមកូនមិនឱ្យកូនធ្វើអ្វីសោះ រហូតដល់កូនលែងចេះធ្វើអ្វីដោយខ្លួនឯង ពឹងតែលើមាតាបិតាតែម្យ៉ាង ។ លុះដល់ម៉ែឪនោះស្លាប់ ឬមិនអាចជួយកូនទៅទៀតបាន ឬ ក៏កូននោះត្រូវបែកពីម៉ែឪ ដោយប្រការណាមួយ កូននោះក៏ក្លាយទៅជាមនុស្សល្ងីល្ងង់មិនចេះធ្វើអ្វី គ្មានគំនិត អាចនឹងជួបប្រសព្វនូវជោគជតាជីវិតអភ័ព្វ ឬក៏ក្លាយទៅជា « ខ្ជិលមនុស្ស » អស់រលីងក៏មាន ។

WAT KHEMARARATANARAM

**អភិវឌ្ឍកូនលើវិស័យអ្វីខ្លះ ?**

មាតាបិតា ត្រូវអភិវឌ្ឍកូនក្នុងវិស័យ ៤ យ៉ាងគឺ :

*១. កាយភាវនា ឬ ការអភិវឌ្ឍន៍ខាងផ្នែករាងកាយ :*




ការអភិវឌ្ឍន៍ខាងកាយ មានគោលបំណងទៅលើការបណ្តុះបណ្តាលកូនឱ្យមានការរីកចំរើនល្អ ទាំងខាងសុខភាព គុណភាព និងគុណធម៌ ។ សុខភាពជាវត្ថុចាំបាច់ដំបូងរបស់កូន ។ កូនដែលមានសុខភាពល្អ គឺកូនដែលបានទទួលចំណីអាហារជីវជាតិបានគ្រប់គ្រាន់ មិនមានជំងឺ រ៉ាំរ៉ៃ ធន់នឹងជំងឺ ។ មាតាបិតាគប្បីជួយថែរក្សាសុខភាពកូន ពេលដែលគេនៅតូច និងណែនាំឱ្យកូនចេះថែរក្សាសុខភាពរបស់ខ្លួនឱ្យបានល្អជានិច្ច ។ ព្រះសម្មាសម្ពុទ្ធ លោកបានត្រាស់ថា « *អរោគ្យា បរមា លាភា* » ប្រែថា : ការមិនមានរោគ ជាលាភយ៉ាងធំ ។ កាយដែលមានគុណភាព គឺកាយដែលរវៀសរវៃ ស្វាហាប់ មិនស្ពឹក រហ័សរហួន ។ ឯកាយដែលមានគុណធម៌ គឺកាយដែលមិនច្រងេងច្រងាង មានមារយាទ ។ ឧទាហរណ៍ នៃកាយដែលគ្មាន

គុណធម៌គឺដូចជាក្មេងខ្លះដើរបណ្តើរ ទាត់នេះទាត់នោះបណ្តើរ រើសក្តិចនេះ បេះនោះ ចូលក្នុងពាក្យថា « រពឹសដៃ ភ័យខ្លួន » ។

## ២. សីលភាវនា ឬ ការអភិវឌ្ឍន៍ខាងរឿងសីល :

សីលជា ឧបដិបត្តិ សម្រាប់ឱ្យមនុស្សរស់នៅក្នុងសង្គមបានដោយងាយស្រួល មិននាំនូវការក្តៅក្រហាយឱ្យកើតដល់ខ្លួន និងមិនប៉ះពាល់ដល់អ្នកដទៃ ជារឿងទាក់ទងនឹងការបញ្ចេញព្រឹត្តិកម្មរបស់ម្នាក់ៗ ។ មាតាបិតា មិនត្រឹមតែចិញ្ចឹមកូនឱ្យរស់ខាងកាយប៉ុណ្ណោះទេ តែត្រូវទទួលខុសត្រូវចំពោះព្រឹត្តិកម្មរបស់កូនដែរ ។ សុភាសិតខ្មែរ « *ដឹងធ្វើយឿតជង កូនលោតរំលងត្អូងឿតមេបា* » ជាគតិមួយគួរឱ្យពិចារណាយកណាស់ ។ មានចំណុច ៤ យ៉ាង ដែលមាតាបិតាត្រូវអប់រំបន្ទំព្រឹត្តិកម្មរបស់កូន គឺ :

២.១. អប់រំកូនឱ្យចេះប្រើប្រាស់អាយតនៈទាំង ៦ ឱ្យបានល្អ គឺ ការសង្រួមក្នុងភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ។ ឧទាហរណ៍ ភ្នែកពិតមែនតែគេសម្រាប់មើលមែន តែក៏ត្រូវចេះជ្រើសរើសមើលដែរ អ្វីដែលជារបស់មានប្រយោជន៍ មិនហុចទោស មិនបង្កើនដល់កិលេសតណ្ហា ដូចជាទៅមើលកុនអាសអាភាស មើលរឿងឃោរឃៅ កាប់សម្លាប់គ្នាជាដើម ។ ត្រចៀកមិនមែនសម្រាប់ស្តាប់ពាក្យជេរប្រទេច អាក្រក់ជាដើម ។ ឯមាត់ក៏មិនមែនមានដើម្បីសម្រាប់និយាយនូវរឿងមិនមានប្រយោជន៍ ជាដើម ។ ការបណ្តែតបណ្តោយកូនឱ្យប្រើអាយតនៈទាំង ៦ ដោយធ្វេសប្រហែស អាចនឹងនាំមកនូវទោសពៀរដល់បុត្រជាពិតប្រាកដ ។ ដូចពុទ្ធភាសិត បានសំដែងថា :

*ឥន្ទ្រិយានិ មនុស្សានំ ហិតាយ អហិតាយ ច*
*អរក្ខិតានិ អហិតាយ រក្ខិតានិ ហិតាយ ច ។*

« ឥន្ទ្រិយ៍ទាំងឡាយគឺ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្តរបស់មនុស្ស មាននៅដើម្បីជាប្រយោជន៍ផង មិនជាប្រយោជន៍ផង គឺដែលគេមិនរក្សា (មិនចេះប្រើ) មិនជាប្រយោជន៍ឡើយ ដែលគេរក្សា (ចេះប្រើ) ទើបជាប្រ.យោជន៍ » ។

២.២. ណែនាំអប់រំកូនឱ្យចេះគោរពច្បាប់ វិន័យ របៀបរៀបរយ មិនបណ្ដោយឱ្យកូនរំលោភច្បាប់ ឬបៀតបៀនច្បាប់របស់សង្គម ជាមូលដ្ឋាន អប់រំកូនកុំឱ្យមើលងាយ ប្រមាថ បៀតបៀនអាយុ ប្រទូសរ៉ាយរាងកាយមនុស្សសត្វផងគ្នា (បាណាតិបាតា វេរមណី) ណែនាំ អប់រំហ៊ឺកហ៊ឺនហាត់កូនកុំឱ្យរពិសដៃជើងលួចយកមិនប្រាប់នូវវត្ថុអ្វីដែលមិនមែនជារបស់ខ្លួន (អទិន្នាទានា វេរមណី) ការពារ រាំងមិនឱ្យកូនមើលងាយស្ត្រីភេទ ប្រព្រឹត្តកន្លងប្រពៃណីដោយខុសច្បាប់ ជំពាក់ជំពិននៅក្នុងរឿងស្នេហា ទាំងវ័យដែលខ្លួនមិនទាន់គ្រប់ និងកំពុងសិក្សា (កាមេសុ មិច្ឆាចារា វេរមណី)ពន្យល់កូនឱ្យឃើញពីទោសនៃការនិយាយកុហក បោកបញ្ឆោត ពាក្យអាក្រក់ ពាក្យគ្រោះឆ្អៀល ពាក្យគ្មានប្រយោជន៍ និងឱ្យកូនរក្សាខ្លួននៅតែក្នុងពាក្យសច្ចះ ពាក្យអាណិត ពាក្យត្រង់ ពិរោះ នាំឱ្យកើតមិត្តភាព មានប្រយោជន៍ (មុសា.វាទា វេរមណី) និងប្រយ័ត្នមិនឱ្យកូនធ្លាក់ទៅក្នុងអបាយមុខទាំងឡូង មានគ្រឿងស្រវឹង ញៀនគ្រប់ប្រភេទ មានសុរា ជារី កញ្ឆា អាភៀន រួមទាំងល្បែងស៊ីសងញៀនទាំងឡាយផង (សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី) ។

សង្គមខ្មែរយើងបច្ចុប្បន្ននេះ ខ្វះខាតអ្នកមានសីល អ្នកគោរពច្បាប់

វិន័យ ដើម្បីដឹកនាំសង្គមណាស់ ។ សូមឱ្យមាតាបិតា បណ្ដុះបណ្ដាលនិស្ស័យកូនឱ្យថែរក្សាសីល ៥ គោរពច្បាប់ វិន័យ ឱ្យបានគ្រប់គ្នា កុំបីខានឡើយ ។ អំពើពុករលួយក្ដី ការកាប់សម្លាប់គ្នាក្ដី កើតមកពីព្រោះការខ្វះខាតការយកចិត្តទុកដាក់អភិវឌ្ឍរឿងសីលនេះឯង ។

២.៣. ជំរុញទឹកចិត្ត និងបង្ហាញជាតួយ៉ាងដល់កូនក្នុងការប្រកបរបរចិញ្ចឹមជីវិតឱ្យបានត្រឹមត្រូវដោយគន្លងធម៌ និងត្រឹមត្រូវតាមច្បាប់ ។ សម្មាអាជីវកម្ម គឺការចិញ្ចឹមជីវិតមិនគកោង មិនយកប្រៀបលើគេ ពឹងលើកម្លាំង និងសតិបញ្ញាខ្លួនឯង និងអាជីវកម្មដែលមានសីលធម៌ ។ អាជីវកម្មខ្លះៗ ដូចតទៅនេះ មិនឈ្មោះថាជាអាជីវកម្មល្អឡើយ ដូចជា រកស៊ីលក់មនុស្ស រកស៊ីសម្លាប់មនុស្ស បើកបនពេស្យា លក់គ្រឿងអាវុធ ជំនួញគ្រឿងញៀនជាដើម ។ នៅក្នុងសេចក្ដីសុខរបស់គ្រហស្ថដែលអ្នកអានបានឃើញពីទំព័រដើមមកហើយ អនវជ្ជសុខ គឺសេចក្ដីសុខដែលកើតមកពីការចិញ្ចឹមជីវិតដែលមិនមានទោស ។ មាតាបិតា ត្រូវបង្ហាញឱ្យកូនឃើញនូវសេចក្ដីសុខនេះឱ្យច្បាស់ ។ ទ្រព្យណាដែលបានមកដោយមិច្ឆាជីព ទ្រព្យនោះរមែងក្ដៅក្រហាយឱ្យដល់បុគ្គលអ្នកកាន់ជាពុំខាន ។

២.៤. ហ្វឹកហាត់ឱ្យកូនចេះសន្សំសំចៃ ចេះចាយវាយលុយកាក់ ទ្រព្យសម្បត្តិ ដោយប្រុងប្រយ័ត្ន មិនយកទ្រព្យទៅបំផ្លាញនៅក្នុងអបាយមុខផ្សេងៗ ។ សុភាសិតខ្មែរដែលគួរយកជាគតិគឺ « ទូកតូចកុំបើកក្ដោងធំ » « អស់បោះនៅឡើយ អស់ហើយនៅបន្តិច » ហើយមិនមិនកំណាញ់ក្រៀតក្រោ រហូតដល់មិនមានបរិភោគប្រើប្រាស់អ្វីទាំងអស់ ធ្លាក់ជាម៉ៅស្វិត នាំឱ្យកើតក្ដៅក្រហាយដល់ខ្លួនឥត អំពើ ។

ក្នុងការរកទ្រព្យសម្បត្តិ និងចាយវាយទ្រព្យសម្បត្តិ ព្រះពុទ្ធលោកបាន

បែងចែកប្រភេទយោងទៅតាមការសរសើររបស់បណ្ឌិត ដូចតទៅនេះ ៖

• *ក្រុមទី ១ :* ស្វែងរកទ្រព្យដោយមិនត្រឹមត្រូវតាមធម៌ ៖

១. ជនពួកមួយ ស្វែងរកទ្រព្យដោយមិនត្រឹមត្រូវតាមធម៌ បានទ្រព្យមកហើយ មិនចិញ្ចឹមខ្លួនឱ្យបានឆ្អែតសុខ មិនបែងចែកជួយឱ្យអ្នកដទៃ និងមិនធ្វើបុណ្យមានដែលជាកុសលកម្ម ។

២. ជនពួកមួយ ស្វែងរកទ្រព្យដោយមិនត្រឹមត្រូវតាមធម៌ បានមកហើយ ចិញ្ចឹមខ្លួនឱ្យបានសុខឆ្អែត តែមិនបែងចែកជួយអ្នកដទៃ និងមិនធ្វើកុសលកម្ម ។

៣. ជនពួកមួយ ស្វែងរកទ្រព្យដោយមិនត្រឹមត្រូវតាមធម៌ បានមកហើយ ចិញ្ចឹមខ្លួនបានសុខឆ្អែត ចែកចាយជួយអ្នកដទៃ និងធ្វើនូវកុសលកម្ម ។

ក្នុងក្រុមទី១ នេះ ពួកទី១ គួរតិះទៀនទាំង ៣ កន្លែង ពួកទី២ គួរតិះទៀន ២ កន្លែង សរសើរមួយកន្លែង ពួកទី៣ គួរតិះទៀន ១ កន្លែង សរសើរ ២ កន្លែង ។

• *ក្រុមទី ២ :* ស្វែងរកទ្រព្យដោយត្រឹមត្រូវខ្លះ មិនត្រឹមត្រូវខ្លះ ៖

៤. ជនពួកមួយ ស្វែងរកទ្រព្យដោយត្រឹមត្រូវតាមធម៌ខ្លះ មិនត្រឹមត្រូវតាមធម៌ខ្លះ បានទ្រព្យមកហើយ មិនចិញ្ចឹមខ្លួនឱ្យឆ្អែតជាសុខ មិនបែងចែកជួយអ្នកដទៃ និងមិនធ្វើនូវកុសលកម្ម ។

៥. ជនពួកមួយ ស្វែងរកទ្រព្យដោយត្រឹមត្រូវតាមធម៌ខ្លះ មិនត្រឹមត្រូវតាមធម៌ខ្លះ បានទ្រព្យមកហើយ ចិញ្ចឹមខ្លួនឱ្យឆ្អែតជាសុខ តែមិនបែងចែកជួយអ្នកដទៃ និងមិនធ្វើនូវកុសលកម្ម ។

៦. ជនពួកមួយ ស្វែងរកទ្រព្យដោយត្រឹមត្រូវតាមធម៌ខ្លះ មិនត្រឹមត្រូវតាមធម៌ខ្លះ បានទ្រព្យមកហើយ ចិញ្ចឹមខ្លួនឱ្យឆ្អែតជាសុខ ចែកជួយអ្នកដទៃ និងធ្វើ

នូវកុសលកម្ម ។

ក្រុមទី២ ពួកទី៤ គួរតិះដៀល ៣ កន្លែង សរសើរ ១ កន្លែង ពួកទី៥ តិះដៀល ២ សរសើរ ២ ពួកទី៦ តិះដៀល ១ សរសើរ ៣ ។

● *ក្រុមទី ៣ :* ស្វែងរកទ្រព្យដោយត្រឹមត្រូវដោយធម៌ :

៧. ជនពួកមួយ ស្វែងរកទ្រព្យដោយត្រឹមត្រូវ បានទ្រព្យមកហើយ ចិញ្ចឹមខ្លួនឱ្យឆ្អែតជាសុខ មិនបែងចែកជួយអ្នកដទៃ និងមិនធ្វើនូវកុសលកម្ម ។

៨. ជនពួកមួយ ស្វែងរកទ្រព្យដោយត្រឹមត្រូវ បានទ្រព្យមកហើយ ចិញ្ចឹមខ្លួនឱ្យឆ្អែតជាសុខ តែមិនបែងចែកជួយអ្នកដទៃ និងមិនធ្វើនូវកុសលកម្ម ។

៩. ជនពួកមួយ ស្វែងរកទ្រព្យដោយត្រឹមត្រូវ បានទ្រព្យមកហើយចិញ្ចឹមខ្លួនឱ្យឆ្អែតជាសុខ បែងចែកជួយអ្នកដទៃ និងធ្វើនូវកុសលកម្ម ។

ក្រុមទី៣ ពួកទី៧ តិះដៀល ២ កន្លែង សរសើរ ១ កន្លែង ពួកទី៨ តិះដៀល ១ កន្លែង សរសើរ ២ កន្លែង ពួកទី៩ សរសើរទាំង ៣ កន្លែង ។

● *ពួកពិសេស :* ជនពួកមួយ ស្វែងរកទ្រព្យដោយត្រឹមត្រូវ បានទ្រព្យមកហើយ ចិញ្ចឹមខ្លួនឱ្យឆ្អែតជាសុខ បែងចែកជួយអ្នកដទៃ និងធ្វើអំពើជាកុសលកម្មផង មិនប្រមាទមួរម៉ៅ មិនជាប់នឹងការបរិភោគ ប្រើប្រាស់នូវទ្រព្យទាំងនោះ ដឹងនូវទោសនៃការជាប់ជំពាក់ក្នុងទ្រព្យសម្បត្តិ មានបញ្ញាធ្វើខ្លួនឱ្យមានឥស្សរភាព ជាម្ចាស់លើទ្រព្យសម្បត្តិបាន ។ មាតាបិតា គួរជ្រើសរកយកប្រភេទក្រុមទី ៣ ក្នុងការអប់រំណែនាំកូនឱ្យក្លាយជាក្មេងដែលមានការអភិវឌ្ឍល្អ ក្នុងផ្លូវអាជីវកម្ម និង ក្រុមពិសេស ដើម្បីជីវិតឧត្តមគតិ មិនមែនឱ្យកូនទៅជាខ្ញុំទ្រព្យសម្បត្តិនាអនាគតទេ ។

៣. *ចិត្តភាវនា ឬការអភិវឌ្ឍន៍ខាងផ្លូវចិត្ត :*




*ចិត្តេន នីយតិ លោកោ :* លោកតែងដឹកនាំទៅដោយចិត្ត

*ចិត្តស្ស ឯកធម្មស្ស សព្វេវ វសមន្វគូ* គ្រប់បែបគ្រប់យ៉ាងធ្លាក់នៅក្រោមអំណាចរបស់វត្ថុមួយ៉ាង គឺ ចិត្ត

*ចិត្តេ សង្កិលិដ្ឋេ បាដិកង្ខា* កាលណាចិត្តសៅហ្មងហើយ រមែងទៅកាន់ទុគ្គតិ

*ចិត្តេ អសង្កិលិដ្ឋេ បាដិកង្ខា* កាលណាមិនមានចិត្តសៅហ្មងហើយ សុគតិ រមែងមានសង្ឃឹម

*យោ ច សព្វបរិត្តាសី វនេ វាតមិគោ យថា លហុចិត្តោតិ តំ អាហុ*

*នាស្ស សម្មជ្ជតេ វតំ* ។ អ្នកណាភ្ញាក់ផ្អើលចំពោះសំឡេងដូចម្រឹគស្ទាន់ព្រៃ លោក ហៅអ្នកនោះថា មានចិត្តស្រាល កិច្ចវត្តរបស់អ្នកនោះរមែងមិនសម្រេច ។

ពុទ្ធភាសិត ៣-៤ ដែលលើកយកមកបង្ហាញនេះ យើងឃើញថាព្រះពុទ្ធ-សាសនា ប្រកាន់ថា ចិត្តជារបស់សំខាន់ ដែលនឹងនាំឱ្យមានសេចក្ដីសុខ ឬ សេចក្ដីទុក្ខ អាក្រក់ ឬ ល្អ រហូតដល់ពេលស្លាប់ ចិត្តក៏កំណត់នូវជីវិតក្រោយ ពេលស្លាប់របស់បុគ្គលនោះទៀត ឬសូម្បីតែការសម្រេចព្រះនិព្វាន ដែលជាគោលដៅខ្ពស់បំផុតរបស់ព្រះពុទ្ធសាសនា ក៏នឹងអាចសម្រេចបានព្រោះចិត្តតែប៉ុណ្ណោះ ។

ដូច្នេះ ការអភិវឌ្ឍន៍ចិត្ត ទើបជាការសំខាន់ណាស់ ដែលមាតាបិតា មាននាទីយ៉ាងធំ ក្នុងការជួយកូនឱ្យមានចិត្តល្អ ជាកុសល ដែលនៅក្នុងនោះ ចិត្តដែលល្អ គឺចិត្តដែលមានសុខភាព គុណភាព និងគុណធម៌ ។

## ចិត្តមានសុខភាព ៖

ចិត្តដែលមានសុខភាពល្អ គឺចិត្តដែលរីករាយមិនចេះកើតទុក្ខ មិនងាយសោកសៅ មិនងាយខឹង មិនរវើរវាយ ពេលសម្រាកលក់ ក៏មិនយល់សប្តិផ្ដេសផ្ដាស មិនមមើមមាយ ។ មនុស្សដែលមានសុខភាពល្អ រាងកាយក៏នឹងមានសុខភាពល្អដែរ តែបើសុខភាពមិនល្អ ចិត្តមិនល្អ រាងកាយក៏នឹងឈឺចាប់ជាញឹយៗ ។

មាតាបិតា គប្បីប្រឹកបាត់កូនឱ្យជាមនុស្សរីករាយ ញញឹមជាប់ជានិច្ច មិនគប្បីឱ្យកូនគិតទៅលើរឿងឥតប្រយោជន៍ បើមានជំងឺក៏រហ័សព្យាបាល ព្រោះបើបណ្តោយយូរអាចនឹងទៅជាវិកលចរិតបាន ។ ត្រូវធ្វើខ្លួនឱ្យទៅ ជាទីទំនុកចិត្តរបស់កូន អាចឱ្យកូនបញ្ចេញប្រាប់នូវរឿងតានតឹងក្នុងខ្លួនបាន ហើយជួយដោះស្រាយមិន

គប្បីធ្វើទារុណកម្ម ឬកៀបសង្កត់ពេលកូនកំពុងមានអារម្មណ៍មិនល្អឡើយ ដែលនឹងអាចឱ្យខូចសុខភាពរបស់កូន ។ ម្យ៉ាងទៀត គួររៀបចំបរិយាកាសជុំវិញកូនឱ្យល្អ មិនគប្បីបណ្តោយឱ្យកូនប្រើភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ទៅលើរបស់ដែលអាចធ្វើឱ្យខូចសុខភាពចិត្តឡើយ ។ ដូចជារឿងស្រើបស្រាល រឿងឃោរឃៅ រឿងតក់ស្លុត រឿងខ្លាចព្រឺ ។ ល ។ មានពាក្យស្លោកមួយដែលគួរឱ្យចាប់អារម្មណ៍គឺ « *នៅម្នាក់ឯងឱ្យប្រយ័ត្នរឿងគិត នៅជាមួយមិត្តឱ្យប្រយ័ត្នវាចា* » ។ បើមានជំងឺផ្លូវចិត្ត គួររហ័សនាំទៅមន្ទីរពេទ្យវិបត្តិផ្លូវចិត្ត ឬពេទ្យចិត្តវិទ្យាឱ្យបានឆាប់ ។

## ចិត្តមានគុណភាព ៖

ចិត្តដែលមានគុណភាព គឺចិត្តដែលមានការអត់ធន់ អត់ធ្មត់ រឹងប៉ឹង ក្លាហាន មោះមុត ពូកែគិត ចាំបានយូរ ពូកែចាំ ពូកែដឹង មិនងាយតក់ស្លុតជាដើម ។ ការហ្វឹកហាត់ចិត្តឱ្យមានគុណភាព ឱ្យមានសមាធិរឹងប៉ឹង ឱ្យចិត្តនឹងនំ មិនប្រែប្រួលងាយៗ មានប្រយោជន៍ខ្លាំងណាស់ក្នុងការរស់នៅ ព្រោះបើចិត្តមិនស៊ូ ទន់ខ្សោយ មិនមានសមាធិ វិលវល់ៗ ចាប់នេះចាប់នោះមិនផ្តោះត្រង់ណាហើយ នឹងអាចឱ្យបរាជ័យក្នុងកិច្ចការជាពិតប្រាកដ ។ ឧទាហរណ៍ ដែលអាចងាយយល់គឺ មនុស្ស ២ នាក់ រាងកាយមាំទាំដូចគ្នា អ្នកដែលចិត្តមានគុណភាព ធ្វើអ្វីធ្វើទាល់តែសម្រេច បើទោះជាមានឧបសគ្គយ៉ាងណាក៏ដោយ ឯមនុស្សដែលចិត្តមិនមានគុណភាព ធ្វើការប៉ះអ្វីតែបន្តិចបន្តួចក៏រាថយ បញ្ឈប់ការងារ ឬចាប់នេះចាប់នោះមិនផ្តោះត្រង់ណា ។ ប្រយោជន៍ក៏មិនសម្រេចដល់ជនដែលមិនតស៊ូនោះឡើយ ។ ការឱ្យកូនហាត់សមាធិជាវិធីមួយ ដែលមាតាបិតាអាចជួយកូនឱ្យមានចិត្ត ដែលមានគុណភាពបាន យ៉ាង

ប្រសើរ ។

## ចិត្តមានគុណធម៌ :

ត្រង់ចំណុចនេះ ខ្ញុំសូមលើកចិត្តដែលមិនមានគុណធម៌មកជូនអ្នក ជាមាតាបិតាឱ្យបានដឹង ដើម្បីងាយស្រួលដល់ការចៀសវាងពេលអប់រំកូន ។ ចិត្តដែលមិនមានគុណធម៌ ១៦ យ៉ាង :

១. *អភិជ្ឈាវិសមលោភ* : គិតតែពីចង់បាន លោភមិនសមគួរ លោភខ្លាំង ។

២. *ព្យាបាទៈ* ចិត្តអាក្រក់ គិតតែពីចង់បៀតបៀនគេ ។

៣. *កោធៈ* ចិត្តក្រោធ ខឹង ។

៤. *ឧបនាហៈ* ចងក្រោធ ចងគំនុំ គុំគួន ។

៥. *មក្ខៈ* លើ្មសគុណ មិនដឹងគុណ បំភ្លេចគុណ លប់បំបាត់អំពើល្អរបស់បុគ្គលដទៃ ។

៦. *បលាសៈ* វាយខ្លួន លើកកំពស់ខ្លួនស្មើគេ គិតថាមានតែខ្លួនល្អជាងគេ មិនព្រមឱ្យនរណាល្អជាងខ្លួន ។

៧. *ឥស្សា* ចិត្តឫស្យា ច្រណែននិន្ទា ។

៨. *មច្ឆរិយៈ* ស្វិតកំណាញ់ ម៉ៅស្វិត បានអ្វីទុកតែឯង មិនចែករំលែក គិតអាណិតអាសូរអ្នកដទៃ ។

៩. *មាយា* ក្រឡិចក្រឡុច បោកប្រាស បាតដៃខ្នងដៃ មានល្បិចអាក្រក់ ។

១០. *សាថេយ្យៈ* អួតអាង បោកប្រាសគេដោយពាក្យអួត យកមេឃ

ទ្រាប់អង្គុយ ។

១១. *ថម្ភៈ* ក្បាលរឹង ។

១២. *សារម្ភៈ* ប្រកួតប្រជែងមិនឈប់ គិតតែពីចង់ឈ្នះ ចង់ចាញ់ ។

១៣. *មានះ* ប្រកាន់ខ្លួន ប្រកាន់ឫក ថាគេមិនដល់ខ្លួន អញស្មើនឹងគេដែរ គេគ្រាន់បើជាងអញ ។

១៤. *អតិមានះ* មើលងាយមើលថោកគេ ថាគេមិនដល់ខ្លួន ។

១៥. *មទះ* ស្រវឹងខ្លួន ។

១៦. *បមាទះ* ប្រមាទ ធ្វេសប្រហែស មិនយកចិត្តទុកដាក់ បណ្ដែតបណ្ដោយ ។

ចិត្តមិនល្អទាំង ១៦ នេះ អាចបង្រួមសង្ខេបមកត្រឹម ៣ ប្រការ គឺចិត្តដែលមានសេចក្ដីលោភ ( លោភៈ ) សេចក្ដីក្រោធ ខឹង ( ទោសៈ ) និងដែលមានសេចក្ដីវង្វេងមិនដឹងខុសត្រូវ ( មោហៈ ) ។

ចិត្តដែលមានគុណធម៌ ក្រៅពីផ្ទុយនឹង ១៦ ខ ខាងលើនេះហើយ នៅមានចិត្តប្រកបទៅដោយព្រហ្មវិហារធម៌ ៤ ទៀត ដែលមាតាបិតា គប្បីបណ្ដុះដល់កូនគឺ :

១. *មេត្តា* មានសេចក្ដីអាណិតអាសូរចំពោះសព្វសត្វ ,

២. *ករុណា* មានចិត្តជួយសង្គ្រោះគេឱ្យបានសេចក្ដីសុខ មិនយកសុខតែឯង ,

៣. *មុទិតា* ត្រេកអររីករាយ ពេលគេបានសុខសប្បាយ មិនច្រណែនឈ្នានីស ផ្ដន្ធា ,

*៤. ឧបេក្ខា* ចិត្តជាកណ្ដាល មានយុត្តិធម៌ មិនលុះទៅក្នុងអគតិធម៌

ទោសនៃការដែលចិត្តមិនបានការអប់រំ គ្មានគុណធម៌ ដែលពុទ្ធភាសិត សំដែង គឺ :

*ទិសោ ទិសំ យន្តំ កយិរា វេរី វា បន វេរិនំ*
*មិច្ឆាបណិហិតំ ចិត្តំ បាបិយោ នំ តតោ ករេ ។*

បច្ចាមិត្តឃើញបច្ចាមិត្ត ឬ បុគ្គលមានពៀរឃើញបុគ្គលមានពៀរ គប្បីធ្វើនូវសេចក្ដីវិនាសឱ្យកើតដល់គ្នានឹងគ្នាយ៉ាងណា ចិត្តដែលបុគ្គលតាំងខុសគន្លងធម៌ហើយ នឹងធ្វើបុគ្គលនោះឱ្យលាមកអាក្រក់លើសជាងសេចក្ដីវិនាស ដែលបច្ចាមិត្តធ្វើដល់បច្ចាមិត្តទៅទៀត ។

*៤. បញ្ញាភាវនា ឬ ការអភិវឌ្ឍន៍ខាងផ្នែកសតិបញ្ញា :*

*ជីវតេវាបិ សប្បញ្ញោ អបិ វិត្តបរិក្ខយា*
*បញ្ញាយ ច អលាភេន វិត្តវាបិ ន ជីវតិ ។*

អ្នកមានបញ្ញា សូម្បីអស់ទ្រព្យ ក៏រស់នៅបាន អ្នកមិនមានបញ្ញា សូម្បីមានទ្រព្យ ក៏រស់នៅមិនបាន ។

*យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ*
*ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។*

បុគ្គលណាមួយឥតប្រាជ្ញា មានចិត្តមិនតាំងមាំ គប្បីរស់នៅអស់មួយរយឆ្នាំ ក៏មិនប្រសើរស្មើនឹងការរស់នៅមួយថ្ងៃរបស់អ្នកមានប្រាជ្ញា មានឈានឡើយ ។

ពុទ្ធភាសិតខាងលើនេះ អាចជាភស្តុតាងបានគ្រប់គ្រាន់ហើយចំពោះមាតា

បិតា ដែលបណ្តុះ និងអភិវឌ្ឍសតិបញ្ញាឱ្យកើតមានដល់កូន ។

## ប្រភពនៃបញ្ញា ៖

បញ្ញាអាចកើតឡើងដោយហេតុ ៣ ប្រការ

១. *ចិន្តាមយបញ្ញា* បញ្ញាកើតពីការគិតពិចារណារកហេតុផល

២. *សុតាមយបញ្ញា* បញ្ញាកើតពីការស្តាប់ ការសិក្សារៀនសូត្រ

៣. *ភាវនាមយបញ្ញា* បញ្ញាកើតពីការហ្វឹកហ្វឺនអប់រំ បដិបត្តិអនុវត្ត និងកើតពីការធ្វើសមាធិ ។

## បេះដូងអ្នកប្រាជ្ញ

អ្នកប្រាជ្ញលោកបានចងជាបទបាលីសម្រាប់ឧបករណ៍ដើម្បីឱ្យពួកយើងបង្កើនប្រាជ្ញាឱ្យរឹតតែកើនឡើងរហូតដល់ក្លាយទៅជាអ្នកប្រាជ្ញថា ៖ *សុ ចិ បុ លិ វិនិមុត្តោ កថំ សោ បណ្ឌិតោ ភវេ* ។ បុគ្គលបើប្រាសចាក *សុ ចិ បុ លិ* ហើយតើនឹងក្លាយទៅជាបណ្ឌិតម្តេចបាន ។

*សុ* ៖ មកពីពាក្យថា *សុត* ប្រែថាស្តាប់ សិក្សារៀនសូត្រ ។

*ចិ* ៖ មកពីពាក្យថា ចិន្ត បានដល់រៀនសូត្រស្តាប់ហើយ គប្បីយកមកត្រិះរិះពិចារណា ឱ្យបានឃើញច្បាស់ យល់ច្បាស់ ។

*បុ* ៖ មកពីពាក្យថា *បុច្ឆា* គឺប្រើត្រិះរិះពិចារណា ឬ ស្តាប់ហើយ រៀនហើយមិនយល់ គប្បីសាកសួរ មិនត្រូវអៀនខ្មាសឡើយ ដូចពាក្យស្លោកខ្មែរថា « *ចោកអ្វីនឹងដៃ ថ្លៃអ្វីនឹងមាត់* » ។

*លិ* ៖ មកពីពាក្យថា *លិខិត* បានដល់ការកត់ត្រា ក្រែងលោភ្លេច ចាំមិនបានយូរ ឬទុកជាភស្តុតាង សម្រាប់អះអាង ។ ម្យ៉ាងទៀត ការសរសេរសៀវភៅ ឬជាអត្ថបទ ជាការបង្កើននូវចំណេះឱ្យរីតតែបែកឡើង១ ជាលំដាប់ដែរ ។

មានអ្នកប្រាជ្ញអង់គ្លេសម្នាក់ ឈ្មោះលោកប្រ្សាន់ស៊ី បេខន់ ( Francis Bacon 1551-1626 ) បានសរសេរថា ៖

« Reading makes a full man

Conference makes a ready man

Writing makes an exact man »

ដែលអាចប្រែយកអត្ថរសបានថា ៖

*ការអានធ្វើឱ្យចេះច្រើន*

*ការធ្វើសន្និបាតធ្វើឱ្យចេះសព្វ*

*ការសរសេរធ្វើឱ្យចេះមែនមែន*

យើងអាចសង្ខេបនូវគន្លឹះ សម្រាប់បណ្តុះប្រាជ្ញាកូន ដូចតទៅនេះ ៖

១. ឱ្យកូនបានសិក្សារៀនសូត្រនូវសិល្បសាស្ត្រគ្រប់យ៉ាងទៅតាមសម័យនិយមទៅតាមលទ្ធភាពរបស់យើង និងដែលកូនអាចទៅបាន,

២. ណែនាំកូនឱ្យចូលចិត្តការអាន និង អានតែសៀវភៅដែលមានប្រយោជន៍,

៣. បើកឱកាសឱ្យកូនបានសាកសួរ និង ជំរុញកូនឱ្យចេះឆ្លើយ ចេះសួរ មិនគប្បីធុញទ្រាន់ចំពោះសំណួរកូនឡើយ ។ មានអ្នកប្រាជ្ញម្នាក់បាននិយាយថា

« *ចម្ងល់ ជាប្រភពនៃទស្សនវិជ្ជា* » ។

៤. លើកទឹកចិត្តកូនឱ្យមានឱកាសបញ្ចេញយោបល់ ពិភាក្សាគ្នាជាមួយខ្លួន និង ជាមួយបណ្ឌិតអ្នកប្រាជ្ញ មិនគប្បីបង្ក្រាបគំនិតកូនឡើយ ដូចពុទ្ធភាសិតលោកសំដែងថា « *កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ* ការជជែកពិភាក្សាគ្នាតាមកាល ជាមង្គលដ៏ឧត្តម » ។

៥. ផ្ដល់ឱកាស និងជំរុញឱ្យកូនចេះគិត ចេះសួរ ចេះរកហេតុផលដោយខ្លួនគេ ដោយមាតាបិតាគ្រាន់តែជាអ្នកណែនាំ មិនមែនចេះតែជួយគិតគូរទាំងអស់ទេ ។ ឧទាហរណ៍ កូនគិតចំណោទមិនចេញ មាតាបិតាមិនគួរធ្វើជំនួសកូនទេ តែពន្យល់ឱ្យកូនបានយល់ និងគិតធ្វើដោយខ្លួនគេ ។

៦. រៀបចំ និងជួយឱ្យកូនមានឱកាស និងអនុវត្តនូវអ្វីដែលគេរៀនចេះហើយមានប្រយោជន៍ និងដាក់កិច្ចការហ្វឹកហាត់អ្វីមួយឱ្យគេបានធ្វើ បានអនុវត្ត ។ ជាឧទាហរណ៍ យើងពន្យល់ពីរបៀបជិះកង់ដល់កូន បើកូននេះគ្មានកង់សំរាប់យកមកអនុវត្តទេ បញ្ហាដែលជិះកង់កើតនោះ នឹងមិនអាចកើតបានឡើយ ។

៧. លើកទឹកចិត្តអោយកូនចេះសរសេរជាអត្ថបទ ជារឿង ជារបាយ-ការណ៍ ឬ ជាហេតុការណ៍ ទស្សនៈអ្វីមួយដែលកូនបានឃើញ ឮ ពីង ដើម្បីជាការហ្វឹកហាត់កូនអោយរឹតតែប្រសើរឡើង ។

៨. ការធ្វើសមាធិ គឺតម្កល់ចិត្តឱ្យស្ងប់នោ នឹងអាចជួយកូនជាខ្លាំងក្នុងការរៀនសូត្របានឆាប់ចាំ ចាំហើយមិនភ្លេច ។ គួរសាកសួរវិធីធ្វើសមាធិសម្រាប់ជីវិតប្រចាំថ្ងៃ ពីលោកអ្នកចេះនឹងផងចុះ ។

## បញ្ហាត្រូវមានហេតុផល និងដោះស្រាយបញ្ហាបាន

បញ្ហាដែលបណ្ដុះឱ្យដល់កូន ត្រូវឈរលើហេតុផល និងអាចដោះស្រាយបញ្ហាបាន ។ បញ្ហាបែបនេះ ត្រូវមានលក្ខណៈជាអរិយសច្ចៈរបស់ព្រះសម្មាសម្ពុទ្ធ គឺៈ

១. បញ្ញាដឹងថាអ្វីជាសេចក្ដីទុក្ខ ឬ ជាបញ្ហាដែលត្រូវដោះស្រាយ ( ទុក្ខ-អរិយសច្ចៈ ) ។

២. បញ្ញាដឹងថា បញ្ហា និងទុក្ខទាំងអស់ កើតមានមកពីអ្វី ( ទុក្ខសមុទយ-អរិសច្ចៈ ) ។

៣. បញ្ញាដឹងថា បញ្ហា និងទុក្ខទាំងនោះ បើដោះស្រាយហើយ នឹងមានលក្ខណៈសុខស្រួលយ៉ាងណា ឬដឹងថា អ្វីជាគោលបំណងក្នុងការដោះស្រាយបញ្ហា ( ទុក្ខនិរោធអរិសច្ចៈ ) ។

៤. បញ្ញាដឹងថា អ្វីជាផ្លូវ វិធី មធ្យោបាយ សំរាប់ដោះស្រាយនូវបញ្ហា និងទៅដល់គោលបំណង គឺសេចក្ដីសុខដែលខ្លួនប្រាថ្នានោះ (ទុក្ខ-និរោធគាមិនី បដិបទាអរិយសច្ចៈ) ។

## គោលបំណងនៃការអភិវឌ្ឍន៍




WAT KHEMARARATANARAM

យើងបានឃើញហើយនូវវិស័យ ៤ យ៉ាង ដែលមាតាបិតាត្រូវជួយកូនក្នុងឋានៈជាអភិវឌ្ឍនករ ។ ការអភិវឌ្ឍន៍ខាងផ្នែករាងកាយ ខាងផ្នែកសីល, ខាងផ្នែកចិត្ត និងខាងផ្នែកបញ្ញា ។ ពាក្យបណ្ដាំចុងក្រោយចំពោះការអភិវឌ្ឍន៍នេះគឺ សូមឱ្យមាតាបិតាទាំងអស់ចាំថា វិស័យទាំង ៤ នេះ មិនអាចបោះចោលមួយណា ឬធ្វើតែមួយណានោះក៏បានទេ ព្រោះថាទាំង ៤ នេះ មានសម្ពន្ធភាពនឹងគ្នាទៅវិញទៅមក ។ យើងប្រៀបប្រដូចទៅនឹងកង់រថយន្ត ដែលមិនអាចមានកង់តែ ៣ ឬកង់តែ ១ បានទេ ។ បើមនុស្សមានកាយរឹងប៉ឹង តែបើគ្មានសីល គ្មានគុណធម៌ និងបញ្ញា ជននោះក៏មិនអាចទៅជាមនុស្សចំរើនបានដែរ ។ ដូចគ្នាដែរ បើមានកាយរឹងប៉ឹង មានសីលបរិបូណ៌ មានចិត្តល្អ តែបើគ្មានបញ្ញា ក៏ឈ្មោះថាជាមនុស្សអភ័ព្វ ។ ជាពិសេស បើមនុស្សមានតែបញ្ញា ហើយគ្មានសីល គ្មានគុណធម៌ក្នុងចិត្ត បញ្ញានោះក៏នឹងក្លាយទៅជាគ្រឿងសស្ត្រាវុធអាចសម្លាប់ម្ចាស់ និងសង្គមឱ្យវិនាសជាពិតប្រាកដ ។ បញ្ញាប្រៀបដូចជាកាំបិតដែលមានមុខពីរ បើយើងប្រើវាមិនត្រូវ ប្រាកដជាយើងនឹងត្រូវរបួសជាមិនខាន ។ ដូច្នេះ ទាំង ៤ នេះ មិនអាចញែកចេញពីគ្នាបានឡើយ ត្រូវអភិវឌ្ឍឱ្យបានព្រមគ្នា ។

ក្នុងឋានៈជាអភិវឌ្ឍនករ មាតាបិតាគប្បីដឹងថា ខ្លួនមានមុខងារ ៣ យ៉ាងគឺ

១. ប្រឹក្សាករ : ជាទីប្រឹក្សារបស់កូន

២. សិក្សាករ : ជាអ្នកផ្ដល់ការសិក្សាឱ្យកូន

៣. ឧបត្ថម្ភក : ជាអ្នកឧបត្ថម្ភ និងសម្រួលកិច្ចការឱ្យកូនទាំងនេះ ដោយយោរយើពាក្យថា « ជួយកូនឱ្យកូនអាចជួយខ្លួនឯងបាន » ។

## ខ. មាតាបិតាក្នុងតួនាទីជាបុព្វការីរបស់បុត្រ

បុព្វការី គឺអ្នកដែលបានធ្វើឧបការគុណជាដំបូងដល់អ្នកណាមួយ ។ មាតាបិតា និងមានឈ្មោះថាជាមាតាបិតាដោយបរិបូណ៌ ក៏ព្រោះជាអ្នកបានធ្វើឧបការៈគុណជាមុន ជាដំបូងដល់បុត្រាបុត្រី ។ ឧបការគុណដែលមានចំពោះកូន គឺចាប់ផ្តើមតាំងពីរៀបអាពាហ៍ពិពាហ៍ ពពោះកូន និងពេលដែលកូនប្រសូតមកហើយ ត្រូវចិញ្ចឹមកូនដោយយកចិត្តទុកដាក់ ។ មាតាបិតាខ្លះ មិនបានបំពេញនាទីជាបុព្វការីឱ្យគ្រប់គ្រាន់ដល់កូនទេ ដូចជាពាក្យស្លោកខ្មែរចំណាំនិយាយថា « កូនមើលតែកូនអណ្តើក » គឺបង្កើតកូនហើយ ដើរចោលកូន លែងលះគ្នា មិនថែរក្សាកូន ឬយកទៅបោះបង់ចោលជាដើម ។ ឈ្មោះថាកូនហើយគឺជាឈាម និងសាច់របស់ខ្លួន ដែលខ្លួនត្រូវបីបាច់ថែរក្សា ទំរាំនឹងអស់នាទីខ្លួនជាបុព្វការី ។ ពាក្យស្លោកខ្មែរថា « *កាត់ទឹកមិនដាច់ កាត់សាច់មិនបាន* » ជាការតឿនដល់មាតាបិតាថា បើដឹងថាកាត់មិនដាច់ហើយ ក៏ត្រូវប្រុងប្រយ័ត្នកុំឱ្យខូច កុំឱ្យពិបាកចិត្តក្នុងការកាត់ ។ ក្នុងទីនេះ ខ្ញុំនឹងមិននិយាយពីការចិញ្ចឹមកូនឱ្យធាត់ធំខាងផ្នែករាងកាយទេ ព្រោះបាននិយាយខ្លះហើយនៅខាងកាយភាវនា ហើយម្យ៉ាងទៀត ឧបការគុណខាងផ្នែករាងកាយឱ្យធំធាត់ មានសាច់ មានឈាម មិនសូវជាពិបាកទេ ព្រោះម៉ែ ឪណា ក៏ចិញ្ចឹមកូនរស់ដែរ ដូចពាក្យស្លោកលោកថា « ម៉ែមួយចិញ្ចឹមកូន ១០ រស់ តែកូន ១០ មិនងាយចិញ្ចឹមម៉ែ ១ រស់ទេ » ។ រឿងដែលពិបាក គឺការធ្វើឧបការគុណខាងផ្នែកជីវិត ខាងផ្នែកចិត្តគំនិត ការប្រព្រឹត្តិក្នុងសង្គម និងឧបការគុណខាងផ្នែកកិត្តិយសថ្លៃថ្នូរ អាចឱ្យកូននោះរស់ខ្លួនឯងបាន បន្ទាប់ពីលែងនៅក្នុងបន្ទុកឪពុកម្តាយហើយ ។ ធម្មតានៃច្បាប់

អាយុ ១៨ - ២០ ឆ្នាំ ម៉ែឪលែងទទួលខុសត្រូវហើយ កាលណាកូននោះធ្វើខុសនឹងច្បាប់ តែខ្មែរយើងភាគច្រើន ម៉ែឪឈប់ទទួលខុសត្រូវលើកូន នៅពេលដែលខ្លួនឯងបិទភ្នែកស្លាប់ ខ្លះក៏ថាបិទភ្នែកមិនជិតទៅទៀត បាល់តែគេបិទឱ្យ ព្រោះរវល់តែនឹងរឿងកូន ។ ខ្ញុំគិតថា បើធ្វើឧបការគុណដល់កូនឱ្យបានត្រឹមត្រូវតាំងពីដំបូងនោះ លុះកូនបានគូស្រករហើយ ម៉ែឪដូចជាអស់រវល់ហើយ អាចនឹងងាកមកសម្លឹងលើជីវិតខ្លួន រកធម៌ រកអាចិសម្រាប់អនាគតជាតិបានយ៉ាងស្រួល ។ រឿងនេះ អាចនឹងប្រព្រឹត្តទៅបាន បើមាតាបិតាធ្វើតាមពុទ្ធធម៌ ៥ ប្រការ ដូចតទៅនេះ :

## ១. ហាមប្រាមកូនកុំឱ្យធ្វើអំពើអាក្រក់

ម៉ែឪ បើមិនចង់ឱ្យពិបាកខ្លួនទៅថ្ងៃក្រោយ ត្រូវហាមប្រាមពន្យល់ ដឹកនាំលើកទឹកចិត្តកូនកុំឱ្យធ្វើអំពើអាក្រក់ ។ ឈ្មោះថាអំពើអាក្រក់ ឬបាប ពុំដែលឱ្យបុគ្គលណាបានសេចក្ដីសុខឡើយ ។ ផ្លូវដែលនឹងនាំឱ្យកូនធ្វើដំណើរឆ្ពោះទៅរកការវិនាសនោះ លោកហៅថា អបាយមុខ :

១.១. ជាអ្នកលេងស្រីញី រាប់ចាប់តាំងពីលេងស្រីពេស្យា កូនក្រមុំគេ ប្រពន្ធគេ ប្ដីគេជាដើម ។ បង្ហាញកូនឱ្យឃើញទោសដែលកើតពីការលេងស្រី ដូចជានាំឱ្យកើតកាមរោគ នាំឱ្យមានរឿងរ៉ាវ កើតគ្រោះថ្នាក់ដល់ខ្លួន ខានរៀន ខានសូត្រ ខូចអនាគត ខូចកេរ្តិ៍ឈ្មោះ ។ល។ ជាពិសេសក្នុងសម័យនេះ ការលេងស្រីអាចនឹងនាំឱ្យកើតរោគបិសាចដែលមិនអាចមើលជាបាន មានតែស្លាប់មួយ៉ាងគឺ រោគអេដស៍ (AIDS) ។

១.២. ជាអ្នកប្រព្រឹត្តក្នុងរឿងគ្រឿងញៀនស្រវឹង រាប់ចាប់តាំងពីស្រា

ទឹកត្នោតជូរ បារី កញ្ឆា អាភៀន ហេរ៉ូអ៊ីន ។ល។ ទោសរបស់គ្រឿងស្រវឹង មាន ច្រើនណាស់ ព្រះសម្មាសម្ពុទ្ធលោកបានលើកជាសង្ខេប ៦ យ៉ាងគឺ ៖ នាំឱ្យអស់ ទ្រព្យសម្បត្តិ, បង្កការជម្លោះវិវាទគ្នា, ជាប្រភពនៃរោគផ្សេងៗ មានរោគរបេង, រោគក្រពះ, រោគមហារីកចំពង់កជាដើម, នាំឱ្យខូចកេរ្តិ៍ឈ្មោះបោះសំឡេង, ធ្វើឱ្យ ទៅជាមនុស្សមិនចេះខ្មាសអៀន, និងធ្វើឱ្យសតិបញ្ញាចុះខ្សោយ ។ សព្វថ្ងៃនេះ អ្នក ដែលប្រព្រឹត្តអាភៀន ឬកញ្ឆា និងមានទោសដល់ជាប់ឃុំឃាំងទៀតផង។ អ្នកស្រវឹង ច្រើនតែវិនាសគ្រប់បែបយ៉ាង ព្រោះពេលស្រវឹង អ្នកនោះធូរស្រាល ដូចពាក្យថា *«ស្លាងតឹង ស្រវឹងធូរ»* បុរាណលោកថា ក្នុងស្រា ឬគ្រឿងស្រវឹងទាំងនោះមាន សុទ្ធតែប្រម៉ាត់សត្វគី ប្រម៉ាត់សត្វជ្រូក ( ស៊ីត្រង់ណាដេកត្រង់ហ្នឹង ) ប្រម៉ាត់សត្វខ្លា (កាចឃោរឃៅ) ប្រម៉ាត់សត្វសេក (ចេះតែនិយាយ) ប្រម៉ាត់សត្វឆ្កែ (ចោកចាប)។

១.៣. ជាអ្នកប្រព្រឹត្តក្នុងរឿងល្បែងស៊ីសង រាប់ចាប់តាំងពីបោះឡូ គប៉ាវង់ រហូតដល់បៀរប៉ោ ជាដើម ។ លោកបានសម្តែងទោសរបស់ល្បែងស៊ីសង ៦ យ៉ាងគឺ ពេលយើងឈ្នះ អ្នកចាញ់រមែងចងពៀរ ពេលចាញ់ក៏សោកស្តាយទ្រព្យ ដែលចាញ់ទៅ, អស់ទ្រព្យសម្បត្តិដែលសម្រាប់ចិញ្ចឹមជីវិតខ្លួន និងក្រុមគ្រួសារ, និយាយទៅរកអ្នកណាក៏គេមិនជឿ, មិត្តភក្តិមើលងាយមើលថោក, រកគូស្រករមិន ងាយបាន ព្រោះគេគិតថា អ្នកលេងល្បែងនឹងមិនអាចចិញ្ចឹមកូនគេឱ្យមានសុភ- មង្គលបាន ។ ការបណ្តែតបណ្តោយឱ្យកូនរៀនលេងល្បែងភ្នាល់ មិនជាការប្រសើរ សោះ ថ្វីត្បិតតែចាប់ផ្តើមតាំងពីលេងភ្នាល់ដាក់កៅស៊ូ ដាក់ជោះគ្នា ឬដាក់នំចំណី ក៏ដោយ ព្រោះនឹងនាំឱ្យកូនធ្លាប់ដៃ ។

១.៤. ចូលចិត្តដើរលេងពេលយប់អធ្រាត្រខុសពេលវេលា ដែលជាការនាំ

WAT KHEMARARATANARAM

ឱ្យកើតទោស ៦ យ៉ាងដែរគឺ : ឈ្មោះថាមិនចេះរក្សាខ្លួន, ឈ្មោះថាមិនចេះរក្សាកូនប្រពន្ធ, ឈ្មោះថាមិនចេះរក្សាទ្រព្យសម្បត្តិ ធ្វើឱ្យគេឯងសង្ស័យ, អាចឱ្យគេនិយាយដើម និយាយចចាមអារ៉ាមអាក្រក់ពីខ្លួន, ជាប្រភពនៃរឿងក្តៅក្រហាយជាច្រើន ។ មាតាបិតាគួរយល់ន័យពីការដើរលេងយប់ដោយសង្ខេបនេះផងចុះ ហើយណែនាំកូនកុំឱ្យប្រព្រឹត្ត ព្រោះជាប្រភពនៃសេចក្តីវិនាសដែរ ។

១.៥. ចូលចិត្តដើរលេងកំសាន្តតាមវង់តន្ត្រីរង្គសាល ល្ខោន កុន ហួសហេតុពេក ព្រោះជាហេតុឱ្យខូចពេលវេលាការងារ និងអាចនាំនូវទោសពៃរ៍ជាច្រើនទៀតផង ។

១.៦. ខ្ជិលច្រអូសក្នុងការងារ, ដោយអាងថា រងារណាស់ ក្តៅណាស់ ល្ងាចណាស់, នៅព្រឹកណាស់, ឃ្លានណាស់, ឆ្អែតណាស់, ហើយមិនធ្វើការ ។ ធម្មតាទ្រព្យសម្បត្តិ មិនអាចហូរចូលដល់បុគ្គលដែលជាអ្នកមានសេចក្តីខ្ជិលច្រអូសឡើយ ។ ត្រូវបង្ហឹកកូនឱ្យឧស្សាហ៍ រវៀសរវៃក្នុងការងារ មានចិត្តមានថ្លើមគ្រប់ការងារទាំងអស់ ។ មាតាបិតា អាចលើកឧទាហរណ៍ពីសត្វឃ្មុំ សត្វកណ្ដៀរ ដែលជាសត្វឧស្សាហ៍ក្នុងការងារដល់កូនបានផងដែរ ។

១.៧. សេពគប់មិត្តអាក្រក់ : រឿងសេពគប់មិត្តនេះ ជារឿងសំខាន់បំផុតក្នុងព្រះពុទ្ធសាសនា ។ ព្រះសម្មាសម្ពុទ្ធបានសំដែងអំពីការសេពគប់មិត្តអាក្រក់ថា *យាទិសំ កុរុតេ មិត្តំ យាទិសញ្ចូបសេវតិ សោបិ តាទិសកោ ហោតិ សហវាសោ ហិ តាទិសោ* = បុគ្គលយកជនបែបណាជាមិត្ត ទាំងចូលទៅសេពគប់នូវជនបែបណា គេក៏នឹងទៅជាជនបែបនោះដែរ ។

ឯការសេពគប់មិត្តអាក្រក់ ពុទ្ធភាសិតសំដែងថា « *ពូតិមច្ឆំ កុសគ្គេន*

*យោ នរោ ឧបនយ្ហតិ កុសាបិ បូតី វាយន្តិ ឯវំ ពាលូបសេវនា* = នរជនខ្ចប់ត្រីស្អុយដោយស្លឹកស្ដា នឹងនាំឱ្យស្លឹកស្ដាមានក្លិនស្អុយផ្សាយទៅ យ៉ាងណាមិញ ការចូលទៅសេពគប់នឹងជនពាល ក៏នឹងនាំឱ្យស្អុយខ្លួន ដូច្នោះដែរ ។

មិត្តអាក្រក់មាន ៤ ប្រភេទដែលមានលក្ខណៈសម្រាប់សំគាល់ដូចតទៅ ៖

*ក. មនុស្សគិតតែពីខាងបាន*

- គិតយកសម្រាប់តែម្នាក់ឯង
- ព្រមខាតប្រយោជន៍ តែបន្តិចបន្តួច និងតែងចង់បានតែពីខាងច្រើន
- ពេលខ្លួនមានភ័យ ទើបស្ទុះទៅជួយធ្វើកិច្ចរបស់មិត្ត
- សេពគប់មិត្ត ព្រោះសម្លឹងឃើញប្រយោជន៍

*ខ. មនុស្សបានតែខាងនិយាយ*

- ពូកែតែរំលើកយករឿងដែលអស់ហើយមកនិយាយ
- ពូកែលើកយករឿងដែលមិនទាន់មកដល់យកមកប្រាស្រ័យ
- ជួយសង្គ្រោះដោយរបស់គ្មានបានប្រយោជន៍
- ពេលមិត្តមានធុរៈ អាងលេសថាមានរវល់ ឬ មានកិច្ចអញ្ជេះអញ្ជុះជានិច្ច ។

*គ. មនុស្សប្រចុប*

- ពេលមិត្តធ្វើអាក្រក់ក៏សាទរ
- ពេលមិត្តធ្វើល្អក៏សាទរ
- នៅពីមុខមិត្ត ពោលសរសើរ
- នៅកំបាំងមុខមិត្ត ក៏រិះគន់និន្ទា

WAT KHEMARARATANARAM

*ឃ. មនុស្សនាំទៅរកតែរឿងវិនាស*

- ពេលមិត្តផឹកគ្រឿងស្រវឹង ក៏ផឹកជាមួយ
- ពេលមិត្តដើរលេងយប់ ក៏ដើរជាមួយ

មិត្តល្អ ៤ ប្រភេទ មានលក្ខណៈសម្រាប់សំគាល់ ដូចតទៅ ៖

*ក. មិត្តមានឧបការៈ*

- ពេលមិត្តប្រមាទ ក៏ជួយរក្សា
- ពេលមិត្តប្រមាទ ក៏ជួយរក្សាទ្រព្យសម្បត្តិឱ្យ
- ពេលមិត្តមានភ័យ ក៏យកខ្លួនឱ្យជាទីពឹងរបស់មិត្តបាន
- ពេលមិត្តមានការចាំបាច់ ជួយចេញទ្រព្យសម្បត្តិ ឱ្យច្រើនជាងមិត្តសុំឱ្យជួយទៅទៀត

*ខ. មិត្តរួមសុខរួមទុក្ខ*

- ប្រាប់រឿងសម្ងាត់ដល់មិត្ត
- បិទបាំងរឿងសម្ងាត់របស់មិត្ត
- ពេលមិត្តមានភ័យអន្តរាយ មិនលះបង់ចោល
- សូម្បីតែជីវិត ក៏អាចលះបង់បានដើម្បីមិត្ត

*គ. មិត្តណែនាំប្រយោជន៍*

- ឃើញមិត្តប្រុងធ្វើរឿងវិនាស ក៏ហាមប្រាម
- ណែនាំមិត្តឱ្យតាំងនៅក្នុងសេចក្តីល្អ
- ឱ្យមិត្តបានស្តាប់ បានដឹងនូវអ្វីដែលមិត្តមិនដែលបានស្តាប់
- ប្រាប់ផ្លូវទៅកាន់ស្ថានសួគ៌ដល់មិត្ត

*ឃ. មិត្តមានទឹកចិត្ត*

- ពេលមិត្តមានទុក្ខ ក៏កើតទុក្ខដែរ
- ពេលមិត្តបានសុខ ក៏សប្បាយរីករាយ
- ពេលគេតិះដៀលមិត្ត ក៏ជួយនិយាយការពារឱ្យ
- ពេលគេសរសើរមិត្ត ក៏ជួយនិយាយសរសើរបន្ថែម

មាតាបិតាត្រូវប្រុងប្រយ័ត្នឱ្យខ្លាំង ក្នុងការសេពគប់មិត្តរបស់កូន ព្រោះថាកូននឹងក្លាយទៅជាអ្នកលេងស្រី, អ្នកប្រព្រឹត្តក្នុងគ្រឿងញៀនស្រវឹង, អ្នកប្រព្រឹត្តល្បែងស៊ីសង, អ្នកដើរលេងយប់អធ្រាត្រខុសពេលវេលា, អ្នកដើរលេងតាមរោងល្ខោន រោងកុន រង្គសាល, និងជាអ្នកខ្ជិលច្រអូស ដែលបានរៀបរាប់រួចមកហើយ រួមទាំងសេចក្តីវិនាសផ្សេងៗ ដែលនឹងកើតឡើងដល់កូន ក៏ព្រោះតែការសេពគប់មិត្តនេះឯង ។ ការបានណែនាំគ្នាកុំឱ្យប្រព្រឹត្តអំពើអាក្រក់ដូចដែលបានរៀបរាប់មកនេះ ឈ្មោះថា មាតាបិតាបានធ្វើឧបការគុណទី ១ ដល់កូនហើយ ។

## ២. ដឹកនាំកូនឱ្យតាំងមាំនៅក្នុងអំពើល្អ

មាតាបិតាត្រូវដឹកនាំកូនឱ្យតាំងមាំនៅក្នុងអំពើល្អ ។ ការមិនធ្វើអំពើអាក្រក់មិនទាន់គ្រប់គ្រាន់ទេ ត្រូវព្យាយាមដឹកនាំកូនឱ្យធ្វើល្អថែមទៀត ។ អំពើល្អដែលមាតាបិតាគប្បីដឹកនាំឱ្យកូនធ្វើនោះ មាន ៖

*១.២. ឱ្យកូនតាំងមាំនៅក្នុងកុសលកម្មបថ ១០ យ៉ាង*

កុសលកម្មបថ ប្រែថា អំពើល្អដែលជាផ្លូវនាំទៅរកសេចក្តីសុខ សេចក្តីចម្រើន និងសុគតិ,

- លះបង់ការកាប់សម្លាប់ ឬ អំពើឃោរឃៅ និងមានមេត្តា ករុណា ជួយ

សង្គ្រោះគ្នាទៅវិញទៅមក,

- លះបង់ការបៀតបៀនទ្រព្យសម្បត្តិ និងគោរពកម្មសិទ្ធិទ្រព្យសម្បត្តិរបស់អ្នកដទៃ,
- លះបង់ការប្រព្រឹត្តខុសក្នុងកាម មានលួចប្រពន្ធប្ដីគេ ជាដើម និងមិនល្មើសលើប្រពៃណីខាងភេទ,
- លះបង់ការនិយាយកុហក ភូតភរ បញ្ឆោត និយាយតែពាក្យសច្ចៈ ពាក្យពិត ពាក្យត្រង់,
- លះបង់ការស៊កសៀត បញ្ឆី ដែលធ្វើឱ្យគេបែកបាក់គ្នា និងជួយនិយាយឱ្យគេមានការស្ម័គ្រស្មាគមសាមគ្គីគ្នា,
- លះបង់ការនិយាយពាក្យអាក្រក់ ពាក្យថោកទាប និយាយតែពាក្យសុភាពផ្អែមល្ហែម,
- លះបង់ការនិយាយពាក្យផ្ដេសផ្ដាស គ្មានប្រយោជន៍ និងត្រូវតាមកាលៈទេសៈ,
- មិនរំពឹងសម្លឹងចង់បានទ្រព្យសម្បត្តិអ្នកដទៃ,
- មិនមានចិត្តឃោរឃៅ បៀតបៀនគេ គិតប្រាថ្នាតែឱ្យគេបានសុខ កុំឱ្យគេមានពៀរវេរា កុំឱ្យគេបៀតបៀនគ្នា កុំឱ្យគេមានទុក្ខ មានតែសុខ,
- មានការយល់ត្រឹមត្រូវ មានសម្មាទិដ្ឋិ ដូចជាយល់ថា ទានមានផល ការបូជាមានផល ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ជាដើម ។

*២.២- ឱ្យកូនតាំងមាំនៅក្នុងការធ្វើបុណ្យ*

បុណ្យក៏ប្រែថាសេចក្ដីល្អ ជារង្វាស់សម្រាប់វាស់មនុស្សថាល្អ ឬអាក្រក់ ។

សេចក្ដីល្អនេះ អាចកើតឡើងបានអាស្រ័យដោយមធ្យោបាយ ១០ យ៉ាង ដែរលោកហៅថា បុញ្ញកិរិយាវត្ថុ ១០ យ៉ាងគឺ ៖

១. *ទានមយៈ* ធ្វើបុណ្យដោយការធ្វើទាន ចែងចែកអ្វីដែលខ្លួនមាន ឱ្យទៅជាប្រយោជន៍ដល់ជនដទៃ,

២. *សីលមយៈ* ធ្វើបុណ្យដោយការរក្សាសីល ប្រព្រឹត្តល្អ គោរពច្បាប់ ( សូមមើលសីលភាវនាផងចុះ ),

៣. *ភាវនាមយៈ* ធ្វើបុណ្យដោយធ្វើភាវនា គឺហ្វឹកហាត់ អប់រំចិត្ត ធ្វើសមាធិ

៤. *អបចាយនមយៈ* ធ្វើបុណ្យដោយការប្រព្រឹត្តខ្លួនឱ្យទន់ភ្លន់ ស្គាល់ខ្ពស់ ស្គាល់ទាប មិនអាក្រក់ ក្រមិក្រមើ ស្គាល់ចាស់ទុំ,

៥. *វេយ្យាវច្ចមយៈ* ធ្វើបុណ្យដោយការខ្វល់ខ្វាយ ជួយធ្វើការ ក្នុងការងារ ធុរកិច្ចរបស់អ្នកដទៃ,

៦. *បត្តិទានមយៈ* ធ្វើបុណ្យដោយការចែងចែកសេចក្ដីល្អ ចែងចែកបុណ្យដល់អ្នកដទៃ,

៧. *បត្តានុមោទនាមយៈ* ធ្វើបុណ្យដោយការត្រេកអរ រីករាយសាទរចំពោះសេចក្ដីល្អរបស់អ្នកដទៃ,

៨. *ធម្មស្សវនមយៈ* ធ្វើបុណ្យដោយការស្ដាប់ធម៌ សិក្សារកការចេះដឹងដែលអាចឱ្យជីវិតមានសេចក្ដីសុខ,

៩. *ធម្មទេសនាមយៈ* ធ្វើបុណ្យដោយការប្រៀនប្រដៅធម៌ បង្ហាញសច្ចធម៌ឱ្យអ្នកដទៃបានឃើញ,

*១០. ទិដ្ឋុជុកម្ម៖ ធ្វើបុណ្យដោយការធ្វើ ការយល់ឃើញទស្សនៈរបស់ខ្លួន ឱ្យបានល្អត្រឹមត្រូវ ។*

### *៣.២. ឱ្យកូនក្លាយទៅជាមនុស្សដែលសង្គមរាប់អាន*

មិនយូរទេ ដែលកូនយើងនឹងត្រូវចេញទៅទាក់ទងជាមួយសង្គម ដូច្នេះ មាតាបិតា ត្រូវត្រៀមកូនឱ្យចេះរបៀបរបបក្នុងសង្គម និងវិធីជីវិតដែលសង្គមនោះរាប់អាន គឺឱ្យកូន « ចូលសង្គមគេចុះ » និង « មិនឃ្លើយសង្គម » ដែលយើងចំណាំនិយាយនោះឯង ។ ប្រពៃណី វប្បធម៌ខ្មែរយើងអប់រំកូនដោយចាប់ផ្ដើមតាំងពីចេះសំពះ ចេះថ្វាយបង្គំ គោរពចាស់ទុំ គោរពស្ត្រីភេទ ទន់ភ្លន់ ស្គាល់មីងមា បងប្អូន ជីដូនជីតា កូនចៅ សាច់ញាតិ ព្រៀងឈាន ។ ល ។ ក្នុងព្រះពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធលោកបានបង្ហាញពីគោលបដិបត្តិសម្រាប់រស់នៅក្នុងសង្គមជាច្រើន ។ ដែលល្បីជាងគេនោះ គឺការដែលលោកប្រៀបធៀបបុគ្គលដែលយើងត្រូវរស់នៅជាមួយទាំងនោះ ដូចជាទិសទាំង ៦ ដែលយើងត្រូវបែរទៅរកជារៀងរាល់ថ្ងៃ គឺទិសលើ ទិសក្រោម ទិសជើង ទិសត្បូង ទិសលិច និងទិសខាងកើត ។



គោលបដិបត្តិ ឬទិសម្រាប់រស់នៅក្នុងសង្គមតាមសិង្គាលោវាទសូត្រគឺ

• បុរត្ថិមទិស ( ខាងកើត ) ទុកជាមាតាបិតា

*- បុត្រធីតាត្រូវចិញ្ចឹមបំរុងលោក ដោយស្ថានធម៌ ៥ យ៉ាង :*

ក) ចិញ្ចឹមបីបាច់ថែរក្សាលោកដូចដែលលោកបានចិញ្ចឹមយើង

ខ) ជួយធ្វើកិច្ចការងាររបស់លោក

គ) ចិញ្ចឹមបំរុងវង្សត្រកូលមិនឱ្យសាបសូន្យ

ឃ) ធ្វើឱ្យសក្តិសមជាអ្នកទទួលទ្រព្យមរតក និងជាអ្នកបន្តវង្សត្រកូល

ង) ពេលលោកមរណភាពហើយ ធ្វើបុណ្យឧទ្ទិសជូនលោក

*- មាតាបិតាត្រូវសង្គ្រោះបុត្រ ដោយស្ថានធម៌ ៥ យ៉ាង :*

ក) ហាមមិនឱ្យកូនធ្វើអាក្រក់

ខ) ឱ្យកូនតាំងនៅក្នុងសេចក្តីល្អ

គ) ឱ្យកូនបានសិក្សារៀនសូត្រ

ឃ) រៀបចំទុកដាក់ឱ្យកូនមានគូស្រករ ផ្គះផ្គង

ង) ចែកទ្រព្យមរតកឱ្យកូនក្នុងឱកាសដែលសមគួរ

• ទក្ខិណទិស ( ខាងត្បូង ) ទុកជាគ្រូអាចារ្យ

*- សិស្សត្រូវប្រតិបត្តិចំពោះគ្រូ ដោយស្ថានធម៌ ៥ យ៉ាង :*

ក) ក្រោកឈរទទួល ពេលគ្រូដើរចូលមក

ខ) ចូលទៅរកគ្រូ ដើម្បីបំរុងចំពី ប្រឹក្សា សាកសួរ និងសុំឱវាទជាដើម

គ) តាំងចិត្តរៀន មានចិត្តស្រឡាញ់ រៀនដោយសទ្ធា ចេះស្តាប់ឱ្យកើតបញ្ញា ។

ឃ) ប្រណិបត្តិ ឧបដ្ឋាកចំពីរលោក,

ង) រៀនសិល្បៈវិទ្យាដោយគោរព មិនលះបង់ មិនខ្ជិលច្រអូស

*. គ្រូអាចារ្យត្រូវអនុគ្រោះសិស្ស ដោយស្ថានធម៌ ៥ យ៉ាង*

ក) ហ្វឹកហាត់ណែនាំសិស្សឱ្យទៅជាមនុស្សល្អ

ខ) បង្រៀនសិស្សឱ្យយល់ច្បាស់ យល់ត្រឹមត្រូវ

គ) បង្រៀនសិល្បៈដល់សិស្សឱ្យអស់មិនលាក់ចំណេះទុក

ឃ) លើកតម្កើងសិស្សក្នុងទីចំពោះមុខមិត្ត ក្រុម ប្រជុំជន សង្គម

ង) សាងគ្រឿងការពារភ័យដល់សិស្សនៅគ្រប់ទិសទី គឺបង្វឹកបង្រៀនឱ្យចេះចិញ្ចឹមជីវិត រក្សាខ្លួន ក្នុងការដែលសិស្សនឹងចេញទៅកសាងជីវិត ក្នុងសង្គមតទៅឱ្យបានប្រសើរ ។

• **បច្ឆិមទិស** ( ខាងលិច ) ទុកជាភរិយា

*. ស្វាមីត្រូវទំនុកបំរុង ដោយស្ថានធម៌ ៥ យ៉ាង :*

ក) លើកតម្កើង ផ្ដល់កិត្តិយសឱ្យសមឋានៈជាភរិយាខ្លួន

ខ) មិនប្រមាថមើលងាយ

គ) មិនក្បត់ចិត្ត

ឃ) ប្រគល់ភារៈជាធំក្នុងផ្ទះ

ង) រកគ្រឿងប្រដាប់តុបតែងមកឱ្យជារង្វាន់ ជាកាដូតាមឱកាស

*. ភរិយាត្រូវប្រតិបត្តិស្វាមីដោយស្ថានធម៌ ៥ យ៉ាង :*

ក) ចាត់ចែងការងារក្នុងផ្ទះឱ្យល្អរៀបរយ

ខ) សង្គ្រោះញាតិមិត្តទាំងសងខាងដោយល្អ

គ) មិនក្បត់ចិត្តស្វាមី

ឃ) រក្សាទ្រព្យសម្បត្តិដែលរកបានមក

ង) ឧស្សាហ៍ ព្យាយាម មិនខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង

• ឧត្តរទិស ( ខាងជើង ) ទុកជាមិត្ត

*. កុលបុត្រត្រូវទំនុកបំរុងមិត្ត ដោយស្ថានធម៌ ៥ យ៉ាង :*

ក) ចែកចាយរបស់ដែលសមគួរឱ្យដល់មិត្ត

ខ) ពោលពាក្យពិរោះផ្អែមល្ហែម

គ) ជួយសង្គ្រោះគ្នាទៅវិញទៅមក

ឃ) ជាអ្នកមានខ្លួនស្មើនឹងមិត្ត រួមសុខរួមទុក្ខជាមួយ

ង) ស្មោះត្រង់ មានសច្ចៈជាមួយគ្នា

*- មិត្តត្រូវតបស្នងដល់កុលបុត្រវិញ ដោយស្ថានធម៌ ៥ យ៉ាង :*

ក) ពេលកុលបុត្រប្រមាទ ជួយរក្សាការពារ

ខ) ពេលកុលបុត្រប្រមាទ ជួយរក្សាទ្រព្យសម្បត្តិឱ្យ

គ) ពេលកុលបុត្រមានភ័យ អាចយកខ្លួនជាទីពឹងបាន

ឃ) មិនលះបង់ចោល ពេលមានទុក្ខលំបាក

ង) រាប់អានរហូតដល់វង្សត្រកូលរបស់កុលបុត្រ

• ហេដ្ឋិមទិស ( ទិសខាងក្រោម ) ទុកជាកម្មករ

*. នាយចៅហ្វាយ គប្បីទំនុកបំរុងកម្មករខ្លួនដោយស្ថានធម៌ ៥ យ៉ាង*

ក) ចាត់ចែងការឱ្យធ្វើតាមសមគួរដោយកម្លាំង និងសមត្ថភាព

ខ) អោយរង្វាន់ បៀវត្ស សមគួរដល់ការងារ និងការរស់នៅ

គ) ជួយរក្សា ព្យាបាល ថែរក្សា ពេលមានជំងឺ

ឃ) បានរបស់ប្លែកៗពិសេសមក ក៏ចែកឱ្យ

ង) អោយមានថ្ងៃឈប់សំរាក និងវិស្សមកាលតាមឱកាសសមគួរ

- *កម្មករត្រូវអនុគ្រោះនាយខ្លួន ដោយស្ថានធម៌ ៥ យ៉ាង :*

ក) ផ្តើមធ្វើការងារ មុននាយចៅហ្វាយ

ខ) សម្រាកការងារ ក្រោយនាយចៅហ្វាយ

គ) កាន់យកតែរបស់ដែលនាយចៅហ្វាយអោយ

ឃ) ធ្វើការងារដោយយកចិត្តទុកដាក់ និងអោយរឹតតែប្រសើរឡើង

ង) នាំកិត្តិគុណរបស់ចៅហ្វាយនាយទៅផ្សព្វផ្សាយ

- **ឧបរិមទិស** ( ខាងលើ ) ទុកជាសមណព្រាហ្មណ៍ ព្រះសង្ឃ

- *គ្រហស្ថគប្បីទំនុកបំរុងព្រះសង្ឃ ដោយស្ថានធម៌ ៥ យ៉ាង :*

ក) ធ្វើអ្វីៗ ក៏ធ្វើដោយមេត្តាចិត្ត

ខ) និយាយអ្វីៗ ក៏និយាយដោយមេត្តាចិត្ត

គ) គិតធ្វើអ្វីៗ ក៏គិតដោយមេត្តាចិត្ត

ឃ) ទទួលយកដោយសេចក្តីពេញចិត្ត

ង) ឧបត្ថម្ភលោកដោយបច្ច័យ ៤

- *ព្រះសង្ឃគប្បីអនុគ្រោះគ្រហស្ថ ដោយស្ថានធម៌ ៦ យ៉ាង :*

ក) ហាមប្រាមមិនឱ្យធ្វើអាក្រក់

ខ) ណែនាំឱ្យតាំងនៅក្នុងសេចក្តីល្អ

គ) អនុគ្រោះដោយទឹកចិត្តល្អ

ឃ) ឱ្យបានស្តាប់ធម៌ដែលមិនធ្លាប់បានស្តាប់

ង) ធម៌ណាដែលធ្លាប់ស្តាប់ហើយ ពន្យល់ឱ្យរឹតតែយល់ច្បាស់ឡើង

ច) ប្រាប់ផ្លូវស្ថានសួគ៌ គឺផ្លូវជីវិតដែលមានសេចក្តីសុខ សេចក្តីចំរើនឱ្យដល់គ្រហស្ថ ។

*មនុស្សជាសត្វសង្គម រស់នៅក្នុងសង្គម មានឥទ្ធិពលលើសង្គម និងទទួលឥទ្ធិពលពីសង្គមគ្រប់ពេលវេលា ។ សង្គមនឹងទៅជាសង្គមល្អ ក៏ព្រោះមនុស្សក្នុងសង្គមជាមនុស្សល្អដែរ* ។ មាតាបិតាដែលបានជួយឱ្យកូនចេះរស់នៅក្នុងសង្គម ក៏ឈ្មោះថាជួយស្ថាបនានៅក្នុងសង្គមដែរ ។ ការជួយនេះ គឺការជួយអោយកូនបំពេញករណីយកិច្ចទៅតាមឋានៈរបស់ខ្លួននេះឯង ។ មនុស្សម្នាក់ៗ មានស្ថានភាពច្រើនណាស់ ដូចដែលមាននៅក្នុងសិង្គាលោវាទសូត្រហើយ គឺ បើអ្នកនៅចំពោះមុខឪពុកម្តាយ គឺអ្នកជាកូន, បើអ្នកនៅពីមុខកូន អ្នកជាមាតាបិតា, បើនៅពីមុខគ្រូ អ្នកជាសិស្ស, បើនៅពីមុខសិស្ស អ្នកជាគ្រូ, បើនៅពីមុខគូស្រករ អ្នកជាស្វាមី ឬភរិយា, បើនៅពីមុខចៅហ្វាយ អ្នកជាកម្មករ, បើនៅពីមុខកម្មករ អ្នកជាចៅហ្វាយ, បើនៅពីមុខព្រះសង្ឃ អ្នកជាគ្រហស្ថ ជាឧបាសក ឧបាសិកា បើនៅពីមុខឧបាសក ឧបាសិកា គឺព្រះសង្ឃ ។ ការផ្លាស់ស្ថានភាពរបស់ខ្លួនភ្លាមៗនេះ ធ្វើឱ្យបុគ្គលម្នាក់ៗមិនអាចបំពេញនាទីខ្លួន អោយបានត្រឹមត្រូវទាំងអស់ទេ បើសិនជាមិនបានទទួលការអប់រំ ។ ដូច្នេះការបដិបត្តិតាមគោលទិសទាំង ៦ នេះ ត្រូវហ្វឹកហាត់តាំងពីតូច និងត្រូវមានការអត់ធន់ ដើម្បីអោយកូន ឬខ្លួនបានទៅជាមនុស្សល្អឡើង ។

*ក្នុងព្រះពុទ្ធសាសនា ការបំពេញនាទីរបស់ខ្លួនទៅតាមស្ថានភាពដែលខ្លួនមាន ឱ្យបានត្រឹមត្រូវ នេះលោកហៅថា ការបដិបត្តិធម៌ ។*

### ៤.២. អោយកូនក្លាយទៅជាពលរដ្ឋល្អ

ស្ថានភាពចុងក្រោយរបស់មនុស្សក្នុងឋានៈជាសមាជិកសង្គម គឺឋានៈជាពលរដ្ឋរបស់ប្រទេស ។ មាតាបិតាភាគច្រើន ពុំសូវយកចិត្តទុកដាក់ចំពោះស្ថានភាពនេះឡើយ ដែលជាហេតុធ្វើឱ្យកូនពុំសូវយកចិត្តដាក់បំពេញនាទីខ្លួន ឱ្យបានគ្រប់គ្រាន់ ។ នាទីក្នុងឋានៈជាពលរដ្ឋ ដែលគួរបណ្ដុះឱ្យកូនមាន :

- គោរពច្បាប់ប្រទេស
- គោរពសិទ្ធិមនុស្ស
- គោរពមតិអ្នកដទៃ
- ចូលធ្វើយោធា ពេលអាយុដល់កំណត់
- បង់ពន្ធភាស៊ី អាករជូនរដ្ឋ
- ចូលរួមក្នុងការជ្រើសរើសអ្នកគ្រប់គ្រង ដែលមានសមត្ថភាព និងគុណធម៌
- មិនបង្ករឿងក្ដៅក្រហាយដល់អ្នកដទៃ
- រួមចំណែកក្នុងការកសាងប្រទេស កសាងសង្គម ភូមិស្រុក
- មានភក្ដីភាពចំពោះប្រទេស ជាតិនិយម

- ការពារផលប្រយោជន៍ប្រទេសជាតិ សម្បត្តិសាធារណៈ
- រកស៊ីចិញ្ចឹមជីវិតត្រឹមត្រូវ
- គោរពរាប់អានជនបរទេស ដែលចូលមកទស្សនាប្រទេសខ្លួន ដោយស្មោះស្ម័គ្រ មិនអោយគេមើលងាយវប្បធម៌ខ្លួន
- រក្សាវប្បធម៌ជាតិ ព្រោះវប្បធម៌ជាគ្រឿងសំគាល់របស់ជាតិ
- ផ្សព្វផ្សាយកិត្តិយសរបស់ប្រទេសជាតិអោយសុះសាយ
- ប្រើប្រាស់ទ្រព្យធម្មជាតិ និងទ្រព្យសម្បត្តិដោយសន្សំសំចៃ
- តាមគន្លងសុភាសិត « *លះបង់ភូមិដើម្បីរក្សាស្រុក លះបង់ស្រុកដើម្បីរក្សាខេត្ត លះបង់ជីវិតដើម្បីរក្សាប្រទេស* » ។

ខ្ញុំគិតថា ចំណុចដែលមាតាបិតា ត្រូវដឹកនាំឱ្យកូនតាំងនៅក្នុងសេចក្ដីល្អទាំង៤ គឺ : ឱ្យកូនតាំងនៅក្នុងកុសលកម្មបថ ១, ឱ្យតាំងនៅក្នុងបុញ្ញកិរិយាវត្ថុ ១០, ឱ្យកូនចូលសង្គមគេចុះ និងឱ្យទៅជាពលរដ្ឋល្អនេះ ប្រាកដជាគ្រប់គ្រាន់គួរសមហើយ ក្នុងឋានៈជាឧបការបុគ្គលដែលគប្បីធ្វើចំពោះកូន ។ សូមអ្នកជាមាតាបិតា ចាំសុភាសិតខ្មែរមួយឃ្លាថា :

> « *នឹងធ្វើយថ្វីតផង កូនសោតវង្វេងក្រោះថ្វីតមេបា*
> *មិនបានប្រដៅឱ្យលុះធម្មា អ្នកផងនិន្ទាថាកូនឥតពូជ* » ។

# ៣ - ឱ្យកូនសិក្សារៀនសូត្រ

ក្នុងមង្គលសូត្រ ដែលជាសូត្រនិយាយអំពីអ្វីជាមង្គល ចំនួន ៣៨ ប្រការ ព្រះសម្មាសម្ពុទ្ធបានសំដែងអំពីការសិក្សា នេះថា ៖

*បាហុសច្ចញ្ច សិប្បញ្ច  វិនយោ ច សុសិក្ខិតោ*

*សុភាសិតា ច យា វាចា  ឯតម្មង្គលមុត្តមំ ។*

បានរៀនសិក្សាចេះដឹងជ្រៅជ្រះមួយ មានសិល្បៈវិទ្យា បច្ចេកទេសក្នុងអាជីពរបស់ខ្លួនមួយ មានរបៀបវិន័យ បានហ្វឹកហាត់អប់រំខ្លួនបានល្អមួយ និយាយពាក្យដែលនាំឱ្យកើតផលល្អមួយ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។ មនុស្សឥតវិជ្ជា លោកទុកថាជាមនុស្សខ្វាក់ ។ វិជ្ជាចោរលួចយកមិនបាន ភ្លើងឆេះមិនដល់ ។ ឈ្មោះថាវិជ្ជា បើសិក្សាបានល្អហើយ រមែងនាំនូវប្រយោជន៍មកឱ្យជាមិនខាន ។

វិជ្ជាមាន ២ ប្រភេទ គឺវិជ្ជាផ្លូវលោក និងវិជ្ជាផ្លូវធម៌ ។ ទាំង ២ នេះ មាតាបិតា ត្រូវឱ្យកូនបានសិក្សាដោយព្រមព្រៀង ព្រោះផ្លូវលោកសម្រាប់ចិញ្ចឹមជីវិត រាងកាយឱ្យរស់ ឯវិជ្ជាផ្លូវធម៌ សម្រាប់ចិញ្ចឹមព្រលឹងវិញ្ញាណ ចិត្ត ឱ្យរស់ ឱ្យទៅជាមនុស្សល្អក្នុងសង្គម ។ មាតាបិតាណា មិនឱ្យកូនរៀនសូត្រ ឈ្មោះថាជាសត្រូវរបស់កូន ។ ព្រោះអ្នកនឹងមិនមានអ្វីចែកឱ្យកូនបានល្អជាងចែកចំណេះវិជ្ជាទេ ។ ខ្ញុំចាំជានិច្ចកាលដែលនៅពីក្មេង បិតាខ្ញុំតែងដាស់តឿនថា « *ខំរៀនទៅកូន ព្រោះពុកពុំមានទ្រព្យសម្បត្តិ កេរ្តិ៍អាករអ្វីចែកឱ្យកូនទេ មានតែការសិក្សានេះឯង* » ។ ខ្ញុំចាំបណ្តាំនេះជានិច្ច ឥឡូវនេះខ្ញុំជឿថា ខ្លួនខ្ញុំអាចរស់ខ្លួនឯងបាន មិនចាំបាច់គាត់ចែកទ្រព្យសម្បត្តិអ្វីឱ្យខ្ញុំទៀតទេ ។

## ៤. រៀបចំទុកដាក់កូនឱ្យមានគូស្រករ ផ្ទះសម្បែង

គឺជារឿងធម្មជាតិរបស់សព្វសត្វ ដែលនៅពេលថ្ងៃណាមួយ គេត្រូវបែកចេញពីមាតាបិតា ដើម្បីរស់នៅជាមួយគូស្នេហារបស់គេ ។ គ្មានអ្នកណាម្នាក់អាចបង្ខាំង ឬរាំងនូវតណ្ហារបស់សត្វបានឡើយ.។ កាលពីជំពូកដំបូង យើងបានឃើញហើយនូវកត្តាពិចារណារបស់គូអាពាហ៍ពិពាហ៍ទៅលើអ្នកម្ខាងទៀត មុននឹងសម្រេចចិត្តថា តើគួរនឹងរស់នៅជាមួយគ្នាបាន ឬទេ ? ក្នុងសង្គមទំនើបទាំងឡាយ មានអឺរ៉ុប ឬ សូម្បីតែថៃនេះក៏ដោយ ក៏ការរួមរស់នៅជាមួយគ្នាក្នុងឋានៈជាស្វាមីភរិយាហាក់ដូចជាលែងសូវត្រូវការយោបល់ ឬការចាត់ចែងពីមាតាបិតាហើយ គឺភាគច្រើន បើគេមានចិត្តស្រឡាញ់គ្នា ក៏រស់នៅជាមួយគ្នា ដោយមិនបាច់រៀបការ ឬមិនបាច់ចុះសំបុត្ររៀបអាពាហ៍ពិពាហ៍ក៏មាន ឬជួនកាលចុះសំបុត្រអាពាហ៍ពិពាហ៍ហើយ ទើបនាំគ្នាទៅសំពះសួរម៉ែឪក៏មាន ។ ឬបើទោះបីជាការចូលស្តីដណ្តឹងតាមប្រពៃណីក៏ដោយ ក៏ការសម្រេចចិត្តជាច្រើនស្ថិតនៅលើសាមីខ្លួន ។ ឯមាតាបិតាគ្រាន់តែជាអ្នកមានយោបល់ ឬផ្តល់ដំណឹងប៉ុណ្ណោះ ហាក់ដូចជាពុំសូវមានឥទ្ធិពលប៉ុន្មានទៅលើកូនទេ ។ ទាំងនេះ គឺជាឥទ្ធិពលនៃវប្បធម៌អឺរ៉ុប និងការធានាពីច្បាប់រដ្ឋដែលថា អ្នកណាសម្រេចនីតិភាវៈ គឺដឹងក្តីចាប់ពីអាយុ ១៨ ឬ ២០ ឆ្នាំហើយ អាចសម្រេចវាសនាជីវិតខ្លួនបានដោយខ្លួនឯង និងចេញពីបន្ទុកមាតាបិតាបាន ។

តែទោះជាយ៉ាងណាក៏ដោយ ម៉ែឪត្រូវទទួលស្គាល់ថា កូនត្រូវតែមានគូស្រករ ។ ដូច្នេះ ក៏គួររៀបដំណើរឱ្យកូនទៅដោយឈរលើការផ្តល់យោបល់ ផ្តល់ដំណឹង បង្ហាញហេតុផល ឯការសម្រេចចិត្តគួរតែឱ្យទៅកូនចុះ ។ បើកូនថាស្រេចតែម៉ែឪ ក៏គួរផ្តល់ដំណឹងពីកូនប្រសារឱ្យបានច្រើន តាមដែលអាចប្រាប់បានដែរ ។ គំនិត

« *ទឹកមិនធំជាងនាវា* » គួរតែឈប់ប្រើបានហើយ ក្នុងករណីរើសកូនប្រសារ ។ ចូរគិតថា « *អ្នកដែលទទួលសុខទុក្ខពិតប្រាកដ គឺកូនរបស់យើង* » ឯមាតាបិតា បើនឹងទុក្ខ ក៏ជាទុក្ខកំរិតទី ២ មិនមែនទី ១ ទេ ។ មាតាបិតា គួរពិនិត្យមើលអនាគតកូនប្រសារលើចំណុចសមសទ្ធា សមសីលា សមចាគា សមបញ្ញា ព្រមទាំងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍របស់បុរស-ស្ត្រី ដែលបានអធិប្បាយរួចមកហើយនោះផងចុះ ។

## ៥. ចែកទ្រព្យមរតកឱ្យដល់កូនក្នុងឱកាសដែលសមគួរ

យើងមកដល់ឧបការគុណចំណុចទី ៤ ដែលជាចំណុចចុងក្រោយ របស់មាតាបិតាហើយ ។ តែកាលណានិយាយពីរឿងទ្រព្យសម្បត្តិ រឿងមាសប្រាក់ លុយកាក់ គឺបានន័យថា កំពុងនិយាយពីបញ្ហាដែលស្មុគស្មាញជាទីបំផុត និងគួរឱ្យព្រួយបារម្ភជាទីបំផុត ។ ព្រះតេជព្រះគុណអធិបតីសង្ឃ សាយធូ សិរីសុវណ្ណោ *ពិន សែម* លោកតែងមានថេរដីកាដាស់តឿនភិក្ខុ . សាមណេរ និងបរិស័ទជារឿយៗថា «*ប្រយ័ត្នទ្រព្យឯងខុះស្នែងចាក់ម្ចាស់* » ។ រឿងនេះ ជាការពិតណាស់ មាតាបិតាជាច្រើន ខិតខំរកទ្រព្យសម្បត្តិដោយមិនខ្លាចបាប ដើម្បីទុកចែកឱ្យកូន តែទ្រព្យនោះច្រើនតែបង្កទុក្ខឱ្យលោកវិញសឹងតែគ្រប់គ្នា *កូនឈ្លោះ : ព្រោះចែកចំណែន, បានតិចបានច្រើន, កាប់សម្លាប់គ្នាដើម្បីឱ្យសល់សមាជិកតិចក្នុងការទទួលទ្រព្យ, កូនខ្លះរហូតដល់ទៅបន់ឪពុកម្តាយខ្លួនឱ្យរហ័សស្លាប់ ដើម្បីឆាប់បានកេរ្តិ៍, ហើយខ្លះរហូតដល់ទៅធ្វើមាតុឃាត និងបិតុឃាតទៀតផងក៏មាន* ។

ក្នុងប្រវត្តិសាស្ត្រព្រះពុទ្ធសាសនា ព្រះបាទអជាតសត្រូវ ក៏បានសម្លាប់បិតាខ្លួនដើម្បីគ្រងរាជ្យដែរ ។ ដូច្នេះ ពាក្យដែលថា ¯ចែកតាមឱកាសដ៏សមគួរនេះ ទើប

ជាពាក្យត្រឹមត្រូវណាស់សម្រាប់ឱ្យមាតាបិតាពិចារណាថា កាលណាគួរ កាលណាមិនគួរនឹងចែកឱ្យកូន ។

ក្នុងពុទ្ធប្រវត្តិ ពេលដែលនាង *ពិម្ពាយសោធរា* ជាអតីតមហេសីរបស់ *ព្រះសិទ្ធត្ថ* ( ព្រះនាមព្រះពុទ្ធមុនត្រាស់ដឹង ) ប្រើរាហុលកុមារ ដែលជាបុត្ររបស់ព្រះនាងឱ្យទៅសុំទ្រព្យពីព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គទ្រង់ពិចារណាថា ធម្មតាទ្រព្យជារបស់ខាងក្រៅ មានមាសពេជ្រកែវកងជាដើមនេះ ជារបស់មិនទៀង ប្រើអស់ ងាយរលាយសាបសូន្យ មិនគួរណានឹងផ្តល់ឱ្យ *រាហុល* ទេ ។ ទើបព្រះអង្គបានប្រទានអរិយទ្រព្យ ៧ ប្រការនោះគឺ ៖

១. *សទ្ធា* ការជឿដែលមានហេតុផល ជឿកម្មផល

២. *សីលៈ* ការរក្សាកាយវាចាឱ្យរៀបរយ ប្រព្រឹត្តត្រឹមត្រូវល្អ

៣. *ហិរិ* ការខ្មាសអៀនចំពោះការធ្វើបាបទាំងពួង

៤. *ឱត្តប្បៈ ការខ្លាចក្រែងមិនហ៊ានធ្វើបាប ខ្លាចបាប*

៥. *ពាហុសច្ចៈ* ការដែលបានសិក្សា រៀនសូត្រច្រើន

៦. *ចាគៈ* លះបង់ ចិត្តល្អ ចិត្តទូលាយ

៧. *បញ្ញា* ការដឹង ការយល់ដឹច្បាស់លាស់ក្នុងហេតុ ក្នុងផលល្អ អាក្រក់ ខុសត្រូវ គុណទោស មានប្រយោជន៍មិនមានប្រយោជន៍ ចេះគិត ចេះពិចារណា ចេះធ្វើ

អរិយទ្រព្យទាំង ៧ នេះ លោកហៅថា ពហុបការធម៌ គឺធម៌ដែលមានឧបការគុណច្រើន ។ អ្នកដែលមានទ្រព្យទាំង ៧ នេះ រមែងមិនក្រ មិនលំបាក មិនវេទនា មិនក្តៅក្រហាយ មិនធ្លាក់នរក ។ ទ្រព្យនេះ បើចែកឱ្យកូន នឹងផ្តល់សុខ

ឱ្យដល់កូនដ៏ពិត១ កូនគ្មានចំនាស់ឈ្លោះគ្នា ព្រោះរឿងស្នេហ៍ ឬមិនស្មើស្មើចទ្រព្យខាងក្រៅទេ ។ ឯមាតាបិតា ក៏មានសេចក្តីសុខគ្រប់ប្រការ មិនមានសេចក្តីទុក្ខ ព្រោះ «ទ្រព្យឯងដុះស្មែងចាក់ម្ចាស់ឡើយ » ។ អាស្រ័យហេតុដូច្នេះ មាតាបិតាគប្បីផ្តល់ទ្រព្យទាំង ៧ នេះ គឺផ្តល់សទ្ធា ផ្តល់សីល ផ្តល់ហិរិ ផ្តល់ឱត្តប្បៈ ផ្តល់ពាហុសច្ចៈ ផ្តល់ចាគៈ និងបញ្ញា ដល់កូនចុះ ប្រាកដជាមិនខុសប្រាថ្នា និងខកបំណងក្នុងការចង់ឱ្យកូនបានសុខ តាមចេតនារបស់ខ្លួនលោកឡើយ ។

នាទីមាតាបិតា ក្នុងឋានៈជាឧបការបុគ្គល បានអធិប្បាយចប់សព្វគ្រប់ហើយ ។ មាតាបិតាណាបំពេញ មានឈ្មោះថាជាអ្នកបានធ្វើគុណឱ្យដល់កូនគ្រប់គ្រាន់ហើយ ដែលនឹងធ្វើឱ្យកូននឹករលឹកដល់ឧបការគុណនេះមិនដាច់ និងតបស្នងសងគុណដល់លោកជាមិនខាន ។

> *កតញ្ញូកតវេទី គឺការដឹងគុណនិងការតបគុណ អាចនឹងដុះបានល្អក្នុងចិត្តកូន ក៏ព្រោះមាតាបិតាបានធ្វើឧបការៈគុណល្អ ជូនមកវិញ បើឧបការគុណធ្វើមិនបានល្អ ត្រឹមត្រូវទេ ពាក្យថា « ម៉ែឪមានគុណ គុណនេះសែនធ្ងន់ធ្ងន់លើសប្រថពី គ្មានអ្វីនឹងស្មើ គុណលោកទាំងពីរ មាសប៉ុនគិរី ថ្លឹងស្មើពុំបាន » នឹងស្ថិតនៅតែត្រឹមលើក្រដាស ឬបបូរមាត់ប៉ុណ្ណោះ ពុំអាចនឹងជ្រាបចូលដល់ហឫទ័យរបស់កូនឡើយ ។*

# គ. មាតាបិតាជាកល្យាណមិត្តរបស់បុត្រ

មាតា មិត្តំ សកេ ឃរេ

*មាតាជាកល្យាណមិត្តរបស់កូននៅក្នុងផ្ទះ ។*

« ម្នាលភិក្ខុទាំងឡាយ មុនពេលដែលព្រះអាទិត្យនឹងរះ រមែងមានពន្លឺលេចចេញមកមុនជានិមិត្តយ៉ាងណា ការមានកល្យាណមិត្តក៏ជាតួនាំ ជាបុព្វនិមិត្តនៃការកើតឡើងរបស់អដ្ឋង្គិកមគ្គដល់ភិក្ខុ ដូច្នេះដែរ » ។

« តថាគតរកមើលមិនឃើញអង្គប្រកបខាងក្រៅ សូម្បីតែមួយដែលមានប្រយោជន៍ច្រើនសំរាប់ភិក្ខុដែលជាសេក្ខៈ ដូចការដែលមានកល្យាណមិត្តឡើយ ។ ភិក្ខុដែលមានកល្យាណមិត្ត រមែងកំចាត់អកុសលបាន និងរមែងធ្វើកុសលឱ្យកើតឡើង ។

ពុទ្ធភាសិតដែលលើកយកមកបង្ហាញខាងលើនេះ ល្មមអាចឱ្យអ្នកជាមាតាបិតា បានឃើញនូវសារសំខាន់របស់ការមានកល្យាណមិត្តហើយ និងឃើញនូវសារសំខាន់របស់អ្នកដែលនឹងត្រូវទៅជាកល្យាណមិត្តរបស់កូនអ្នក ។

កល្យាណមិត្ត គឺមិត្តល្អ ជាមិត្តដែលអ្នកណាបានសេពគប់រស់នៅជាមួយហើយ នឹងនាំឱ្យកើតសេចក្តីល្អ សេចក្តីចំរើនប្រយោជន៍ ។

កល្យាណមិត្ត សំដៅដល់គ្រូ ឬអ្នកអាណាព្យាបាលរបស់កូន ព្រោះថាមាតាបិតាជាបុព្វាចារ្យ គឺអាចារ្យដើមរបស់កូន ដែលមាននាទីជួយបង្ហាត់បង្រៀនកូនតាំងតែពីតូចក្រូចឆ្មារ រហូតដល់ធំដឹងក្តី មុននឹងទៅរកគ្រូឯណាៗទៀត ដែលនៅឯសាលាបង្រៀនកូនបន្ថែម ដូចមានពុទ្ធភាសិតថា ៖

*ព្រហ្មាតិ មាតាបិតរោ បុព្វាចរិយាតិ វុច្ចរេ*
*អាហុនេយ្យា ច បុត្តានំ បជាយ អនុកម្បកា ។*

លោកហៅមាតាបិតាថាព្រហ្ម ថាបុព្វាចារ្យ ថាអាហុនេយ្យៈរបស់បុត្រទាំងឡាយផង ថាជាអ្នកអនុគ្រោះដល់ពួកសត្វផង ។

មាតាបិតា នឹងមានឈ្មោះថាជាកល្យាណមិត្តរបស់កូន ព្រោះមានលក្ខណៈ ៧ ប្រការនៅក្នុងខ្លួន គឺ :

១. *បិយោ* : មាតាបិតាត្រូវធ្វើខ្លួនឱ្យកូនស្រឡាញ់ ឱ្យមានភាពស្និទ្ធស្នាល ធ្វើឱ្យកូនចង់និយាយលេង ចង់ប្រឹក្សា ហ៊ាននិយាយការអាថ៌កំបាំងប្រាប់ សាកសួរ ។ មាតាបិតាខ្លះធ្វើខ្លួនឱ្យកូនខ្លាច រហូតមិនហ៊ាននិយាយជាមួយ មិនហ៊ានប្រាប់ការអាថ៌កំបាំង រហូតដល់ទៅហ៊ានកុហក ព្រោះខ្លាច ។ ការដែលឱ្យកូនខ្លាចខ្លាំងពេកនេះ មិនជាការត្រឹមត្រូវទេ គប្បីនិយាយស្តីដោយផ្អែមល្ហែម កាយវិការទន់ភ្លន់ មិនធ្វើមុខយក្សដាក់កូនព្រឹកល្ងាច ឬប៉ះដៃៗ ប៉ះជើងៗ នោះឡើយ ។

២. *គរុ* : គប្បីធ្វើខ្លួនឱ្យទៅជាទីគោរពរបស់កូន ឱ្យទៅជាគំរូដ៏ល្អរបស់កូន ។ ធម្មតា បើមាតាបិតាប្រព្រឹត្តយ៉ាងណា កូនក៏នឹងចម្លងគំរូនោះជាមិនខាន ។ ពាក្យថា « *ពុតត្រូកុំគ្រាប់ ឡាប់ត្រូឱ្យយក* » មិនគប្បីយកមកប្រើនឹងកូនយើងឡើយ ។ មាតាបិតាខ្លះប្រព្រឹត្តស្រី ស្រា ល្បែង គ្រឿងអបាយមុខផ្សេងៗ ប្រព្រឹត្តខ្លួនថោកទាបរហូតដល់កូនមើលងាយមើលថោក ឬបើមិនដូច្នោះទេ កូនក៏អស់សង្ឃឹមក្នុងជីវិតតែម្តង ព្រោះគ្មានគិតថា គ្មានមិនអាចយកយើងជាទីពឹងបាន ។

៣. *ភាវនីយោ* : ជាអ្នកគួរឱ្យលើកតម្កើងតម្កល់ក្នុងឋានៈជាអ្នកមានសតិបញ្ញាចេះដឹង ថែមទាំងជាអ្នកចេះអប់រំខ្លួន អភិវឌ្ឍខ្លួនឱ្យកាន់តែប្រសើរ ជានិច្ច

ដែលជាការធ្វើឱ្យកូនសប្បាយចិត្ត រីករាយ ព្រោះមានឪពុកម្ដាយដែលជាមនុស្សល្អ មានគេកោតសរសើរ ។ ចំណុចត្រង់នេះ ជារឿងដែលត្រូវឱ្យមាតាបិតា គប្បីខំរៀនសូត្រឱ្យបានចេះដឹងទាន់ហេតុការណ៍ មិនមែនជាមនុស្សហួសសម័យ ដែលនាំឱ្យកូនមើលងាយថាជាមនុស្សបុរាណនោះទេ ។ ពាក្យថា « *ចាស់ឡើង ភ្លើឡើង* » ឬ « *ចាស់ឡើង កាន់តែឡិកឡក់ដូចក្មេងឡើង* » មិនមែនជាលក្ខណៈ កល្យាណមិត្តឧបមា ឡើយ ។

*៤. វត្តា ច* ៖ ចេះនិយាយឱ្យកើតផល ចេះនិយាយពន្យល់ យល់ដឹងថាកាលណាគួរនិយាយ ពេលណាគួរស្ងៀម ជាទីប្រឹក្សាដ៏ល្អ ។ ពេលឃើញកូនធ្វើខុសក៏ណែនាំដោយល្អ មានតិចនិកក្នុងការប្រៀនប្រដៅ មិនមែនទៅទាំងចចឹងចិស ឬបណ្ដោយៗរហូតដល់ទៅនិយាយលែងស្ដាប់នោះទេ ។ ព្រះបាទជ័យចេស្ដា ព្រះមហាក្សត្រនៃប្រទេសកម្ពុជា នាស.វ.ទី១៧ បានរៀបចំតិកនិកនៅក្នុងការស្នូរចម្លើយអ្នកជាប់ក្ដី ៤ យ៉ាង ហៅថា *ល្បិចចៅក្រម* ដែលយើងអាចយកមកកែច្នៃរៀបចំនៅក្នុងការអប់រំកូនក្នុងទីនេះបាន ។ ល្បិចនោះគឺ មន្ទលេន សោនបេទ បណ្ដុកជសីហលោ មានសេចក្ដីថា ៖

*៤.១. មន្ទលេន* ៖ ប្រែថា ទន់ ទន់ភ្លន់ ស្រទន់ សន្សឹមៗ តិចៗ ជាការអប់រំណែនាំ សាកសួរដោយការប្រើកាយវិការទន់ភ្លន់ សុភាព មិនកញ្ឆក់កញ្ឆេងឧបមាដូចទឹកដែលហូរចូលទៅក្នុងត្រពាំងរិញៗ លុះត្រាតែពេញ មិនហូរគំហុកខ្លាំងទាល់តែបាក់ច្រាំងនោះទេ ដូចពាក្យស្លោកថា « *សីមៗកុំបំបោល ក្រែងដុំដល់ដូចប្រាថ្នា* » ។

*៤.២. សោនបទ* ៖ ប្រែថា ដំណើរសត្វខ្លែងតាបកូនមាន់ ។ លោកឱ្យ

ឧទាហរណ៍ថា សត្វខ្លែងមុននឹងឆាបកូនមាន់ វាត្រូវហើរវេរា កេឈរកុងស្ទង់មើលសិន បើល្មុះតែឃើញមានចំនងឱកាសល្មមឆាបឆក់បាន វាក៏សម្រួបស្លាបឆាបចុះ ហើយហើរវេរឡើងវិញភ្លាម ។ ដូចគ្នាដែរ កូនខ្លះត្រូវប្រើល្បិចកិច្ចកល ឬចាំឱកាសហុចឱ្យបន្តិច ទើបគួរនឹងប្រដៅបាន បើទោទាំងពិសពាស នឹងមិនបានផលឡើយ ។

*៤.៣. មណ្ឌូកជ* ៖ ប្រែថា ដំណើរកង្កែប ។ ធម្មតាកង្កែប វាជាសត្វដែលលោតឈប់ៗ បង្អង់ហើយទើបទៅទៀត ។ ត្រង់នេះអាចយកជាគតិថា ធម្មតាការស្ដីប្រដៅ បើប្រដៅតាំងពីព្រឹកទល់ល្ងាច ១ខែ ៣០ថ្ងៃ គ្មានលោះត្រង់ណានោះ ប្រាកដជាគ្មានកូនណាទ្រាំបានទេ ត្រូវទុកឱកាសឱ្យគ្នាបានយកទៅកែខ្លួនផង ឬបើមានការស្ដីប្រដៅ ក៏ត្រូវមានការឱ្យរង្វាន់ជាគូដែរ ( ពេលកង្កែបសម្រាកស៊ី ) ដូចជា « អើ ! កូនឯងធ្វើល្អហើយ ប្រសើរហើយកូន » ជាដើម ។

*៤.៤. សីហលោ* ៖ ប្រែថា កាន់យក ឬកាន់តាមសត្វសីហៈ គឺ តោ ។ ធម្មតាសត្វតោ ជាសត្វមានអំណាចលើសសត្វនានា ព្រោះវាមានកម្លាំងខ្លាំងអាចសង្កប់សត្វដទៃទៀតឱ្យស្ងប់បាន ។ កូនខ្លះនិយាយពាក្យទន់មិនស្ដាប់ ធ្វើល្បិចក៏មិនបាន ស្ដីប្រដៅក៏មិនបាន ម៉ែឪគួរប្រើរបៀបសីហៈ គឺទណ្ឌកម្ម ។ ទណ្ឌកម្ម បានដល់ការដាក់ទោស ការឈប់និយាយរកមួយរយៈ ការកំហែងគំរាម ឬក៏ដោយការវាយនិងវាយធ្វើបាបជាដើម ។ តែសូមប្រយ័ត្ន ការវាយនិងវាយធ្វើបាបនេះ ត្រូវប្រកបដោយមេត្តា មិនមែនវាយរហូតដល់ទៅសន្លប់ បាក់បែកដៃជើង ឬពិការមួយជីវិតនោះទេ ។ ហើយសូមជ្រាបថា សព្វថ្ងៃនេះនៅខាងអឺរ៉ុប គេឈប់ប្រើរបៀបវាយដំចំពោះកូនហើយ ព្រោះមានច្បាប់ « សិទ្ធិកុមារ » ជួយមកការពារ ។

*៥. វចនក្ខមោ* ៖ អត់ធន់ចំពោះពាក្យសំដី គឺពេញចិត្តមិនធុញទ្រាន់នឹង

ការស្តាប់សំណួរ ឬការពិភាក្សា ការរិះគន់ ការបញ្ចេញយោបល់ពីកូនជានិច្ច ។ មាតាបិតាត្រូវគិតថា កូនក្មេងមានចរិតមួយ គឺឆ្ងល់ហើយចង់ចេះ ដូច្នេះ ត្រូវអត់ធន់ចំពោះសំណួរកូន កុំគប្បីខឹង ឬក្រេវក្រោធ ឬធ្វើមុខមិនសប្បាយចិត្តពេលកូនសួរ ឬសុំយោបល់ពីខ្លួននោះ ។ រឿងការអត់ធន់នេះ នឹងអាចធ្វើឱ្យកូនរឹតតែគោរព និងលើកតម្កើងយើងថា ជាបុគ្គលដែលមានប្រយោជន៍ចំពោះជីវិតគេ ។

*៦. គម្ភីរញ្ច កថំ កត្តា* : អាចពន្យល់រឿងដែលជ្រៅៗ រឿងពិបាកៗស្មុគស្មាញឱ្យកូនយល់ និងកាន់តែបែកប្រាជ្ញាឡើង ។ ចំពោះមាតាបិតាដែលពុំសូវមានចំណេះ មិនអាចពន្យល់កូនបាន ក៏គួរប្រាប់កូនតាមត្រង់ ហើយប្រាប់ថា ចាំទៅរក ឬទៅសួរពីលោកនេះ ឬអ្នកនោះឱ្យ ឬរកសៀវភៅមកឱ្យអានខ្លួនឯង ឬក៏នាំទៅជួបលោកអ្នកប្រាជ្ញណាដែលអាចឆ្លើយបាន ។ ធ្វើយ៉ាងនេះឈ្មោះថា យើងអាចដោះស្រាយកង្វល់របស់កូនបាន ។ ម្យ៉ាងទៀត បើខ្លួនបង្រៀនកូនអស់ចំណេះហើយ ក៏គប្បីរកគ្រូដែលល្អជាងខ្លួនឱ្យបង្រៀនកូន ឱ្យកាន់តែយល់ច្បាស់ជ្រៅទៀត មិនគប្បីខ្លាចកូនចេះជាងខ្លួនទេ ។

*៧. នោ ចដ្ឋានេ និយោជយេ* : មិននាំកូនក្នុងរឿងខុស រឿងវិនាស ឬរឿងដែលមិនមានប្រយោជន៍ ។ ដូចជាឱ្យកូនរៀនជក់បារី រៀនផឹកស្រា រៀនលេងល្បែង ជាដើម ។ ម៉ែឪខ្លះ ឃើញកូនមានដៃមានជើងចេះលួចរបស់គេមកឱ្យខ្លួនបាន ក៏ត្រេកអរសប្បាយ ឬឃើញកូនចេះជេរបញ្ឆោរអ្នកណាដែលខ្លួនមិនពេញចិត្ត ក៏រុញកូនថែម ឬឃើញកូនចេះគេចវេះដោយល្បិចអាក្រក់បាន ក៏សាទរ ធ្វើបែបនេះឈ្មោះថា បង្រៀនកូនឱ្យចូលទៅរកសេចក្តីវិនាស ជាពិតប្រាកដ ។

WAT KHEMARARATANARAM

គោលធម៌របស់កល្យាណមិត្តទាំង ៧ ប្រការនេះ គប្បីមាតាបិតាយកចិត្តទុកដាក់ឱ្យបានជិតដល់ ព្រោះអ្នកមាននាទីជាគ្រូ បើបង្រៀនសិស្សមិនបានល្អទេ សិស្សអ្នកប្រាកដជាប្រលងធ្លាក់មិនខាន ។

WAT KHEMARARATANARAM

## ឃ . មាតាបិតាជាបូជនីយបុគ្គលរបស់បុត្រ

បូជនីយបុគ្គល គឺជាបុគ្គលដែលគេគួរបូជា ។ បុគ្គលដែលគេនឹងបូជា ព្រោះមិនមែនអ្នកនោះមានទ្រព្យសម្បត្តិច្រើនទេ តែព្រោះអ្នកនោះមានគុណធម៌ដ៏ខ្ពង់ខ្ពស់ណាមួយដែលគួរឱ្យគេគោរព ។ មាតាបិតាដែលបានឈ្មោះថាជាបូជនីយ-បុគ្គលទៅបាន ក៏ព្រោះអាស្រ័យគុណធម៌នោះឯង ។ ជាទូទៅ បុគ្គលដែលគេបូជា សំដៅទៅលើអ្នកដឹកនាំសាសនា ឬព្រះអាទិទេពណាមួយដែលគេរាប់អាន ។ ក្នុងព្រហ្មញ្ញសាសនា គេមានជំនឿថា បុគ្គលដែលគួរគេបូជា គឺព្រះព្រហ្ម ព្រោះព្រះព្រហ្មជាអ្នកបង្កើតមនុស្សគ្រប់វណ្ណៈ បង្កើតពិភពលោក និងច្បាប់ទម្លាប់ទាំងអស់ ។ លុះដល់ពុទ្ធសាសនាកើតឡើង ព្រះពុទ្ធលោកក៏បដិវត្តពាក្យប្រៀនប្រដៅសាសនាព្រាហ្មណ៍ខ្លះ ដូចជាថាជាជាងទៅជឿថា មនុស្សយើងកើតពីព្រះព្រហ្ម ព្រះអង្គក៏ប្រាសទូន្មានពុទ្ធបរិស័ទថា « ពួកព្រាហ្មណ៍ កើតចេញពីផ្ទៃមាតាសោះ ទៅជាថាខ្លួនឯងកើតពីព្រហ្ម ហើយបើថាព្រហ្មជាអ្នកបង្កើតមនុស្សមែន មាតាបិតានេះឯង គឺជាព្រះព្រហ្មរបស់កូន ព្រោះលោកប្រកបទៅដោយព្រហ្មវិហារធម៌ ៤ ប្រចាំចិត្ត គឺ មេត្តា ករុណា មុទិតា និងឧបេក្ខា » ។ មាតាបិតាជាព្រះព្រហ្ម ដែលគួរបូជារបស់កូនមែន ។ ជាព្រះព្រហ្មនៅក្នុងន័យដែលលោកមានព្រហ្មវិហារធម៌ មិនមែនមានន័យត្រឹមតែបង្កើតកូន ដែលសត្វណាៗក៏ធ្វើបាននោះទេ ។ បើព្រហ្មមានន័យត្រឹមតែបង្កើតកូន មនុស្សក៏នឹងមិនមានតម្លៃអ្វីខុសពីមេឈ្មោល ដែលជាលក្ខណៈរបស់សត្វតិរច្ឆាននោះឡើយ ។ ដូច្នេះមាតាបិតា មិនមែនខ្លួនលោកមានឈ្មោះថាជាមាតាបិតា ព្រោះខ្លួនលោកចេះបង្កើតកូននោះទេ តែព្រោះលោកមានគុណធម៌ទាំង ៤

KHEMARARATANARAM

ប្រការនេះក្នុងខ្លួន បើពុំមានទេ លោកក៏មានន័យត្រឹមតែជាមេបារបស់សត្វ តែប៉ុណ្ណោះ ។

១. *មេត្តា* គឺការអាណិតស្រឡាញ់កូនអស់ពីពោះ ចង់ឱ្យកូនមានតែសេចក្ដីសុខ ។ ព្រឹត្តិកម្មទាំងឡាយដែលមាតាបិតាមានចំពោះកូន ត្រូវប្រកបដោយមេត្តា គឺនឹងធ្វើអ្វីក៏ធ្វើដោយមេត្តា ( មេត្តាកាយកម្ម ) និងនិយាយស្ដីអ្វី ក៏និយាយស្ដីដោយមេត្តា (មេត្តាវចីកម្ម ) បើនឹងគិតអ្វី ក៏គិតដោយចិត្តមេត្តា ( មេត្តាចិត្ត ) ចង់ឱ្យតែកូនបានសុខ គ្មានគំនិតព្យាបាទ ចងគំនុំ ឬគិតបៀតបៀនកូន ។ មេត្តានេះក៏រួមដល់អត្ថន័យថា ធ្វើអ្វីមិនប្រកបដោយហិង្សា ឃោរឃៅផងដែរ គឺក្នុងការគ្រប់គ្រងចិញ្ចឹមអប់រំកូន ត្រូវប្រើវិធីអហិង្សាជាប់ជានិច្ចចំពោះកូន ។

២. *ករុណា* គឺការជួយសង្គ្រោះបំបាត់នូវសេចក្ដីទុក្ខ សេចក្ដីលំបាករបស់កូន ។ ការជួយសង្គ្រោះមិនចាំបាច់តែមានទ្រព្យសម្បត្តិទេ ព្រោះម៉ែឪខ្លះក៏ក្រ តែការជួយសង្គ្រោះខាងផ្លូវគំនិតយោបល់ ជួយលួងលោម ជួយថែទាំពេលកូនមានទុក្ខ មានវិបត្តិក្នុងខ្លួន ឱ្យកូនមានកំលាំងចិត្តក្នុងការតស៊ូក្នុងឆាកជីវិត មានកម្លាំងក្នុងការត្រឡប់ខ្លួនមកក្នុងផ្លូវត្រូវ ឬផាស់ជៀនកូនពេលឃើញកូនប្រមាទ ធ្វេសប្រហែសជាដើម ។

៣. *មុទិតា* ការត្រេកអរសាទរនៅពេលដែលឃើញកូនមានសេចក្ដីសុខ ឃើញកូនប្រព្រឹត្តល្អ ជាកំលាំងចិត្តឱ្យកូនខំប្រព្រឹត្តល្អថែមទៀត មិនបង្អាក់រារាំងចំពោះសេចក្ដីសុខរបស់កូន ។

៤. *ឧបេក្ខា* គឺតាំងចិត្តជាកណ្ដាល មិនលំអៀងទៅដោយអគតិ ៤ ប្រការ គឺ លំអៀងព្រោះស្រឡាញ់, លំអៀងព្រោះស្អប់, លំអៀងព្រោះខ្លាច,

លំអៀងព្រោះមិនដឹង ល្ងង់ ។ បើមានកូនច្រើន មាតាបិតាគប្បីស្រឡាញ់រាប់អានកូនឱ្យបានស្មើៗគ្នា កុំស្អប់មួយស្រឡាញ់មួយ ព្រោះមួយណាក៏ជាកូនដែរ ។

# ៨- មាតាបិតាជាទីពឹងរបស់មនុស្ស សង្គម និងធម្មជាតិ

កូនគឺជាអ្នកបន្តចម្លងនូវអ្វីៗគ្រប់យ៉ាងទាំងអស់ពីមាតាបិតា តាំងពីសាច់ឈាម ចិត្តគំនិត ការប្រព្រឹត្ត និងទ្រព្យសម្បត្តិពីជំនាន់មួយទៅជំនាន់មួយទៀត ដរាបណានៅតែមានមាតាបិតារស់នៅ ។ ដូច្នេះ ទើបមាតាបិតាជាមេពុម្ពរបស់កូន មេពុម្ពរបស់សង្គម មេពុម្ពរបស់ប្រទេស និងជាមេពុម្ពមនុស្សលោក ។ បើមេពុម្ពយ៉ាងណា វត្ថុដែលចេញពីពុម្ព ក៏យ៉ាងនោះដែរ ។




ក្នុងទស្សនៈពុទ្ធសាសនា មនុស្សម្នាក់ៗ កើតមកតែងមានទីពឹងទីអាស្រ័យសំរាប់ជាកម្លាំងក្នុងការដើរលើផ្លូវជីវិត ។ ទីពឹងនេះ មាន ៣ យ៉ាង គឺ

ពឹងលើខ្លួនឯង ពឹងលើសង្គម និងពឹងលើធម្មជាតិ ។ បើតាមពុទ្ធភាសិត *ព្រហ្មាតិ មាតាបិតរោ បុព្វាចរិយាតិ វុច្ចរេ អាហុនេយ្យា ច បុត្តានំ បជាយ អនុកម្បកា* ដែលប្រែថា មាតាបិតាជាព្រហ្មរបស់បុត្រ ជាបុព្វាចារ្យ ជាអាហុនេយ្យៈរបស់បុត្រទាំងឡាយ និងជាអ្នកអនុគ្រោះដល់ពួកសត្វលោក នោះខ្ញុំយល់ថា មាតាបិតាមានសារសំខាន់ណាស់សំរាប់សត្វលោកទាំងឡាយដែលមានជីវិតជាឯកជន ដែលរស់នៅក្នុងសង្គម និងដែលពឹងពាក់ទៅលើប្រពៃសម្បត្តិធម្មជាតិ ។ ឬបើនឹងនិយាយផ្ទុយមកវិញ យើងអាចនិយាយថា ទាំងបុគ្គលម្នាក់ៗ ទាំងសង្គមទាំងមូល និងទាំងធម្មជាតិដែលនៅជុំវិញយើង ឬពិភពលោកនេះ សុទ្ធតែត្រូវពឹងពាក់លើមាតាបិតាទាំងអស់ ព្រោះជាកត្តាកំណត់នូវការរីកចំរើន ឬថយក្រោយ និងការគង់វង្ស ឬរលំរលាយ ។

មាតាបិតាបង្កើតកូនឱ្យទៅជាកសិករ កម្មករ ឧស្សាហករ ពាណិជ្ជករ គ្រូ អ្នកស្រាវជ្រាវ អ្នកវិទ្យាសាស្ត្រ អ្នកបួស ទាហាន និងជាចៅក្រុងរដ្ឋ ។ បើមាតាបិតាបានបំពេញនាទីខ្លួនជាអាហុនេយ្យបុគ្គលរបស់បុត្រគឺ ៖ ជាអ្នកបានបំពេញនាទី ឬបដិបត្តិធម៌របស់មាតាបិតាដោយប្រពៃ ( សុបដិបន្នោ ) ។

- ជាអ្នកបំពេញនាទី ឬបដិបត្តិធម៌ដោយត្រង់ គឺបដិបត្តជាមជ្ឈិមាបដិទា មិនតឹងពេក មិនធូរពេក ដោយឈរលើដ្ឋានទាំង ៨ គឺ ការយល់ត្រូវ ការគិតត្រូវ ការប្រព្រឹត្តត្រូវ ការចិញ្ចឹមជីវិតត្រូវ ការព្យាយាមត្រូវ ការមានសតិរលឹកត្រូវ និងការតម្កល់ចិត្តឱ្យនឹងត្រូវហើយនោះ កសិករ កម្មករ ... និងចៅក្រុងរដ្ឋទាំងនោះ ក៏នឹងទៅជាកសិករល្អ កម្មករល្អ ... និងចៅក្រុងរដ្ឋល្អជាមិនខាន ។ ហើយបើមាតាបិតានៃជំនាន់នីមួយៗ បំពេញនាទីដោយប្រពៃ និងដោយត្រង់គ្រប់ៗជំនាន់នោះ សង្គមយើង ពិភពលោកយើងនេះនឹងមិនមានសភាពឃោរឃៅ ប្រកួតប្រជែងខ្ចេចខ្ចីប្រព្យធម្ម.

ជាតិដូចសព្វថ្ងៃនេះឡើយ ។ ម្នាក់ៗនៅក្នុងសង្គម នឹងមានសេចក្ដីមេត្តាដល់គ្នានឹងគ្នា សង្គមមនុស្សនឹងគួរឱ្យចង់រស់នៅជាងបច្ចុប្បន្ននេះជាមិនខាន ហើយធម្មជាតិ ក៏នឹងនៅជាគូជីវិតសំរាប់មនុស្សជាតិ ជានិរន្តន៍តទៅ ។

WAT KHEMARARATANARAM

# ៩- នាទីចំពោះសង្គម

ខ្ញុំគិតថា នាទីចំពោះសង្គមរបស់ស្វាមីភរិយា ហាក់ដូចជាមិនបាច់អធិប្បាយអ្វីឱ្យវែងឆ្ងាយទេ ព្រោះបើយើងពិនិត្យទៅលើករណីយកិច្ចទាំងអម្បាលម៉ាន ដែលមាតាបិតាគប្បីធ្វើចំពោះបុត្រ មាននាទីជាអភិវឌ្ឍនករ នាទីជាឧបការី នាទីជាកល្យាណមិត្ត និងជាបូជនីយបុគ្គលនោះ ហាក់ដូចជាគ្របដណ្តប់ទៅលើនាទីដែលគូស្វាមីភរិយាត្រូវមានចំពោះសង្គមអស់ទៅហើយ ។ គ្រាន់តែសូមឱ្យអ្នកជាគូស្វាមីភរិយា ងាកក្រោយទៅអានម្តងទៀត ហើយគិតទុកក្នុងចិត្តថា គោលធម៌ទាំងអស់ដែលខ្លួនត្រូវប្រៀនប្រដៅកូនទាំងប៉ុន្មាន ខ្លួនត្រូវធ្វើឱ្យបាន ដូចដែលបានប្រាប់កូនដែរ ។ តែប៉ុណ្ណោះ ក៏នឹងអាចយល់បានទៅហើយ ។ ដូច្នេះ ក៏សូមអានពិនិត្យម្តងទៀតចុះ ។ មិនេះ ខ្ញុំសូមបន្ថែមតែទៅលើការរស់នៅជាមួយមាតាបិតា និងសាច់ញាតិ ព្រមទាំងករណីយកិច្ចក្នុងឋានៈជាកូន ដែលត្រូវមានកតញ្ញូកតវេទិតាធម៌ចំពោះមាតាបិតាយើង ឱ្យរឹតតែបានច្បាស់បន្តិចទៀត ។

## ការរស់នៅជាមួយមាតាបិតាក្មេក

ភាគច្រើនៗ តែមានបញ្ហារវាងមាតាបិតាក្មេក និងកូនប្រសារ ឬរវាងខ្លួននិងសាច់ថ្លៃ ។ ពាក្យចាស់លោកថា « *ទ្រាំផ្សែងភ្លើងបាន ទើបទ្រាំនឹងម៉ែឪក្មេកនិងសាច់ថ្លៃបាន* » ដូចជាត្រឹមត្រូវណាស់ ។ បើសិនជាមិនអាចនៅជាមួយបានទេ ក៏គួរតែពិគ្រោះគ្នានឹងប្តីប្រពន្ធខ្លួន ព្រមទាំងសូមអនុញ្ញាតពិគាត់ដើម្បីបែកផ្ទះសំបែង

WAT KHEMARARATANARAM

ជាការគួរ ។ តែការបែកនេះ មិនមែនជាការបែកដើម្បីកុំឱ្យឃើញមុខគាត់ និងបំភ្លេចគុណលោកទេ ព្រោះមាតាបិតាជាអ្នកមានគុណលើយើងជាដ៏ខ្ពង់ខ្ពស់ និងមិនមានអ្វីដែលអាចនឹងតបស្នងសងគុណលោកបានឡើយ ។ នៅក្នុងគោលធម៌ដែលនិយាយពីភ្លើង ដែលគួរថែរក្សា ព្រះសម្មាសម្ពុទ្ធ លោកបានហៅមាតាបិតាថាជាភ្លើងដែរ គឺ « *អាហុនេយ្យគ្គី* » មានន័យថាជាភ្លើងដែលគួរគោរពបូជា ។ ធម្មតាភ្លើង មានទាំងគុណទាំងទោស បើយើងថែរក្សាបានល្អ ប្រុងប្រយ័ត្ន ថែទាំ នោះភ្លើងក៏នឹងទៅជាប្រទីបសំរាប់បំភ្លឺ ទៅជាភ្លើងសំរាប់ផ្តល់ប្រយោជន៍ តែបើយើងមិនប្រុងប្រយ័ត្នទេ ឬរក្សាមិនល្អ ភ្លើងក៏អាចនឹងឱ្យយើងរលាកដៃ ឆេះផ្ទះសម្បែង និងបំផ្លាញអ្វីៗទៀតបានដែរ ។ ខ្ញុំតែងឮចាស់ៗលោកថា « *អ្នកណាស៊ីងគុណម៉ែឪ រកស៊ីមិនឡើងទេ* » ហើយឃើញច្បាស់ថាអញ្ចឹងមែន ។ បើលោកជាអ្នកណាធ្វើបាបលោក អ្នកនោះក៏រមែងរកស៊ីមិនចំរើន លុះដល់មានកូនធំឡើង កូននោះក៏ប្រព្រឹត្តចំពោះខ្លួនក្នុងផ្លូវមិនល្អ ដូចយើងធ្លាប់ធ្វើឱ្យដល់មាតាបិតាយើងដែរ ។ ក្នុងមង្គលទាំង ៣៨ ប្រការ ការចិញ្ចឹមមាតាបិតាក៏ជាមង្គលមួយដែរ « *មាតាបិតុឧបដ្ឋានំ ឯតម្មង្គលមុត្តមំ* » ការឧបត្ថម្ភចិញ្ចឹមមាតាបិតា ជាមង្គលដ៏ឧត្តម ។ ពុទ្ធភាសិតដែលសរសើរពីគុណមាតាបិតា គឺ : *យោ មាតរំ បិតរំ វា មច្ចោ ធម្មេន បោសតិ ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតិ* ប្រែថា « អ្នកណាចិញ្ចឹមមាតាបិតាដោយធម៌ ពួកបណ្ឌិតតែងសរសើរអ្នកនោះក្នុងលោកនេះ; អ្នកនោះទៅខាងមុខ រមែងរីករាយក្នុងស្ថានសួគ៌ ។ ឯបុគ្គលដែលមិនដឹងគុណមាតាបិតា លោកបានសម្តែងថា : *ឯវំ កិច្ឆាភតោ បោសោ បិតុ អបរិចារកោ បិតរិ មិច្ឆាចរិត្វាន និរយំ សោ ឧបបជ្ជតិ* បុគ្គលដែលមាតាបិតាចិញ្ចឹមមកបានដោយលំបាកយ៉ាងនេះហើយ មិនបំរើមាតាបិតា ព្រមទាំងប្រព្រឹត្ត

ខុសចំពោះលោក បុគ្គលនោះរមែងធ្លាក់ទៅដល់នរក ។ ដូច្នេះ បុត្រាបុត្រីទាំងឡាយ មានគូស្វាមីភរិយាហើយ កុំភ្លេចគុណអ្នកជាមាតាបិតាឱ្យសោះ ។ អ្នកពិបាកនឹងកូនអ្នកយ៉ាងណា ចង់ឱ្យកូនអ្នកដឹងគុណអ្នកយ៉ាងណា លោកដែលជាមាតាបិតា គាត់លំបាកនឹងយើង ជាងយើងលំបាកនឹងកូនយើងទៅទៀត ដូច្នេះ ត្រូវតបស្នងសងគុណគាត់ឱ្យបានសក្តិសមជាកូនល្អ ។

ជាចុងក្រោយ សូមនាំពាក្យខ្មែរយើង ១ ឃ្លាទៀតមកផ្តាំ គឺ « *បើចង់ឱ្យសុខ ចូរស្រឡាញ់ម៉ែក្មេកឪក្មេកឱ្យដូចម៉ែឪខ្លួនបង្កើត ឬឱ្យច្រើនជាងផង នោះរឹតតែប្រសើរ* » ។

ចំពោះបងប្អូនមីងមាដូនតាសាច់បង្កើត និងសាច់ថ្លៃ ក៏គប្បីស្រឡាញ់រាប់អានឱ្យបានស្មើគ្នាចុះ ហើយក៏ជួយសង្គ្រោះតាមដែលយើងអាចធ្វើទៅបានព្រោះការសង្គ្រោះញាតិក៏មានឈ្មោះថាជាមង្គលដ៏ឧត្តមមួយដែរ *ញាតិសង្គហោ ឯតម្មង្គលមុត្តមំ* ។ ញាតិរមែងជួយយើងពេលមានការអាសន្ននៅគ្រាក្រ បើមិនតិចក៏ច្រើនដែរ ។ ពាក្យខ្មែរថា « *ធ្វើផ្ទះឱ្យស្រែះបន្លា* » គឺការយកញាតិមិត្តមកធ្វើជាបន្ទាជារបងការពារយើង ក្នុងរឿងនេះ ព្រះសម្មាសម្ពុទ្ធលោកបានឱ្យយើងបដិបត្តិសង្គហវត្ថុ ៤ យ៉ាង ដែលជាគោលធម៌បដិបត្តិសំរាប់ជាចំណងចងចិត្តបុគ្គល និងឱ្យក្រុមញាតិយើងនឹករលឹកយើង និងសំរាប់ពង្រឹងសាមគ្គីភាពផង គឺ ៖

*១. ទាន* ការឱ្យ គឺមានចិត្តសប្បុរសទូលាយ លះបង់ ចែករំលែកជួយគ្នាដោយទ្រព្យសម្បត្តិ រហូតដល់ការជួយគ្នាដោយការផ្តល់នូវចំណេះ មធ្យោបាយគំនិតសំរាប់ចិញ្ចឹមជីវិតជាដើម ។

*២. បិយវាចា* មានវាចាសម្តីសម្តៅជាមិត្រស្រឡាញ់ផ្អែមល្ហែមពិរោះ ធ្វើ

ឱ្យគេជាប់ចិត្ត ធ្វើឱ្យគេមានសាមគ្គី ឱ្យកើតមេត្រីធម៌ មានហេតុមានផល អាច ឱ្យគេជឿ និងយល់ព្រមតាមបាន ។

*៣. អត្ថចរិយា* គឺការខ្វល់ខ្វាយជួយសង្គ្រោះក្នុងកិច្ចការដែលជាប្រយោជន៍របស់ញាតិមិត្ត និងសាធារណជន មិនសំងំយកសុខតែឯង ។

*៤. សមានត្តតា* គឺការមានខ្លួនស្មើ ទោះជានៅទីណាក៏ដោយ មិនមែននៅនឹងមុខធ្វើអញ្ចេះ នៅក្រោយធ្វើអញ្ចុះ រួមសុខទុក្ខជាមួយគ្នា រួមទាំងការធ្វើខ្លួនឱ្យសមទៅតាមឋានៈបុគ្គល និងស្ថានការណ៍ជុំវិញផង ។

សង្គហៈទាំង ៤ យ៉ាងនេះ ឈ្មោះថាជាចំណងសំរាប់ចងចិត្តថ្លៃញាតិមិត្ត ឬជារបងសំរាប់ការពារផ្ទះ និងជាស្នេហ៍សំរាប់ឱ្យញាតិមិត្តចូលចិត្ត និងពឹងពាក់បានពេលយើងមានអាសន្នអន់ក្រ ។ បុគ្គលមិនគប្បីមើលងាយញាតិរបស់ខ្លួនឡើយ ដូចពុទ្ធភាសិតទ្រង់សំដែងថា :

*ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ* នរជនណាប្រកាន់ខ្លួនព្រោះកំណើត ថាខ្លួនអញត្រាន់បើជាងប្រកាន់ខ្លួនព្រោះទ្រព្យ ថាខ្លួនអញមានច្រើនជាង ព្រោះវង្សត្រកូល ថាអញប្រសើរជាង ហើយមើលងាយញាតិរបស់ខ្លួន ការប្រកាន់ខ្លួន និងការមើលងាយនេះ ជាប្រធាននៃសេចក្ដីវិនាសសំរាប់នរជននោះ ។

ឯសាស្ត្រាច្បាប់បណ្ដាំបិតា និយាយថា :

*រីម្ដាយឪពុក នឹងបានលើកមុខ ដោយកូនពិងារ*
*អស់ទាំងបងប្អូន ជីដូនជីតា ម្ដាយមីងឪមា*
*សឹងស្រួលដូចចិត្ត ។*

ព្បិតកូនសុភាព ជាអ្នករាបទាប ត្រូវនឹងគំនិត
គ្រប់អស់បងប្អូន ទោះឆ្ងាយទោះជិត សឹងបានដូចចិត្ត
ដូចដួងចិន្តា ។

WAT KHEMARARATANARAM

# ១០- សុភមង្គលដ៏ឧត្តម

គ្មានអ្វីទៀងទាត់ទេនៅលើផែនដីមួយដុំតូចនេះ ។ គ្រប់យ៉ាងតែងតែមានការចាប់ផ្ដើមកំណើត ការចំរើនលូតលាស់ និងរលត់ទៅវិញជាការធម្មតា ។ កើត ចាស់ ស្លាប់ ។ ចាប់ផ្ដើម តាំងនៅ ចប់ទៅវិញ ។

បទភ្លេងពិរោះដែលប្រគំហើយ ក៏នឹងត្រូវមានពេលចប់ ។ មិនមានពិធីជប់លៀងណាមួយដែលមិនឈប់នោះទេ ។ សុភមង្គលដែលបង្កើតឡើងហើយ ក៏នឹងត្រូវចប់ទៅវិញជាមិនខាន ។ នេះជាធម្មតារបស់លោក ជាសច្ចភាពរបស់អនិច្ចតាធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ហើយដោយប្រពៃ ។

បើអញ្ចឹង ជីវិតអាពាហ៍ពិពាហ៍នេះ វាមិនក្លាយទៅជាការអស់សង្ឃឹមហើយឬ ? មានប្រយោជន៍ និងត្រូវស្វែងរកសុភមង្គលធ្វើអ្វី បើវាបញ្ចប់ដោយភាពសោកសៅផ្លូវចិត្តនោះ ?

មានទ្រព្យសម្បត្តិបរិបូណ៌ មានយសសក្ដិខ្ពង់ខ្ពស់ ទៅទីណាក៏មានគេសរសើររំពង ការមានសេចក្ដីសុខកាយ សុខចិត្តគ្រប់ប្រការទាំងប៉ុននេះ ជាបំណងរួមនៃជីវិតមនុស្ស ។ ប៉ុន្តែ មានប៉ុន្មាននាក់ដែលទទួលបាននូវសេចក្ដីសង្ឃឹមនេះបានដូចចិត្ត ?

សត្វមមាចដែលឃើញភ្លើង គិតថាជារបស់គួរឱ្យសប្បាយ ភ្លេចគិតថាភ្លើងក្ដៅ ទីបំផុតក៏ត្រូវស្លាប់ខ្លួនព្រោះភ្លើង ។ អ្នកកំពុងតែព្រេបសុភមង្គលច្រើនតែ

ភ្លេចនូវអ្វីដែលនៅជុំវិញខ្លួន ។ ទីបំផុតក៏ទទួលនូវសេចក្តីទុក្ខ ព្រោះសុភមង្គលនោះរលត់ទៅវិញ ។ ទ្រព្យក្តី យសក្តី សុខក្តី បើវាអាចកើតដល់យើងបាន វាក៏អាចរលត់ទៅវិញបានដែរ ព្រោះវិជ្ជមាន និងអវិជ្ជមាន ជារបស់គូនៅប្រចាំលោក ។

| វិជ្ជមាន + | | អវិជ្ជមាន - |
|---|---|---|
| បានលាភ | | បាត់លាភ |
| បានយស | លោកធម៌ | បាត់យស |
| សរសើរ | | និន្ទា |
| សុខ | | ទុក្ខ |

ទាំង ៨ យ៉ាងខាងលើនេះ លោកហៅថា « លោកធម៌ » ប្រែថា ធម៌ប្រចាំលោក ធម៌របស់លោក កើតមានដល់មនុស្សគ្រប់ៗគ្នា ។ បើជីវិតកំពុងវិជ្ជមាន ត្រូវគិតថា អវិជ្ជមាន គង់នឹងមានមកដល់ជាមិនខាន ហើយបើជីវិតកំពុង អវិជ្ជមាន គប្បីគិតថា វិជ្ជមាន គង់នឹងមកពេលណាមួយមិនខាន ។ សំខាន់បំផុត បើអ្នកកំពុងវិជ្ជមាន ក៏កុំអរពេក រហូតដល់ទៅភ្លេចខ្លួនដូចមមាច តែបើអវិជ្ជមាន ក៏កុំទោមនស្សរហូតដល់ទៅធ្វើអត្តឃាត ឬអស់សង្ឃឹមក្នុងជីវិត ។

ដើម្បីឈ្នះលោកធម៌ អ្នកត្រូវដាក់ចិត្តឱ្យស្ថិតនៅពីលើវិជ្ជមាន និងអវិជ្ជ-មាន ។ ព្រះសម្មាសម្ពុទ្ធបានប្រមាននិវាទ ដែលមានប្រយោជន៍សំរាប់ជីវិតអាពាហ៍ពិពាហ៍ ដែលកំពុងក្រេបសុភមង្គលថា « *ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន*

*កម្បតិ ឯតម្មង្គលមុត្តមំ* » « ចិត្តមិនរញ្ជួយ ញាប់ញ័រ ពេលដែលលោកធម៌ទាំង ៨ ចូលមកប៉ះ ជាមង្គលដ៏ឧត្តម » ។

*ចិត្តដែលមិនរញ្ជួយញាប់ញ័រព្រោះលោកធម៌ ជាមង្គលដ៏ឧត្តម ជាលោកុត្តរសុខ ជាសុខស្ថិតស្ថេរ ប្រសើរជាងលោកិយសុខ បុគ្គលអ្នកប្រាថ្នាសុភមង្គលដែលស្ថិតស្ថេរ គប្បីតាំងចិត្តឱ្យនឹង កុំរញ្ជួយញាប់ញ័រព្រោះលោកធម៌ទាំង ៨ ប្រការឱ្យសោះ ។*

**ចប់**

# គោលធម៌សំខាន់ៗបន្ថែម

**សប្បុរិសបញ្ញត្តិធម៌ ៣ :** គោលការណ៍សប្បុរស ៣ យ៉ាង

*១. ទាន* ការឱ្យ ការចែករំលែកគ្នា

*២. បព្វជ្ជា* តាំងខ្លួននៅក្នុងធម៌ គឺអហិង្សា

*៣. មាតាបិតុឧបដ្ឋាន* ទំនុកបំរុងមាតាបិតា

**បុត្រ ៣ ជំពូក :**

*១. អតិជាតបុត្រ* បុត្រប្រសើរជាងមាតាបិតា

*២. អនុជាតបុត្រ* បុត្រស្មើនឹងមាតាបិតា

*៣. អវជាតបុត្រ* បុត្រដែលថោកទាបជាងមាតាបិតា

**អគ្គិ ៣ :** ភ្លើង ៣ យ៉ាង

*១. អាហុនេយ្យគ្គិ* ភ្លើងគួរបូជា បានដល់មាតាបិតា

*២. គហបតគ្គិ:* ភ្លើងម្ចាស់ផ្ទះ បានដល់បុត្រភរិយា និងអ្នកនៅក្រោមអាណាព្យាបាល

*៣. ទក្ខិណេយ្យគ្គិ* ភ្លើងគួរដល់ទក្ខិណា បានដល់ព្រះសង្ឃ

**ប្រយោជន៍ ៣ យ៉ាង** ដែលបុគ្គលត្រូវស្វែងរក

ក. *១. ទិដ្ឋធម្មិកត្ថ:* ប្រយោជន៍បច្ចុប្បន្ន

*២. សម្បរាយិកត្ថ:* ប្រយោជន៍នាអនាគត ឬជាតិមុខ

*៣. បរមត្ថ:* ប្រយោជន៍ខ្ពស់បំផុត បានដល់ព្រះនិព្វាន

ខ. ១. *អត្តត្ថៈ* ប្រយោជន៍ផ្ទាល់ខ្លួន

២. *បរត្ថៈ* ប្រយោជន៍អ្នកដទៃ

៣. *ឧភយត្ថៈ* ប្រយោជន៍រួម

## អរិយសច្ច ៤ ៖ ធម៌សំរាប់តម្រង់ជីវិត និងដោះស្រាយបញ្ហាទុក្ខទាំងឡាយ

*១. ទុក្ខៈ ដឹងថានេះជាសេចក្ដីទុក្ខ ឬបញ្ហា*

*២. ទុក្ខសមុទយៈ ដឹងហេតុ ឬប្រភពដែលនាំឱ្យកើតទុក្ខ បញ្ហា*

*៣. និរោធៈ ដឹងសភាវៈដែលគ្មានទុក្ខ បញ្ហា ឬដឹងគោលបំណង*

## មជ្ឈិមបដិបទា ៖ ផ្លូវកណ្ដាលសំរាប់ជាជីវិតរបស់មនុស្ស

*១. សម្មាទិដ្ឋិ* យល់ត្រូវ

*២. សម្មាសង្កប្បៈ គិតត្រូវ*

*៣. សម្មាវាចា* និយាយត្រូវ

*៤. សម្មាកម្មន្តៈ ធ្វើការងារត្រូវ*

*៥. សម្មាអាជីវៈ* ចិញ្ចឹមជីវិតត្រូវ

*៦. សម្មាវាយាមៈ* ព្យាយាមត្រូវ

*៧. សម្មាសតិ* មានសតិរលឹកត្រូវ

*៨. សម្មាសមាធិ* តម្កល់ចិត្តត្រូវ

## សមជីវិតធម៌ ៤

*១. សមសទ្ធា* មានសទ្ធាស្មើគ្នា

*២. សមសីលា* មានសីលស្មើគ្នា

*៣. សមចាគា* មានចាគៈស្មើគ្នា

៤. *សមបញ្ញា* ៖ មានបញ្ញាស្មើគ្នា

**ឃរាវាសធម៌ ៤ ៖** ធម៌សំរាប់គ្រហស្ថមានផ្ទះសម្បែង

១. *សច្ចៈ* ស្មោះត្រង់ ពិត

២. *ទមៈ* ហ្វឹកហាត់ អប់រំនិស្ស័យ

៣. *ខន្តិ* អត់ធន់

៤. *ចាគៈ* លះបង់

**ចក្ក ៤ ៖** ធម៌សំរាប់នាំជីវិតទៅរកសេចក្តីចំរើនរុងរឿង ដូចកង់រថនាំទៅរកគោលដៅ ។

១. *បដិរូបទេសវាសៈ* រស់នៅក្នុងបរិយាកាសជុំវិញល្អ ទឹកដីល្អ

២. *សប្បុរិសូបសំសេវៈ* សេពគប់ជាមួយសប្បុរស

៣. *អត្តសម្មាបណិធិ* តាំងខ្លួនដោយត្រឹមត្រូវល្អ

៤. *បុព្វេកតបុញ្ញតា* ភាវៈជាអ្នកបានធ្វើអំពើល្អទុក

**ទិដ្ឋធម្មិកត្ថ ៤ ៖** ធម៌សំរាប់ឱ្យកើតប្រយោជន៍បច្ចុប្បន្ន

១. *ឧដ្ឋានសម្បទា* បរិបូណ៌ដោយការព្យាយាមរកទ្រព្យសម្បត្តិ

២. *អារក្ខសម្បទា* បរិបូណ៌ដោយការថែរក្សាទ្រព្យដែលគេរកបាន

៣. *កល្យាណមិត្តតា* សេពគប់មិត្តល្អ

៤. *សមជីវិតា* មានការរស់នៅដោយសមរម្យ

**សម្បរាយិកត្ថធម៌ ៤ ៖** ធម៌សំរាប់ការពារនូវប្រយោជន៍នាអនាគត

១. *សទ្ធាសម្បទា* បរិបូណ៌ដោយសទ្ធាលើកម្មផល

២. *សីលសម្បទា* បរិបូណ៌ដោយសីល គឺការប្រព្រឹត្តល្អ

WAT KHEMARARATANARAM

*៣. ចាគសម្បទា* ៖ បរិបូណ៌ដោយការលះបង់

*៤. បញ្ញាសម្បទា* ៖ បរិបូណ៌ដោយបញ្ញា

## កុលចិរដ្ឋិតិធម៌ ៤ ៖ ធម៌សំរាប់ឱ្យគង់វង្សត្រកូលតាំងនៅបានយូរ

*១. នដ្ឋគវេសនា* របស់បាត់ របស់អស់ ចេះរកមកទុក

*២. ជិណ្ណបដិសង្ខរណា* របស់ចាស់ បាក់បែក ចេះជួសជុល កែខៃ

*៣. បរិមិតបានភោជនា* ស្គាល់ប្រមាណក្នុងការប្រើប្រាស់ការបរិភោគ

*៤. អធិបច្ចសីលវតស្ថាបនា* តាំងអ្នកមានសីលធម៌ឱ្យធ្វើជាមេផ្ទះ

## សប្បុរិសធម៌ ៧ ៖ ធម៌សំរាប់សប្បុរសជន

*១. ធម្មញ្ញុតា* ដឹងអ្វីថាជាហេតុ ជាប្រភព

*២. អត្ថញ្ញុតា* ដឹងអ្វីថាជាផល ជាគោលដៅ

*៣. អត្តញ្ញុតា* ស្គាល់ខ្លួន

*៤. មត្តញ្ញុតា* ស្គាល់ប្រមាណ ស្គាល់ល្មម

*៥. កាលញ្ញុតា* ស្គាល់កាលវេលា

*៦. បរិសញ្ញុតា* ស្គាល់ប្រជុំជន

*៧. បុគ្គលញ្ញុតា* ស្គាល់បុគ្គលម្នាក់ៗ

# ឯកសារពិគ្រោះ

- ព្រះត្រៃបិដកខ្មែរ របស់បណ្ណាល័យមជ្ឈមណ្ឌលស្រាវជ្រាវព្រះពុទ្ធសាសនាខ្មែរ
- សាសនសុភាសិត ភាគ ១ . ២ . ៣
- វចនានុក្រមខ្មែរ ភាគ ១ . ២
- ច្បាប់ផ្សេងៗ
- ធម្មសង្គហៈ
- Dictionary of Buddhism Mahachulalongkorn Buddhist University, Thailand
- និងឯកសារមួយចំនួនទៀត

WAT KHEMARARATANARAM

គ្រួសារគឺជាកោសិកាសង្គមដ៏តូចបំផុត ។ ឬ បើនិយាយត្រឡប់មកវិញ សង្គមគឺជាការរួមប្រជុំ នៃ គ្រួសារទាំងឡាយ ។ គ្រួសារគឺជាការកំណត់របស់សង្គម ទាំងផ្នែកសន្តិភាព សុខុមាលភាព និង វិបុលភាព ។ ពួកយើងច្រើនតែមើលរំលងទៅលើស្ថាប័នដទៃទៀតមាន ការគ្រប់គ្រង ការសិក្សា សាសនា ការកំសាន្ត និងជាពិសេសស្ថាប័ន សេដ្ឋកិច្ច ហើយច្រើនតែមើលទៅលើសង្គមរួមទាំងមូលជាបែបមហាភាគ ។ គ្រួសារមានលក្ខណៈជាសង្គមមួយដោយបរិបូណ៌ ។ បើសង្គមតូចនេះល្អ គ្មានជំងឺ សង្គមធំក៏ល្អ និង មានសុខភាពល្អដែរ ។ ក្នុងខ្លួនមនុស្សយើងការរកឃើញ មេរោគមហារីក បានបង្ហាញអោយដឹងថា រោគនេះកើតឡើងដោយកោសិកាក្នុងខ្លួនយើងត្រង់ណាមួយ << ឆ្កួត >> ឬ << មិនធ្វើការទៅតាមមុខនាទីខ្លួន >> ដែលគួរធ្វើ ទៅនាំគេនាំឯងរហូតវិនាសសាច់ត្រង់នោះ ។ រចនាករ យល់ឃើញថា បើសង្គមគ្រួសារ << ឆ្កួត >> ឬ << មិនធ្វើតាមតួនាទីខ្លួន >> ដែលគួរធ្វើទេ សង្គមមនុស្សនោះប្រាកដជាកើតរោគមហារីកដែរ ជាមិនខាន ។

តម្លៃ ១៣៥០០ ៛